# របាយការណ៍ឃ្លាំមើលលទ្ធផល ការបំពេញ/អនុវត្តន៍គោលនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ ឆ្នាំទី១

ខុមហ្វ្រែល COMFREL


«យុទ្ធសាស្ត្រចតុកោណ»

ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព :

កសាងមូលដ្ឋានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

ដំណាក់កាលទី ៤

របស់រាជរដ្ឋាភិបាល នីតិកាលទី ៦នៃរដ្ឋសភា

ខែ ស្រាពណ៍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១៨

ការបង្កើតរាជរដ្ឋាភិបាល

សមាជិករាជរដ្ឋាភិបាល

ស្ថាប័នក្រោមចំណុះថ្មី

ថវិកាថ្នាក់ជាតិក្រោងចំណាយ

គោលនយោបាយ និងការអនុវត្តន៍៖ លទ្ធផល និងបញ្ហាប្រឈម

ខែកុម្ភៈ ឆ្នាំ២០២០

# របាយការណ៍

# ស្តីពី

# ការឃ្លាំមើលលើលទ្ធផល

# នៃការបំពេញ/អនុវត្តន៍គោលនយោបាយ

# របស់រាជរដ្ឋាភិបាលនីតិកាលទី៦ ឆ្នាំទី១

# មាតិកា


I. ខ្លឹមសារសង្ខេប ..... 4

II. សេចក្តីផ្តើម ..... 6

III. វិធីសាស្ត្រ និងដែនកំណត់នៃរបាយការណ៍ ..... 7

IV. ការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី៦ ..... 7

V. សមាជិករាជរដ្ឋាភិបាល និងការបង្កើតស្ថាប័នក្រោមចំណុះថ្មី ..... 9

1. សមាជិករាជរដ្ឋាភិបាល ..... 9

2. ការបង្កើតស្ថាប័នក្រោមចំណុះថ្មី ..... 11

VI. ថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ២០១៩ ..... 13

VII. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៦ ..... 14

VIII. ការអនុវត្តគោលនយោបាយ៖ លទ្ធផល និងបញ្ហាប្រឈម ..... 16

1. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច ..... 16

1.1. ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន ..... 17

1.2. ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ..... 20

1.3. ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ..... 22

1.4. ការពង្រឹងអភិបាលកិច្ចល្អវិស័យឯកជន ..... 23

2. គោលនយោបាយ និងការងារអាទិភាព នៃបរិយាស្ថានអនុវត្តយុទ្ធសាស្ត្រទាំងមូល ..... 25

2.1. សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ ..... 26

2.2. បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ ..... 29

2.3. ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ ..... 31

2.4. ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ..... 32

3. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍធនធានមនុស្ស ..... 35

3.1. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ..... 35

3.2. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ..... 39

3.3. ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ ..... 40

3.4. ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម .......... 42
4. គោលនយោបាយ និងការងារអាទិភាព នៃការធ្វើពិពិធកម្មសេដ្ឋកិច្ច .......... 43
4.1. កែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល .......... 43
4.2. ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ .......... 46
4.3. ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ .......... 49
4.4. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ .......... 51
5. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍវិស័យឯកជន និងការងារ .......... 54
5.1. ការអភិវឌ្ឍទីផ្សារការងារ .......... 54
5.2. ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព .......... 57
5.3. ការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន .......... 59
5.4. ការពង្រឹងការប្រកួតប្រជែង .......... 63
6. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន .......... 63
6.1. ការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍជនបទ .......... 64
6.2. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព .......... 67
6.3. ការពង្រឹងការគ្រប់គ្រងនគររូបនីយកម្ម .......... 71
6.4. ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ .......... 73
IX. សេចក្តីសន្និដ្ឋាន .......... 75

## I. ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ ត្រូវបានបង្កើតឡើងចេញពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ។ រដ្ឋសភាបានរៀបចំដំណើរការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការនានានៃរដ្ឋសភា និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលនីតិកាលទី ៦ នេះ ដោយប្រើប្រាស់នីតិវិធីបោះឆ្នោតជាកញ្ចប់ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០១៨ ។

ខុសពីនីតិកាលទី ៥ ដោយសារគណបក្សប្រជាជនកម្ពុជា បានឈ្នះឆ្នោត និងទទួលបានអសនៈរដ្ឋសភាចំនួន ១២៥ ទាំងស្រុង រដ្ឋសភានីតិកាលទី៦ នេះ មានថ្នាក់ដឹកនាំរដ្ឋសភា និងថ្នាក់ដឹកនាំនៃគណៈកម្មការជំនាញរដ្ឋសភា មានសមាសភាពមកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់។

នីតិវិធីនៃការបង្កើតរដ្ឋាភិបាលនេះត្រូវបានអនុវត្តតាមស្មារតីមាត្រា ០៤ នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម។ ប៉ុន្តែ ដើម្បីបង្កើតរាជរដ្ឋាភិបាល យោងតាមបទបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជាធរមាន ជាដំបូង គេត្រូវបង្កើតថ្នាក់ដឹកនាំរដ្ឋសភា តាមមាត្រា ៨២ ថ្មីនៃរដ្ឋធម្មនុញ្ញជាមុនសិន រួចទើបអនុវត្តមាត្រា ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញ។ យោងលើមាត្រា ៨២ ថ្មី គេត្រូវការសំឡេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ពោលគឺ ៦២ សម្លេងតែប៉ុណ្ណោះ ដើម្បីបោះឆ្នោតបង្កើតថ្នាក់ដឹកនាំរដ្ឋសភា ខណៈដែលកូរ៉ុមសម្រាប់សម័យប្រជុំលើកទី ១ នោះមានចំនួនដល់ទៅ ១២៥រូប ដែលសមាសភាពទាំងអស់នោះមកពីគណបក្សប្រជាជនកម្ពុជា។ ដូច្នេះ ពិតប្រាកដណាស់ យើងអាចសន្និដ្ឋានបានថា មាត្រា ៨២ថ្មីនៃរដ្ឋធម្មនុញ្ញត្រូវសម្រេចទៅបាន ដោយមិនចាំបាច់ប្រើប្រាស់មាត្រា ០៤ នៃច្បាប់ធម្មនុញ្ញបន្ថែម ដែលនាំឲ្យផ្ទុយពីស្មារតីមាត្រា ៨២ថ្មី និងមាត្រា ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញ និងមាត្រា ០៣ នៃច្បាប់រដ្ឋធម្មនុញ្ញបន្ថែម។

រាជរដ្ឋាភិបាលនីតិកាលទី ៦ មានក្រសួងចំនួន ២៨ និងមានលេខាធិការដ្ឋានចំនួន ១ សម្រាប់អនុវត្តគោលនយោបាយរបស់ខ្លួន។ ដោយសារតែការធ្វើវិសោធនកម្មមាត្រា ១១៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ០៤ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដោយកែប្រែសមាសភាពសមាជិករដ្ឋាភិបាលមានដូចជា៖ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី រាជរដ្ឋាភិបាលនេះ មានសមាជិកត្រឹមតែចំនួន ៤៦រូប នៃតួនាទីចំនួន៥៧ (នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ១០ ទេសរដ្ឋមន្ត្រី ១៧ រដ្ឋមន្ត្រី ២៩) នៅពេលចាប់ផ្តើមអាណត្តិរបស់ខ្លួន ។ ប៉ុន្តែ រាជរដ្ឋាភិបាលមានមន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៨៥៨ រូបជារដ្ឋលេខាធិការ ២៤១ រូប អនុរដ្ឋលេខាធិការ ៣៩១ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១៩ រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប។ ដោយសារតែគ្មានបទបញ្ញត្តិកំណត់ពីចំនួនរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃបណ្តាក្រសួងនានា ចំនួននេះបានកើនឡើងនៅនីតិកាលទី៦ ។ ការបន្តកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនីតិកាលទី៦ ក៏ជាមូលហេតុមួយនៃការបន្ថែមបន្ទុកចំណាយថវិកាជាតិប្រចាំឆ្នាំផងដែរ។ គួរឲ្យកត់សម្គាល់ផងដែរថា ក្រោយពីរាជរដ្ឋាភិបាលនីតិកាលទី៦ ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០១៨ ចំនួន

ថវិកាចំណាយរបស់រាជរដ្ឋាភិបាល បានកើនឡើងដល់ជាង ៦,៧ ពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៩[1] និង ៨,២ ពាន់លានដុល្លារសម្រាប់ឆ្នាំ២០២០ បើប្រៀបធៀបជាមួយឆ្នាំ ២០១៨ ថវិកាមានចំនួនប្រមាណត្រឹមតែ ៦ ពាន់លានដុល្លារ[2]។

រដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ការកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ គឺមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ។ គេមានជំនឿថា ការកំណែទម្រង់ណាមួយដែលធ្វើឡើងដោយគ្មានការវាយតម្លៃឯករាជ្យជាមុនសិននោះទេ ពិតជានឹងមិនមានប្រសិទ្ធិភាពខ្ពស់ឡើយ។

រាជរដ្ឋាភិបាលនីតិកាលទី៦ បានបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។ ការបង្កើតស្ថាប័នថ្មីនេះមានគោលបំណងលើកស្ទួយរបបនយោបាយសេរីពហុបក្សនៅកម្ពុជា។ គណបក្សនយោបាយចំនួន ១៦ រួមទាំងគណបក្សប្រជាជនកម្ពុជា ក្នុងចំណោមគណបក្សនយោបាយចំនួន ២០ បានចូលរួម និងក្លាយជាប្រតិភូគណបក្សក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដែលមានសមាជិកសរុប ៣០ រូប។ ប្រតិភូដែលបានចូលរួមក្នុងឧត្តមក្រុមប្រឹក្សានេះត្រូវបានផ្តល់ឋានៈស្មើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ហើយមានភារកិច្ចចំបងៗ ដូចជា ការផ្តួចផ្តើមគំនិត ឬផ្តល់យោបល់លើការរៀបចំគោលនយោបាយ ឬសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងការតាមដានការអនុវត្តច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។[3] យន្តការថ្មីនេះត្រូវបានគេវាយតម្លៃថា ជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ នៅពេលសភាមានតំណាងរាស្ត្រមកពីគណបក្សតែមួយ។ ស្ថាប័នថ្មីនេះមិនមានស្វ័យភាពថវិកា និងមានលេខាធិការដ្ឋានក្រោមការគ្រប់គ្រងរបស់ប្រមុខស្ថាប័ននីតិប្រតិបត្តិ ដែលនាំឲ្យមិនផ្តល់ឯករាជ្យភាពពេញលេញដល់ប្រតិភូគណបក្សក្នុងការបំពេញភារកិច្ចរបស់ខ្លួនទេ។ ម្យ៉ាងទៀត ការបង្កើតយន្តការថ្មីនេះ ដែលជំនួសយន្តការសភា ដើម្បីទទួលយកធាតុចូលពីគណបក្សនយោបាយមិនមានអាសនៈក្នុងសភា មិនទទួលបាននីត្យានុកូលភាពជាតំណាងពីប្រជាពលរដ្ឋឡើយ ព្រោះប្រតិភូនៃគណបក្សនយោបាយទាំងនោះមិនទាន់បានទទួលសេចក្តីទុកចិត្តពីប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតកាលពីឆ្នាំ២០១៨នោះឡើយ។

រាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៩ ប្រមាណ ៦.៤៤១ លានដុល្លារអាមេរិក ដើម្បីអនុវត្តគោលនយោបាយ និងកិច្ចការងារជាអាទិភាពរបស់ខ្លួននៅក្នុងឆ្នាំទី ១ នៃនីតិកាលទី៦ ។ បើប្រៀបធៀបនឹងខណៈពេលដូចគ្នានឹងនីតិកាលទី ៥ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពចំណាយខ្ពស់លើវិស័យសេដ្ឋកិច្ច ចាប់តាំងពីដើមនីតិកាលទី៦ ។ នៅឆ្នាំ ២០១៩ រដ្ឋាភិបាលកម្ពុជាបានគ្រោងនឹងខ្ចីប្រាក់ពីដៃ

[1] Khmer Times: National Budget 2020 Approved, By Chea Vannak, November 27th , 2019; https://www.khmertimeskh.com/664298/national-budget-for-2020-approved/

[3] មាត្រា១០ នៃព្រះរាជក្រមស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ០៦ កញ្ញា ២០១៨

គូអភិវឌ្ឍន៍បរទេស ក្នុងកម្រិត ១.៤០០លាន SDR ឬ ស្មើនឹងប្រមាណជិត ២ ពាន់លានដុល្លារបន្ថែមទៀត យោងតាមសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ។

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៦ ដាក់ជូនរដ្ឋសភាជាតិនូវកម្មវិធីនយោបាយរបស់ខ្លួន ដែលគូសបញ្ជាក់អំពីការធានាការពារនូវសន្តិភាព ស្ថិរភាព សន្តិសុខ និងសុវត្ថិភាពភូមិ/ឃុំ ការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ការធានាបន្តជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមក្នុងគ្រប់វិស័យ ការធានាបន្តជំរុញលើកកម្ពស់ជីវភាពរបស់ប្រជាជន និងការធានាសុវត្ថិភាពសង្គម និងលំនឹងក្នុងការរស់នៅរបស់ប្រជាជនទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត។

គោលនយោបាយ និងកិច្ចការងារជាអាទិភាពដែលបានចែង ឬសន្យា តាមរយៈយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ត្រូវបានកំណត់ថា មាន៦ ផ្នែកធំៗរួមមាន ស្នូលនៃយុទ្ធសាស្រ្តចតុកោណ ដែលសំដៅដល់ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច, បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្រ្តទាំងមូល, ការអភិវឌ្ឍធនធានមនុស្ស, ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការអភិវឌ្ឍវិស័យឯកជន និងការងារ, និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។

គោលនយោបាយដែលបានបែងចែកជា ៦ ផ្នែកធំៗ និងចំណុចការងារអាទិភាពរបស់រដ្ឋាភិបាលស្របគ្នាទាំងស្រុងនៅទៅនឹងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ។ អ្វីដែលគួរឲ្យកត់សម្គាល់នៅក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ រដ្ឋាភិបាលបានសន្យាការអនុវត្តគោលនយោបាយទាំងនោះ ដោយមិនបានកំណត់សូចនាករច្បាស់លាស់នោះទេ។ ក្នុងរយៈពេលជាងមួយឆ្នាំដំបូងនៃកាន់អំណាចនេះ រដ្ឋាភិបាលបានអនុវត្តផ្នែកខ្លះនៃគោលនយោបាយរបស់ខ្លួន។ ការខិតខំរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន បានជួបបញ្ហាប្រឈមធំៗទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ។

## II. សេចក្តីផ្តើម

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានអនុវត្តគម្រោងឃ្លាំមើលការអនុវត្តការសន្យារបស់រាជរដ្ឋាភិបាល តាំងពីនីតិកាលទី ៣ នៃរដ្ឋសភា និងនីតិកាលបន្តបន្ទាប់ រហូតដល់នីតិកាលទី៦ នៃរដ្ឋសភា។ របាយការណ៍ឃ្លាំមើលការអនុវត្តន៍ការសន្យារបស់រាជរដ្ឋាភិ បាល ត្រូវបានបង្កើតឡើងជារៀងរាល់ឆ្នាំ ដើម្បីវាយតម្លៃចំពោះការអនុវត្តន៍ការសន្យា ផ្អែកតាមគោលនយោបាយរបស់ខ្លួនដែលបានដាក់ចេញនៅដើមនីតិកាលនីមួយៗ។ រាជរដ្ឋាភិបាលនីតិកាលទី៦ នេះ ត្រូវបានរដ្ឋសភាដែលមានតំណាងរាស្រ្តមកពីគណបក្សតែមួយ គឺគណបក្សប្រជាជនកម្ពុជា បោះឆ្នោតផ្តល់សេចក្តីទុកចិត្តថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨[4] ។

ក្នុងនីតិកាលទី៦ ទាំងរដ្ឋាភិបាល និងរដ្ឋសភា ស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុ

---

[4] Also see: Xinhua: Cambodian PM Changes date of forming new gov't after winning election, August 8th 2018; http://www.xinhuanet.com/english/2018-08/08/c_137375680.htm

ជាតែមួយគត់ ខុសពីអាណត្តិមុនៗដែលរដ្ឋាភិបាលដឹកនាំដោយគណបក្សកាន់អំណាច ចំណែកឯគណបក្សប្រឆាំងមានតំណាងរាស្ត្រនៅក្នុងរដ្ឋសភា។

ក្រោយពីចូលកាន់តំណែង នាយករដ្ឋមន្ត្រីបានប្រកាសដាក់ចេញជាផ្លូវការ ក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ នូវការដាក់ចេញការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលមានមូលដ្ឋានពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ និងជាមូលដ្ឋានក្នុងការរៀបចំ និងបង្កើតផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ គឺដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។

ដើម្បីបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវ នូវអ្វីដែលបានសន្យា អង្គការខុមហ្វ្រែល បានសង្កេត លើការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងឆ្នាំទី ១ នៃនីតិកាលទី៦ ខុមហ្វ្រែល បានសិក្សារបាយការណ៍ ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធ និងគោលនយោបាយ ដើម្បីវាយតម្លៃ និងចងក្រងជាបាយការណ៍នេះ ។

## III. វិធីសាស្ត្រ និងដែនកំណត់នៃរបាយការណ៍

របាយការណ៍នេះកើតចេញពីការវិភាគលើទិន្នន័យ និងព័ត៌មានដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ ។

ក្នុងការចងក្រងរបាយការណ៍ស្តីពីការឃ្លាំមើលដំណើរការ និងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល យើងក៏មានបញ្ហាប្រឈមមួយចំនួនផងដែរដូចជា ការខ្វះខាតព័ត៌មានសម្រាប់ការវិភាគ ដែលបណ្តាលមកពីការមិនអាចទទួលបានជាសាធារណៈនូវទិន្នន័យ ព័ត៌មាន ឯកសារ និងរបាយការណ៍មួយចំនួនពីស្ថាប័នរបស់រដ្ឋ។ សិទ្ធិទទួលបានព័ត៌មានប្រកបដោយតម្លាភាពពីស្ថាប័នរដ្ឋ នៅតែជាឧបសគ្គសម្រាប់ការធ្វើរបាយការណ៍នេះ។

## IV. ការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី៦

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ បានបង្កើតឡើងពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ កន្លងមក ដែលមានភាពសម្រូងចម្រាស់ និងត្រូវបានមតិជាតិ និងអន្តរជាតិ រិះគន់ថា មិនមានការប្រកួតប្រជែងផ្នែកនយោបាយនឹងគណបក្សកាន់អំណាច ព្រោះគណបក្សប្រឆាំងដែលមានសំឡេងគាំទ្រច្រើនត្រូវបានផាត់ចេញពីការបោះឆ្នោតនោះ។ ទាំងអង្គការសហប្រជាជាតិ និងបណ្តាប្រទេសលោកខាងលិចបានពិពណ៌នា អំពីការបោះឆ្នោតនេះថា មានលក្ខណៈមិនត្រឹមត្រូវ បន្ទាប់ពីតុលាការកំពូលបានរំលាយ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងធំមួយ ជុំវិញការចោទប្រកាន់ថា បានរៀបចំ

ផែនការផ្តួលរំលំរដ្ឋាភិបាល។[5]

ក្រោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានបេក្ខជនជាប់ឆ្នោតចំនួន ១២៥ រូប មកពីគណបក្សកាន់អំណាចពោលគឺ គណបក្សប្រជាជនកម្ពុជា រដ្ឋសភាជាតិ បានបើកកិច្ចប្រជុំដំបូង នៅថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០១៨ ក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ **នរោត្តម សីហមុនី** ។ នៅក្នុងកិច្ចប្រជុំនោះ បេក្ខជនជាប់ឆ្នោតចំនួន ១២៥ មកពី គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្តល់សុពលភាពជាតំណាងរាស្ត្រ។

រដ្ឋសភាជាតិបានរៀបចំដំណើរការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា និងប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការជំនាញនានានៃរដ្ឋសភា និងបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលនីតិកាលទី៦ នេះ ដោយប្រើប្រាស់នីតិវិធីបោះឆ្នោតជាកញ្ចប់កាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨ ។

ខុសពីនីតិកាលទី ៥ ដោយសារគណបក្សប្រជាជនកម្ពុជាបានឈ្នះឆ្នោត និងទទួលបានអសនៈរដ្ឋសភាទាំស្រុងចំនួន ១២៥ រដ្ឋសភានីតិកាលទី៦ នេះ មានថ្នាក់ដឹកនាំរដ្ឋសភា និងថ្នាក់ដឹកនាំនៃគណៈកម្មការជំនាញរដ្ឋសភាដែលសមាសភាពមកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់។

ប៉ុន្តែ បើពិនិត្យមើលទៅលើច្បាប់ធម្មនុញ្ញបន្ថែមនៃច្បាប់នេះ ត្រង់មាត្រា ៣ បានចែងយ៉ាងច្បាស់ថា ក្នុងករណីដែលឃើញថា នីតិវិធីនៃមាត្រា ៨២ ថ្មី និង ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញ[6] មិនអាចសម្រេចបាន រដ្ឋសភាតាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការបោះឆ្នោតជាកញ្ចប់ ដើម្បីជ្រើសតាំងប្រធាន អនុប្រធាន ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះសមាជិករដ្ឋាភិបាល។ ចំណែកមាត្រា ៨២ ថ្មីនៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី ២ បានចែងថា មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានរដ្ឋសភា និងសមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ដោយឡែកវាក្យខណ្ឌទី ១ មាត្រា ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញបានចែងថា តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលបោះឆ្នោតឲ្យបង្កើតរាជរដ្ឋាភិបាល។ វរជនដែលត្រូវបានចាត់តាំងនោះ នាំសហការីដែលជាតំណាង

[5] Reuters World News: Cambodia's parliament holds first session since July vote, by Prak Chanthul, 5th September 2018; https://www.reuters.com/article/us-cambodia-politics/cambodias-parliament-holds-first-session-since-july-vote-idUSKCN1LL0GM
[6] The Constitution of the Kingdom of Cambodia, Unofficial Translation Version supervised by the Constitutional Council of Cambodia, March 2010

រាស្ត្រ ឬសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តួចផ្តើមឲ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ផ្អែកលើនីតិវិធីដែលបានរៀបរាប់ ដើម្បីបង្កើតរាជរដ្ឋាភិបាល យោងតាមបទបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជាធរមាន ដំបូងគេត្រូវបង្កើតថ្នាក់ដឹកនាំរដ្ឋសភា តាមមាត្រា ៨២ថ្មីនៃរដ្ឋធម្មនុញ្ញជាមុនសិន រួចទើបអនុវត្តមាត្រា ១១៩ ថ្មីរដ្ឋធម្មនុញ្ញ។

យោងលើមាត្រា ៨២ ថ្មី គេត្រូវការសំឡេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ពោលគឺ ៦២ សំឡេងតែប៉ុណ្ណោះ ដើម្បីបោះឆ្នោតបង្កើតថ្នាក់ដឹកនាំរដ្ឋសភា ខណៈដែលកូរ៉ុមសម្រាប់សម័យប្រជុំលើកទី ១ នោះមានចំនួនដល់ទៅ ១២៥ ដែលសមាសភាពទាំងអស់នោះមកពីគណបក្សប្រជាជនកម្ពុជា ។ ដូច្នេះពិតប្រាកដណាស់ យើងអាចសន្និដ្ឋានថា មាត្រា ៨២ ថ្មីនៃរដ្ឋធម្មនុញ្ញត្រូវសម្រេចបាន ដោយមិនចាំបាច់ប្រើប្រាស់មាត្រា ៣[7] និងមាត្រា ៤ នៃច្បាប់ធម្មនុញ្ញបន្ថែម ដែលនាំឲ្យផ្ទុយពីស្មារតីនៃមាត្រា ៨២ ថ្មី និងមាត្រា ១១៩ ថ្មីនៃរដ្ឋធម្មនុញ្ញ។

## V. សមាជិករាជរដ្ឋាភិបាល និងការបង្កើតស្ថាប័នក្រោមចំណុះថ្មី

### 1. សមាជិករាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី ៦ ដឹកនាំដោយ គណបក្សប្រជាជនកម្ពុជាមានក្រសួងចំនួន ២៨[8] និងមានលេខាធិការដ្ឋានចំនួន ១ នៅពេលចាប់ផ្តើមនីតិកាល។ ហើយនៅពេលចាប់ផ្តើមអាណត្តិរបស់ខ្លួន រាជរដ្ឋាភិបាលនេះមានសមាជិកចំនួន ៨៦ រូប នៃតួនាទីចំនួន ៥៧ (នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ១០ ទេសរដ្ឋមន្ត្រី ១៧ រដ្ឋមន្ត្រី ២៩)។ ហើយរាជរដ្ឋាភិបាលមានមន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៨៥៨ រូប ដែលជារដ្ឋលេខាធិការ ២៤១ រូប អនុរដ្ឋលេខាធិការ ៣៩១ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១៩ រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប។

| ប្រភេទ | នីតិកាលទី ៤ (ចំនួនតួនាទី) | នីតិកាលទី ៥ (ចំនួនតួនាទី) | នីតិកាលទី៦ (ចំនួនតួនាទី) |
|---|---|---|---|
| ➢ នាយរដ្ឋមន្ត្រី | 01 (ស្រី 0នាក់) | 01 (ស្រី 0 នាក់) | 01 (ស្រី 0នាក់) |
| ➢ ឧបនាយករដ្ឋមន្ត្រី | 09 (ស្រី 01នាក់) | 09 (ស្រី 01 នាក់) | 10 (ស្រី 01 នាក់) |
| ➢ ទេសរដ្ឋមន្ត្រី | 16 (ស្រី 0នាក់) | 15 (ស្រី 0 នាក់) | 17 (ស្រី 0នាក់) |
| ➢ រដ្ឋមន្ត្រី | 26 (ស្រី 02នាក់) | 28 (ស្រី 03 នាក់) | 29 (ស្រី 03នាក់) |
| ➢ រដ្ឋមន្ត្រីអមនាយករដ្ឋមន្ត្រី | 08 (ស្រី 0នាក់ ) | 14 (ស្រី 0 នាក់) | 19 (ស្រី 0នាក់) |
| ➢ រដ្ឋលេខាធិការ | 206 (ស្រី 15នាក់) | 187 (ស្រី 38 នាក់) | 241 (ស្រី 37នាក់) |
| ➢ អនុរដ្ឋលេខាធិការ | | | 391 (ស្រី 58នាក់) |
| ➢ ទីប្រឹក្សារាជរដ្ឋាភិបាល | | | 207 (ស្រី17នាក់) |

[7] ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា៨២ និង១១៩ថ្មី នៃរដ្ឋធម្មនុញ្ញមិនអាចសម្រេចបាន រដ្ឋសភាតាមសំណើរបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភាអាចដំណើរការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជាប្រធាន និងអនុប្រធានគណៈកម្មការក្នុងពេលជាមួយគ្នា និងការផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាល។

[8] ព្រះរាជក្រឹត្យលេខ០៩១៨/៩២៥, នរោត្តម សីហមុនី, ០៦ កញ្ញា ២០១៨

បើប្រៀបធៀបជាមួយរយៈពេលដើមនីតិកាលទី ៥ ចំនួនសមាជិករដ្ឋាភិបាលដែលជាគណៈរដ្ឋមន្ត្រីមានចំនួនថយចុះយ៉ាងខ្លាំងពី ២៤៤ រូប មកត្រឹម ៤៦ រូប។ ការធ្លាក់ចុះចំនួនសមាជិករាជរដ្ឋាភិបាលបណ្តាលមកពីការធ្វើវិសោធនកម្ម មាត្រា ១១៨[9] នៃរដ្ឋធម្មនុញ្ញ និង មាត្រា ៨[10] នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដោយកែប្រែសមាសភាពសមាជិករដ្ឋាភិបាលមានដូចជា នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី។ ដោយឡែក អនុរដ្ឋលេខាធិការមិនត្រូវបានកំណត់ជាសមាភាពរដ្ឋាភិបាលឡើយ។ ការដកចេញនូវតួនាទីរដ្ឋលេខាធិការពីសមាជិករាជរដ្ឋាភិបាល នឹងនាំឲ្យចំនួនសមាជិករដ្ឋាភិបាល និងចំនួនជាតួនាទីសមាជិកគណៈរដ្ឋមន្ត្រីធ្លាក់ចុះ បើប្រៀបធៀបនឹងចំនួនក្នុងនីតិកាលកន្លងមក ប៉ុន្តែ នៅតែមិនទាន់ធានាបាននូវការធ្លាក់ចុះចំនួនមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលនោះទេ ស្របពេលដែលត្រូវបានគេរិះគន់ផងដែរថា នៅកម្ពុជា កំពុងមានកំណើនកើនឡើងយ៉ាងច្រើនរហូតដល់ធ្វើឲ្យមាននូវអតិផរណាតួនាទីឯកឧត្តម[11] នៅពេលដែលមន្ត្រីរដ្ឋាភិបាលកាន់តែច្រើនទទួលបានការតំឡើងឋានៈជាឯកឧត្តម ឬលោកជំទាវ។

ការធ្វើវិសោធកម្មនេះ បណ្តាលឲ្យមានការកែប្រែនីតិវិធីនៃការតែងតាំងរដ្ឋលេខាធិការនៃក្រសួងនិងស្ថាប័នរដ្ឋាភិបាល ដោយអនុញ្ញាតឲ្យតួនាទីរដ្ឋលេខាធិកាត្រូវបានតែងតាំងតាមសំណើររបស់នាយករដ្ឋមន្ត្រីទៅព្រះមហាក្សត្រ និងមិនតម្រូវឲ្យបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភានោះទេ។ ដូចនេះ រដ្ឋលេខាធិការនឹងមិនមានកាតព្វកិច្ចទទួលខុសត្រូវ ចំពោះរដ្ឋសភាដែលស្ថាប័ននីតិបញ្ញត្តិកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។ អ្វីដែលគួរឲ្យកត់សម្គាល់ នៅពេលដែលនីតិវិធីតែងតាំងរដ្ឋលេខាធិការ មិនត្រូវឲ្យមានការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភា ចំនួនរដ្ឋលេខាធិកាអាចនឹងកើនឡើង ក្រោមហេតុផលដូចគ្នានឹងការតែងតាំងតួនាទីអនុរដ្ឋលេខាធិការ ដោយសារតែគ្មានបទបញ្ញត្តិកំណត់ពីចំនួនរដ្ឋាលេខាធិការ ចំនួនអនុរដ្ឋលេខាធិការនៃបណ្តាក្រសួងនានា។ ជាក់ស្តែងនៅដើមនីតិកាលទី ៥ រដ្ឋលេខាធិការមានចំនួន ១៨៧ រូប ហើយចំនួននេះបានកើនឡើងដល់ ២៤១ រូបនៅនីតិកាលទី៦ ។ ចំនួនអនុរដ្ឋលេខាធិការបានកើនឡើងពី ២៣៨ រូប ដល់៣៩១ រូប និងចំនួនរដ្ឋមន្ត្រីអបប្រតិភូនាយករដ្ឋមន្ត្រីកើតឡើងពី ១៤ រូប ដល់ ១៩ រូប បើប្រៀបធៀបក្នុងខណៈពេលដើមនីតិកាលដូចគ្នា[12]។

---

[99] Cambodia Constitution, Article 118 states: The Council of Ministers is the Royal Government of Cambodia. The Council of Ministers shall be led by one Prime Minister assisted by Deputy Prime Ministers, and by State Ministers, Ministers as members.

[10] សមាសភាពនៃរាជរដ្ឋាភិបាលមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី។

[11] Khmer Times: Leading reforms in Cambodia’s government, January 17th, 2020, https://www.khmertimeskh.com/680458/leading-reforms-in-government/

[12] ទំព័រទី៩៨, របាយការណ៍ឃ្លាំមើល និងការផ្តល់ពិន្ទុលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥, ដោយ ខុមហ្វ្រែល, កុម្ភៈ ២០១៩

យើងអាចសន្និដ្ឋានបានថា បើទោះបីជាចំនួនសមាជិកនៃរាជរដ្ឋាភិបាលនីតិកាលទី៦ បានថយយ៉ាងច្រើន ចំនួនមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនៅតែបន្តកើនឡើងដដែល។ ការបន្តកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលនីតិកាលទី៦ ក៏ជាមូលហេតុមួយនៃការបន្ថែមបន្ទុកចំណាយថវិកាជាតិប្រចាំឆ្នាំផងដែរ។ តាមច្បាប់ថវិកាជាតិសម្រាប់ការគ្រប់គ្រង រាជរដ្ឋាភិបាលគ្រោងថវិកាចំនួន ២,១ ពាន់លានដុល្លារអាមេរិកសម្រាប់ប្រាក់បៀវត្សរ៍មន្ត្រីរាជការ ក្នុងឆ្នាំ ២០២០។[13] រាជរដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ការកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ គឺមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ ស្របពេលដែលមានមតិរិះគន់លើកឡើងថា "មេដឹកនាំជំនាន់ថ្មីនៃវិស័យសាធារណៈនៅកម្ពុជា យ៉ាងហោចណាស់ ត្រូវមានផ្នត់គំនិតបែបកំណែទម្រង់ លើកស្ទួយការបង្កើតថ្មី និងទទួលយកនូវការផ្លាស់ប្តូរ។ របៀបដឹកនាំកន្លងមកដែលពឹងផ្អែកបុគ្គលនិយម និងទឹកប្រាក់នឹងមិនអាចអនុវត្តបានទៀតឡើយ"[14]។

អ្វីគួរកត់សម្គាល់នោះ គឺចំនួនស្ត្រីក្នុងសមាសភាពគណរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលបានកើនឡើងក្នុងអំឡុងពេលនៃពីរនីតិកាលចុងក្រោយនេះ។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានលើកឡើងថា « រដ្ឋមន្ត្រីជាស្ត្រីបានកើនឡើងពី សូន្យ ដល់ចំនួន០៣ រដ្ឋលេខាធិការជាស្ត្រីកើនដល់ចំនួន៥៣ នៅត្រឹមឆ្នាំ២០១៩ ចំណែកអនុរដ្ឋលេខាធិការជាស្ត្រីបានកើនលឡើងពីចំនួន០២រូប ដល់៧០រូបក្នុងរយៈពេលដូចគ្នា។[15]

## 2. ការបង្កើតស្ថាប័នក្រោមចំណុះថ្មី

លទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ បានធ្វើឲ្យកម្ពុជាមានរដ្ឋសភាឯកបក្សដោយសារតំណាងរាស្ត្រទាំង ១២៥ រូបមកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់។ ដំណើរការរដ្ឋដែលអំណាចនីតិបញ្ញតិទាំងមូលលត្រូវផ្តល់ឲ្យគណបក្សកាន់អំណាច ដែលកំពុងដឹកនាំអំណាចនីតិប្រតិបត្តិត្រូវទទួលបានការរិះគន់ពីសហគមន៍អន្តរជាតិ និងនាំឲ្យបាត់បង់តុល្យភាពអំណាចរវាងស្ថាប័ននីតិបញ្ញតិ និងស្ថាប័ននីតិប្រតិបត្តិ។ នេះនឹងបង្កើតឲ្យមានការសង្ស័យអំពីតម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់អំណាចសាធារណៈ។

---

[13] Khmer Times: National Budget 2020 Approved, By Chea Vannak, November 27th , 2019; https://www.khmertimeskh.com/664298/national-budget-for-2020-approved/

[14] Khmer Times: Leading reforms in Cambodia's government, January 17th, 2020; https://www.khmertimeskh.com/680458/leading-reforms-in-government/

[15] Phnom Penh Post: Calls for more women in leadership positions, by Niem Chheng, 12 Mach 2020; ; https://www.phnompenhpost.com/national/calls-more-women-leadership-positions?

នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ ២០១៨ តាមរយៈការស្នើរបស់លោកនាយរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនីតិកាលទី៦ ព្រះមហាក្សត្រកម្ពុជា បានចេញព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។ ការបង្កើតស្ថាប័នថ្មីនេះមានគោលបំណងលើកស្ទួយរបបនយោបាយសេរីពហុបក្សនៅកម្ពុជា យោងតាមមាត្រា ១ នៃព្រះរាជក្រឹត្យ។ គណបក្សនយោបាយចំនួន ២០ ដែលបានចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ត្រូវបានបើកឲ្យមានឱកាសក្លាយជាប្រតិភូក្នុងឧត្តមក្រុមប្រឹក្សានេះ។ គណបក្សនយោបាយចំនួន ១៦ រួមទាំងគណបក្សប្រជាជនកម្ពុជា ក្នុងចំណោមគណបក្សនយោបាយចំនួន ២០ ដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឆ្នាំ ២០១៨ បានចូលរួម និងក្លាយជាប្រតិភូគណបក្សក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះ[16]។ ប្រតិភូដែលបានចូលរួមក្នុងឧត្តមក្រុមប្រឹក្សានេះត្រូវបានផ្តល់ឋានៈស្មើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ហើយមានភារកិច្ចចំបង ដូចជា ការផ្តួចផ្តើម គំនិត ឬផ្តល់យោបល់លើការរៀបចំគោលនយោបាយ ឬសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល និងការតាមដានការអនុវត្តច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យន្តការថ្មីនេះត្រូវបានគេវាយតម្លៃថា ជាយន្តការក្រៅសភាដែលទទួលធាតុចូលបន្ថែមពីគណបក្សនយោបាយ នៅពេលសភាមានតំណាងរាស្ត្រមកពីគណបក្សតែមួយ។

ថវិកាចំណាយរបស់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ជាថវិការបស់ជាតិដែលស្ថិតនៅក្រោមខ្ទង់ចំណាយរបស់ទីស្តីការគណរដ្ឋមន្ត្រី។ ម្យ៉ាងទៀត ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានលេខាធិការដ្ឋាននៅក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី ហើយប្រធានលេខាធិការដ្ឋាននោះត្រូវចាត់តាំងដោយនាយករដ្ឋមន្ត្រីផងដែរ។ ការបង្កើតយន្តការថ្មីដែលមិនមានស្វ័យភាពថវិកា និងមានលេខាធិការដ្ឋានក្រោមការគ្រប់គ្រងរបស់ប្រមុខស្ថាប័ននីតិប្រតិបត្តិ និងមិនផ្តល់ឯករាជ្យភាពពេញលេញដល់ប្រតិភូគណបក្សក្នុងការបំពេញភារកិច្ចរបស់ខ្លួនទេ។

ម្យ៉ាងទៀតការបង្កើតយន្តការថ្មីនេះ ជំនួសយន្តការសភា ដើម្បីទទួលយកធាតុចូលពីគណបក្សនយោបាយមិនមានអាសនៈក្នុងសភា មិនទទួលបាននីត្យានុកូលភាពជាតំណាងពីប្រជាពលរដ្ឋឡើយ ព្រោះប្រតិភូនៃគណបក្សនយោបាយទាំងនោះមិនទាន់ទទួលបានសេចក្តីទុកចិត្ត ពីប្រជាពលរដ្ឋតាមរយៈការបោះឆ្នោតឡើយ។

ទោះបីយ៉ាងណា ស្ថាប័នដែលបានស្នើដោយនាយករដ្ឋមន្ត្រី បង្កើតឡើងដោយព្រះរាជក្រឹត្យ ក្រោយការបោះឆ្នោតដែលទទួលបានការរិះគន់ថា ខ្វះការប្រកួតប្រជែង មិនមាននិរន្តភាពក្នុងដំណើរការរបស់ខ្លួនឡើយ ព្រោះវាបានពឹងផ្អែកលើការសម្រេចចិត្តរបស់នាយរដ្ឋមន្ត្រី។ លោកនាយរដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១៩ ថា «នឹងមិនមានទៀតឡើយ ឧត្តមក្រុមប្រឹក្សា

[16] Cambodia Daily: Cambodia Forms Supreme Council for Consultation and Recommendations, by Xinhua Net, September 7th, 2018; https://english.cambodiadaily.com/news/cambodia-forms-supreme-council-for-consultations-recommendations-140114/

ពិគ្រោះ និងផ្តល់យោបល់ នៅអាណត្តិក្រោយ។ លោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា បានពន្យល់បន្ថែមថា មូលហេតុចំបងមួយដែលជំរុញឲ្យប្រមុខរដ្ឋាភិបាលកម្ពុជាសម្រេចចិត្តបែបនេះគឺដោយសារតែកន្លងមក សមាជិកឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់មួយចំនួន ហាក់បានដើរហួសពីតួនាទីរបស់ខ្លួន។[17]

ការបង្កើតស្ថាប័នឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មិនស្ថិតនៅក្រោមបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញដូចចការជាការបង្កើតស្ថាប័នសភាជាតិឡើយ។ ម្យ៉ាងវិញទៀត បើទោះបីជាគោលបំណងក្នុងការបង្កើតស្ថាប័ននេះដើម្បីលើកស្ទួយ និងបង្កើនប្រសិទ្ធិភាពរបបនយោបាយសេរីពហុបក្សក្នុងដំណើរការរដ្ឋ តួនាទី និងការទទួលខុសត្រូវរបស់ឧត្តមក្រុមប្រឹក្សា និងសមាជិករបស់ខ្លួនមិនអាចទទួលបានឧត្តមភាពដូចរដ្ឋសភា និងសមាជិករដ្ឋសភាឡើយដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។

## VI. ថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ ២០១៩

រាជរដ្ឋាភិបាល នៃរដ្ឋសភានីតិកាលទី៦ ដើម្បីអនុវត្តគោលនយោបាយរបស់ខ្លួន ក្នុងឆ្នាំ១ បានគ្រោងចំណាយថវិកាថ្នាក់ជាតិ ប្រមាណ ៦.៤៤១ លានដុល្លារអាមេរិក។ ថវិកាចំណាយថ្នាក់ជាតិត្រូវចំណាយជាអាទិភាពខ្ពស់លើវិស័យសង្គមកិច្ច (២៨%) និងសេដ្ឋកិច្ច(២៥%) ។




បើប្រៀបធៀបនឹងខណៈពេលដូចគ្នានឹងនីតិកាលទី ៥ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពចំណាយខ្ពស់ លើវិស័យសេដ្ឋកិច្ចចាប់តាំងពីដើមនីតិកាលទី៦ ។ វិស័យសេដ្ឋកិច្ចទទួលបានថវិកាចំណាយប្រមាណតែ ៩% ក្នុងឆ្នាំទី ១ នៃនីតិកាលទី ៥ ប៉ុន្តែទទួលបានរហូតដល់ ២៥% ក្នុងឆ្នាំទី១ នៃនីតិកាលទី៦ នេះ ហើយដែលកើនឡើង ១% បន្ថែមទៀត បើធៀបនឹងឆ្នាំ ២០១៨ ។ ដោយឡែកខ្ទង់ចំណាយមិនទាន់បែងចែកបានធ្លាក់ចុះពី ៤៥% ក្នុងឆ្នាំ ២០១៤ ដល់ ១៩% ក្នុងឆ្នាំ ២០១៩ តែតួរលេខគឺបានកើនឡើង ១% ផងដែរ បើធៀបនឹងឆ្នាំ ២០១៨ ។

| វិស័យថវិកាចំ ណាយ | ជាលាន ដុល្លា (USD) និងការប្រែ ប្រួល | | | | | | | % នៃថវិកាសម្រាប់ ឆ្នាំនីមួយៗ និងការប្រែ ប្រួល | | | | | | | កំណើនថវិកាប្រ ចាំឆ្នាំ ជាលាន ដុល្លា(USD) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2014 | 2015 | 2016 | 2017 | ######## | ######## | ប្រែ ប្រួល | 2014 | #### | 2016 | 2017 | #### | 2019 | ប្រែ ប្រួល | **2014-15** | **2015-16** | **2016-17** | **2017-18** | **2018-19** |
| រដ្ឋបាលទូទៅ | 280.31 | 420.27 | 427.6 | 539.16 | 613.25 | 615.89 | | 8.2 | 11 | 9.79 | 10.7 | 10 | 9.56 | | 139.96 | 7.33 | 111.56 | 74.09 | 2.63 |
| ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | 468.17 | 610.27 | 711.05 | 860.38 | ######## | ######## | | 13.8 | 16 | 16.3 | 17.1 | 17 | ##### | | 142.1 | 100.78 | 149.33 | 141.04 | 104.87 |
| សង្គមកិច្ច | 791.47 | ######## | ######## | 1,439.02 | ######## | ######## | | 23.3 | 28 | 27.7 | 28.5 | 30 | ##### | | 254.19 | 164 | 229.36 | 314.50 | 58.83 |
| សេដ្ឋកិច្ច | 302.90 | ######## | ######## | 1,349.16 | ######## | ######## | | 8.9 | 29 | 29.5 | 26.7 | 24 | ##### | | 770.88 | 215.19 | 60.19 | 67.36 | 238.59 |
| ចំណាយមិនទាន់បែងចែក | ####### | 608.82 | 728.35 | 858.9 | ######## | ######## | | 45.8 | 16 | 16.7 | 17 | 18 | ##### | | -947.2 | 119.53 | 130.55 | 213.46 | 179.26 |
| ចំណាយសរុបរួម | ####### | ######## | ######## | 5,046.61 | ######## | ######## | | 100 | 100 | 100 | 100 | 100 | 100 | | 359.91 | 606.81 | 680.99 | 810.46 | 584.18 |

[17] http://www.rfi.fr/km/cambodia/hun-sen-with-new-law-in-gov-07-06-2019

នៅឆ្នាំ ២០១៩ រដ្ឋាភិបាលកម្ពុជា គ្រោងនឹងខ្ចីប្រាក់ពីដៃគូអភិវឌ្ឍន៍បរទេស ក្នុងកម្រិត ១.៤០០ លាន SDR ឬ ស្មើនឹងប្រមាណជិត ២ពាន់លានដុល្លាររបន្ថែមទៀត យោងតាមសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ។ គិតត្រឹមខែកញ្ញា ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានជំពាក់បំណុលសាធារណៈពីបរទេស មានទឹកប្រាក់សរុបប្រមាណ ៦.៨ ពាន់លានដុល្លារ រួមមាន ៤៨,៣ ភាគរយ បំណុលចិន ២៩ ភាគរយជាបំណុលទ្វេភាគីផ្សេងទៀត ៩,១ ភាគរយ ជាបំណុលចាស់ដែលកំពុងចរចាដោះស្រាយ ៥,២ ភាគរយ ជំពាក់កូរ៉េខាងត្បូង ៤,៤ភាគរយ ជំពាក់ជប៉ុន និង ៤ ភាគរយ ជាបំណុលទ្វេភាគី។[18]

## VII. គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៦

នៅក្នុងសម័យប្រជុំលើកទី ១ នៃរដ្ឋសភានីតិកាលទី៦ រាជរដ្ឋាភិបាលដែលត្រូវបានរដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត បានដាក់ចេញ ដាក់ជូនរដ្ឋសភានូវ កម្មវិធីនយោបាយរបស់ខ្លួន ដែលគូសបញ្ជាក់អំពីការធានា ៤ យ៉ាងរបស់រាជរដ្ឋាភិបាល សម្រាប់កម្ពុជានៅក្នុងនីតិកាលទី៦ នេះ៖

ទី១៖ **ការធានាការពារនូវសន្តិភាព ស្ថិរភាព សន្តិសុខ និងសុវត្ថិភាពភូមិ/ឃុំ ការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី។**

**ទី២៖ ការធានាបន្តជំរុញអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងគ្រប់វិស័យ** ដោយផ្តោតអាទិភាពទៅលើការកែទម្រង់អភិបាលកិច្ច ការពង្រឹងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ការបន្តផ្តោតអាទិភាពខ្ពស់ទៅលើការវិនិយោគលើមូលធនមនុស្ស ការលើកកម្ពស់ និងការបង្កើនការវិនិយោគ ទាំងការវិនិយោគសាធារណៈ ទាំងការវិនិយោគឯកជន និងការពង្រីកបរិយាបន្នហិរញ្ញវត្ថុ។

**ទី៣៖ ការធានាបន្តជំរុញលើកកម្ពស់ និងកែលម្អជីវភាពរបស់ប្រជាជន** តាមរយៈការផ្តល់ដល់ស្រទាប់យុវជននូវការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការជួយកសិករក្នុងការពង្រីកផលិតកម្ម និងការរកទីផ្សារលក់កសិផលដោយថ្លៃសមរម្យ ការបន្តដំឡើងប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ព្រមជាមួយនឹងការកែលម្អលក្ខខណ្ឌការងារ និងការការពារអាជីពជូនកម្មករនិយោជិត ការបន្តដំឡើងបៀវត្សរ៍ និងប្រាក់សោធននិវត្តជូនមន្ត្រីសាធារណៈគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងអតីតយុទ្ធជន ការពង្រីកបណ្តាញផ្គត់ផ្គង់ និងការបញ្ចុះថ្លៃអគ្គិសនី ក៏ដូចជាការខិតខំបញ្ចុះថ្លៃទឹកស្អាត ពិសេសនៅតំបន់ជនបទ ។ល។

**ទី៤៖ ការធានានូវសុវត្ថិភាពសង្គម និងលំនឹងក្នុងការរស់នៅរបស់ប្រជាជនទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជាទៅអនាគត** តាមរយៈការអភិវឌ្ឍ និងការពង្រឹងប្រព័ន្ធគាំពារសង្គម និងរបបសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព និងចីរភាព ដោយជួយគាំពារប្រជាជនគ្រប់រូប ពិសេសអ្នកក្រីក្រ និងក្រុមជនងាយរងគ្រោះ ពីហានិភ័យនានា ដោយមិនទុកប្រជាជនណាម្នាក់ ទទួលការរងគ្រោះដោយមិនមានការយកចិត្តទុកដាក់នោះឡើយ។

[18] http://www.rfi.fr/km/cambodia/debt-khmer-gov-26-10-2018

នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ នៃនិតិកាលទី៦ កាលពីថ្ងៃទី៦ កញ្ញា ២០១៨ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានដាក់ចេញនូវការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលមានមូលដ្ឋានពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ និងជាមូលដ្ឋានក្នុងការរៀបចំ និងបង្កើតផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ **គឺដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព៖ កសាងមូលដ្ឋានឆ្ពោះទៅចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០**[19]។

គោលនយោបាយ និងកិច្ចការងារជាអាទិភាពដែលរដ្ឋាភិបាលបានចែង ឬសន្យាតាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ត្រូវបានកំណត់ថាមាន ៦ ផ្នែកធំៗរួមមាន៖

- ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច
- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល
- ការអភិវឌ្ឍធនធានមនុស្ស
- ការធ្វើពិពិធកម្មសេដ្ឋកិច្ច
- ការអភិវឌ្ឍវិស័យឯកជន និងការងារ
- ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន

ដែលនៅក្នុងនោះ រដ្ឋាភិបាលបានកំណត់ការងារអាទិភាពរបស់ខ្លួន ដែលត្រូវយកចិត្តទុកដាក់អនុវត្តក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ។ គោលនយោបាយដែលបានបែងចែកជា ៦ ផ្នែកធំៗ និងចំណុចការងារអាទិភាពរបស់រដ្ឋាភិបាល ស្របគ្នាទាំងស្រុងនៅទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ដែលសភានីតិកាលទី៦ បានអនុម័ត កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០១៩។

អ្វីដែលគួរឲ្យកត់សម្គាល់ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ រដ្ឋាភិបាលបានសន្យាការអនុវត្តគោលនយោបាយទាំងនោះ ដោយមិនបានកំណត់សូចនាករច្បាស់លាស់នេះទេ ពោលគឺរដ្ឋាភិបាលបានសន្យាដោយសរសេរថា «បន្តអនុវត្ត......» «ពង្រឹង......» «យកចិត្តទុកដាក់លើ.......» ជាដើម។

ចំណែកនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) រដ្ឋាភិបាល បានសសេរអំពីសូចនាករនៃការអនុវត្តគោលនយោបាយ និងការងារអាទិភាពមួយចំនួនផងដែរ ប៉ុន្តែសូចនាករទាំងនោះមិនទាន់មានភាពជាក់លាក់នៅឡើយ ដោយមិនមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់នោះទេ។

ភាពមិនច្បាស់លាស់នៃដំណើរនៃរាជរដ្ឋាភិបាល ដែលកើតចេញពីវិបត្តិនយោបាយបន្ទាប់ពីការ

---

[19] See details in the government 4th rectangular Strategy at: Royal Government of Cambodia: : "Rectangular Strategy", for Growth, Employment, Equity and Efficiency: Building the Foundation Towards Realizing the Cambodia vision 2050; Phase IV, of the Royal government of Cambodia of the 6th Legislature of the National Assembly, Phnom Penh, September 2018. http://iric.gov.kh/rectangular-strategy-phase-iv-in-khmer/

រំលាយគណបក្សនាំងនៅកម្ពុជាសង្គ្រោះជាតិ និងការចាប់ខ្លួនប្រធានគណបក្សនេះ ដែលធ្វើឲ្យមានការរិះគន់ពីអន្តរជាតិអាចត្រូវបានគេយល់ថា ជាភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាល ក្នុងការកំណត់សូចនាករច្បាស់លាស់ក្នុងការបំពេញគោលនយោបាយរបស់ខ្លួន។ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលកើតចេញពីសេចក្ដីសម្រេចចិត្តរបស់សហភាពអឺរ៉ុប គឺជាកត្តាចម្បងមួយ ដែលដាក់ដែនកំណត់ដល់ឆន្ទៈមោះមុតរបស់រាជរដ្ឋាភិបាលក្នុងការតាក់តែងគោលនយោបាយដែលមានសូចនាការច្បាស់លាស់។ ស្របពេលជាមួយគ្នានេះដែរ ការអនុវត្តមួយជំហានម្តងៗ ដែលត្រូវបានគេហៅថា «ជំហានគីង្កក់» ត្រូវបានរាជរដ្ឋាភិបាលបន្តប្រើប្រាស់ជារបៀបដើម្បីការអភិវឌ្ឍក្នុងអំឡុងពេលមិនជាក់លាក់នេះ។ ដូចនេះ ការប្រើប្រាស់ «បន្តពង្រីក និងពង្រឹងបន្ថែម» និង « បន្តលើកស្ទួយ» នៅក្នុងការតាក់តែងគោលនយោបាយរបស់ខ្លួនត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់បង្ហាញអំពីការលទ្ធផលនៃអនុវត្ត/បំពេញរបស់រដ្ឋាភិបាល ដែលមិនអាចបានកំណត់បានប្រកបដោយប្រសិទ្ធភាព។

## VIII. ការអនុវត្តគោលនយោបាយៈ លទ្ធផល និងបញ្ហាប្រឈម

ខាងក្រោមនេះជាការឆ្លុះបញ្ចាំងទៅលើលទ្ធផល នៃការអនុវត្តជាក់ស្ដែងសម្រាប់គោលនយោបាយនីមួយៗ ដោយផ្អែកទៅលើសូចនាករ ឬលទ្ធផលនានាដែលបានរំពឹងទុកនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ នៃអាណត្តិទី៦ របស់រាជរដ្ឋាភិបាល។ សូមបញ្ជាក់ផងដែរថា នៅក្នុងដំណើរការនៃការចងក្រងរបាយកាណ៍នេះយើងមានការប្រឈម និងការខ្វះនូវព័ត៌មានមួយចំនួនដែលមិនមានក្នុងឯកសារយោង។ បញ្ហានេះនឹងអាចនាំឲ្យមានភាពខ្វះខាត មួយចំនួនទាក់ទិនទៅនឹងការបង្ហាញនូវលទ្ធផល ដែលបានកើតឡើងដោយផ្អែកទៅតាមសូចនាករនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ ការអធិប្បាយខាងក្រោមនេះត្រូវបានចែកចេញទៅតាមទម្រង់ នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ដែលបានលើកយកមកពិភាក្សានៅក្នុងរបាយការណ៍នេះ ដែលមានជាអាទិ៍៖ 1) ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច 2) បរិយាស្ថានអនុវត្តយុទ្ធសាស្ត្រទាំងមូល 3) ការអភិវឌ្ឍធនធានមនុស្ស 4) ការធ្វើពិពិធកម្មសេដ្ឋកិច្ច 5) ការអភិវឌ្ឍវិស័យឯកជន និងការងារ 6) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។

### 1. ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ច

នៅក្នុងការកំណែទម្រង់អភិបាលកិច្ចនេះផែនការយុទ្ធសាស្ត្ររាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- ការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន
- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ
- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ
- ការពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យឯកជន

### 1.1. ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន

ក្រសួង និងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ត្រូវបានពង្រឹងទៅលើភាពជាម្ចាស់ ការទទួលខុសត្រូវ និងគណនេយ្យភាព សាមគ្គីភាព និងត្រូវបានលើកកម្ពស់នូវសមត្ថភាព និងគុណវុឌ្ឍិរបស់មន្ត្រីរាជការផងដែរ។ រាជរដ្ឋាភិបាលរៀបចំក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័នការងារ ក្រមខណ្ឌអភិវឌ្ឍមូលធនមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីរាជការសាធារណៈ។ ក្រោយការបោះឆ្នោតជាតិឆ្នាំ ២០១៨ រដ្ឋាភិបាលបន្តជំរុញកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដើម្បីផ្តល់អំណាចកាន់តែច្រើនដល់អាជ្ញាធរមូលដ្ឋាន។ ជាលទ្ធផល គិតត្រឹមខែធ្នូ ឆ្នាំ ២០១៩ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានប្រកាសថា រដ្ឋាភិបាល បានត្រៀមថវិកាជាង ៣,៥ ពាន់ពាន់លានរៀល (ជិត ៩០០ លានដុល្លារ) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនសម្រាប់ឆ្នាំក្រោយ។[20]

សម្រាប់កងកម្លាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលគ្រោងត្រូវបានបន្តកែទម្រង់លើចំណុចមួយចំនួនដូចជា ការដឹកនាំ និងការគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស និងបង្កើនសមត្ថភាពរួមទាំងផ្នែកបច្ចេកវិទ្យា ការលើកទឹកចិត្តដល់គ្រួសារកងទ័ពឲ្យរស់នៅតាមបណ្តោយព្រំដែនដើម្បីថែរក្សាបាននូវសន្តិភាព និងសុវត្ថិភាព ការបន្តចូលរួមសកម្មភាពរបស់អង្គការសហប្រជាជាតិ និងការចូលរួមសកម្មភាពគាំទ្រការអភិវឌ្ឍ និងអន្តរាគមន៍ក្នុងពេលមានគ្រោះធម្មជាតិ ផ្សេងៗ នៅឆ្នាំ ២០១៩ វិស័យកងកម្លាំងប្រដាប់អាវុធកម្ពុជា មានថវិកាសរុប ៦០៤ លានដុល្លារអាមេរិក។ សមយុទ្ធយោធានៃប្រតិបត្តិការសង្គ្រោះបន្ទាន់ ការកសាងសន្តិភាព និងការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ត្រូវបានធ្វើឡើង ដើម្បីធានាថាកងទ័ពបានត្រៀមខ្លួនដើម្បីបំពេញភារកិច្ចរបស់ពួកគេនៅពេលចាំបាច់។ សមយុទ្ធកងទ័ពទាំងនេះ ទោះយ៉ាងណាក៏ត្រូវទទួលរងការរិះគន់ពីសម្ព័ន្ធមិត្តលោកខាងលិចថា កម្ពុជាកំពុងរអិលចូលទៅជារណបរបស់ប្រទេសចិននៅក្នុងតំបន់។ ការចោទប្រកាន់នេះបានកើតឡើង បន្ទាប់ពីមានការសម្រេចចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការផ្អាកសមយុទ្ធយោធារួមគ្នាជាមួយសហរដ្ឋអាមេរិក និងការផ្អាកជំនួយមនុស្សធម៌ដទៃទៀត ដែលធ្វើឡើងដោយកងទ័ពសហរដ្ឋអាមេរិកនៅកម្ពុជា។ ដោយសារភាពតានតឹងនយោបាយផ្ទៃក្នុង និងការបញ្ចេញមតិរបស់រដ្ឋាភិបាលក្នុងការខិតទៅជិតប្រទេសចិនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមបញ្ហាភូមិសាស្ត្រនយោបាយ។ ចិនបានកសាងកំពង់ផែសមុទ្រ និងទីតាំងចុះចតយាន្តអាកាសនៅខេត្តកោះកុង ដែលត្រូវបានអ្នក

20 Phnom Penh Post: Local administrations allocated $900M, By Mech Dara, date: 8th December 2019; https://www.phnompenhpost.com/national/local-administrations-allocated-900m?

ជំនាញយោធាមួយចំនួនអះអាងថា បម្រើដល់គោលបំណងយោធាចិនជាជាងសម្រាប់សកម្មភាពពាណិជ្ជកម្ម និងសកម្មភាពស៊ីវិល។[21]

ក្នុងក្របខណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គ.ជ.អ.ប ផ្តោតជាសំខាន់ទៅលើកិច្ចការស្នូលជាអាទិភាពចំនួន ៣ រួមមាន ទី១. ការបង្កើនមូលនិធិឃុំ សង្កាត់ ទី២. ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងទី៣. ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រុង-ស្រុក។ វឌ្ឍនភាពនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងឆ្នាំ ២០១៩ មានសមិទ្ធផលសំខាន់រួមមាន ការកែសម្រួលមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានីខេត្ត និងការបង្កើនថវិកា សម្រាប់ផ្នែកអភិវឌ្ឍន៍ដល់រដ្ឋបាលឃុំ-សង្កាត់។

ទន្ទឹមនឹងនេះ កម្មវិធីវិមជ្ឈការត្រូវបានរារាំងដោយសារការផ្តល់សេវាមិនសូវបានឆ្លើយតបឲ្យត្រូវទៅតាមតម្រូវការ របស់ប្រជាពលរដ្ឋ ខ្វះការសម្របសម្រួលសមស្របក្នុងការផ្តល់សេវាកម្ម និងសមត្ថភាពរបស់មន្ត្រីនៅមានកម្រិត។ វាគួរតែផ្តោតលើការកែទម្រង់មន្ត្រីផ្តល់សេវាបន្ថែមលើអ្វីដែលមានស្រាប់ដើម្បីធ្វើកំណែទម្រង់វិស័យសាធារណៈ។[22]

រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ ២០១៩ ស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋានចាប់ពីឆ្នាំ ២០២០ តទៅ។ ក្នុងនោះរដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនប្រមាណ ១២២.០០០ ដុល្លារអាមេរិក ដែលក្នុងនោះថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋានមានចំនួនជាមធ្យមប្រមាណជាង ៧០.០០០ ដុល្លារអាមេរិកក្នុងឆ្នាំ ២០២០ (កើនឡើងទ្វេដងធៀបនឹងឆ្នាំ ២០១៩) ហើយថវិកានេះនឹងកើនឡើងជាបន្តបន្ទាប់រៀងរាល់ឆ្នាំ។ តាមការប៉ាន់ប្រមាណរហូតដល់ឆ្នាំ ២០២៣ រដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនប្រមាណ ១៩៣.០០០ ដុល្លារអាមេរិក ដែលក្នុងនោះថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋានមានចំនួនជាមធ្យមប្រមាណជាង ១៣២.០០០ ដុល្លារអាមេរិក។

ទោះបីយ៉ាងនេះក្តី រហូតមកដល់ដំណាក់កាលនេះ ការបែងចែកថវិកានេះនៅតែមិនទាន់ច្បាស់អំពីរបៀប ប្រើប្រាស់ថវិកាទាំងនោះនៅថ្នាក់មូលដ្ឋាន។ ទន្ទឹមនឹងនេះការបង្កើនថវិកាដល់ឃុំ/សង្កាត់ បានធ្វើឱ្យមានការព្រួយបារម្ភបន្ថែមទៀតអំពីសមត្ថភាពរបស់ឃុំ/សង្កាត់នៅមូលដ្ឋានក្នុងការគ្រប់គ្រងថវិកា ប្រកបដោយតម្លាភាពនិងមានគណនីភាពគ្រប់គ្រាន់។ គេនៅតែមានការព្រួយបារម្ភអំពីការពង្រឹងការគាំទ្រផ្នែកបច្ចេកទេស និងសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាឱ្យបានថា រដ្ឋបាលឃុំ សង្កាត់នីមួយៗអាច

[21] Kyodo News: Chinese Project in Cambodia raises alarms of Military build up, August 12th 2019; https://english.kyodonews.net/news/2019/08/2a1e00ec3d97-focus-chinese-project-in-cambodia-raises-alarms-of-military-build-up.html

[22] World Bank Report: Cambodia’s Cross –Cutting Reforms: Public Financial Management, Decentralization, and Public Administration Reform: Achievements, Coordination, Challenges and Next Steps, 2018, International Bank for Reconstruction and Development,

គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិការបស់ខ្លួនស្របតាមគោលការណ៍ និងនីតិវិធីជាធរមានប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗ និងដោយមានការចូលរួមតាមដានត្រួតពិនិត្យពីប្រជាពលរដ្ឋដោយផ្ទាល់ផងដែរ។[23] អវត្តមាននៃក្រុមប្រឹក្សាឃុំសង្កាត់ពី គណបក្សប្រឆាំងដែលត្រូវបានគេរំលាយ ជាការបាត់បង់នូវយន្តការ ដ៏មានសក្តានុពលមួយ ដើម្បីធ្វើការត្រួតពិនិត្យអំពីរបៀបដែលថវិកាត្រូវបានចំណាយអោយបានត្រឹមត្រូវ។ បញ្ហានេះអាចនឹងមានកាន់តែធ្ងន់ធ្ងរទៅទៀត ដោយសារតែក្រុមប្រឹក្សាឃុំមូលដ្ឋានខ្លះបានយកតួនាទីខ្លួនទៅបំរើសកម្មភាព និងផលប្រយោជន៍គណបក្សជាជាងផលប្រយោជន៍ជាតិ។

ផ្អែកលើឧបសគ្គខាងលើ រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែពុំទាន់មានតួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការផ្តល់សេវាចាំបាច់ជាមូលដ្ឋាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនៅឡើយ។ បើទោះបីជា គ.ជ.អ.ប. តាមរយៈលេខាធិការដ្ឋាន បានខិតខំសម្របសម្រួល និងផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះដល់ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីជំរុញដល់ការផ្ទេរមុខងារសមស្របនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏កិច្ចការនេះនៅតែមានភាពយឺតយ៉ាវ និងសម្រេចបាននូវសមិទ្ធផលតិចតួចនៅឡើយ។ នេះបើតាមការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង នៅក្នុងកិច្ចប្រជុំលើកទី១៧ របស់ គ.ជ.អ.ប កាលពីព្រឹកថ្ងៃពុធ ទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៩។[24] ទន្ទឹមនឹងនេះដែរ បើទោះបីរដ្ឋាភិបាលបានណែនាំម្តងហើយម្តងទៀត ដល់អាជ្ញាធរថ្នាក់ក្រោមជាតិឱ្យធ្វើការដោយឯករាជ្យពីនយោបាយ គេនៅតែសង្កេតឃើញថាក្រុមប្រឹក្សាឃុំ/សង្កាត់នៅមូលដ្ឋានខ្លះ នៅតែបន្តធ្វើសកម្មភាពដោយស្តាប់តែការណែនាំពីថ្នាក់លើនៅក្នុងរចនាសម្ព័ន្ធនយោបាយរបស់ពួកគេ ជាជាងធ្វើសកម្មភាពជាក់ស្តែងក្នុងនាមជា រដ្ឋាភិបាលនៅមូលដ្ឋាន។

លើសពីនេះ កម្មវិធីវិមជ្ឈការរបស់រដ្ឋាភិបាលតាមរយៈអភិបាលកិច្ចបែបប្រជាធិបតេយ្យ បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីការបាត់បងក្រុមប្រឹក្សាឃុំ/សង្កាត់នៅមូលដ្ឋានដែលជាប់ឆ្នោតចេញពី គណបក្សសង្គ្រោះជាតិ ហើយជំនួសមកវិញដោយក្រុមប្រឹក្សាឃុំ/សង្កាត់មកពីគណបក្សនយោបាយដែលមិនបានជាប់ឆ្នោត។ ការដឹកនាំរបស់គណបក្សនយោបាយតែមួយ មិនមានតុល្យភាពត្រួតពិនិត្យទេ ហើយប្រព័ន្ធវិមជ្ឈការទាំងមូលត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច។ ដើម្បីឱ្យការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែទទួលមានប្រសិទ្ធភាព អនុក្រឹត្យចំនួន ៤ ត្រូវបានសម្រេចដាក់ចេញ ហើយឲ្យអនុវត្តចាប់ពីឆ្នាំ ២០២០ នេះតទៅ។

---

[23] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បើកកិច្ចប្រជុំលើកទី១៧, ដោយ៖ នាយកដ្ឋានព័ត៌មានវិទ្យា, November 20, 2019, https://www.interior.gov.kh/news/detail/1262

[24] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បើកកិច្ចប្រជុំលើកទី១៧ ដោយ នាយកដ្ឋានព័ត៌មានវិទ្យា November 20, 2019, https://www.interior.gov.kh/news/detail/1262

ផ្នែកមួយនៃការកសាងសមត្ថភាពនៃការគ្រប់គ្រងថ្នាក់ក្រោមជាតិ គឺបង្កើតឲ្យមានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងបានធ្វើប្រតិភូកម្មមុខងារផ្តល់សេវារដ្ឋបាលចំនួន ២១១ ប្រភេទ សេវាលើវិស័យជំនាញចំនួន ១០ គិតមកដល់បំណាច់ឆ្នាំ ២០១៩ នេះ។ មកដល់ពេលបច្ចុប្បន្ន ការិយាល័យច្រកចេញចូលតែមួយ ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌមានចំនួន១១៥ ក្នុងចំណោមក្រុង ស្រុក ខណ្ឌ ចំនួន ២០៣ នៃរាជធានី ខេត្តទាំង ២៥ ដែលក្នុងនោះរួមមានរដ្ឋបាលក្រុង ចំនួន ២៧ រដ្ឋបាលស្រុកចំនួន ៧៤ និងរដ្ឋបាលខណ្ឌ ចំនួន ១៤ ស្មើនឹង ៥៧% នៃចំនួនរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស[25]។

### 1.2. ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

ក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិ «មិនហ៊ាន មិនអាច និងមិនចង់» ប្រព្រឹត្តអំពើពុករលួយ តាមរយៈសកម្មភាពអប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាប។ រាជរដ្ឋាភិបាលបន្តពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានអំពីសេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្តិ និងឯកសារគោលនយោបាយជាតិ និងយន្តការអធិការកិច្ច និងសវនកម្ម និងជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រលប់នៃការផ្តល់សេវាក្នុងវិស័យសាធារណៈ។ បន្ថែមលើសពីនេះទៀត រាជរដ្ឋាភិបាល នឹងជំរុញឲ្យមានការចូលរួមពីប្រជាជនក្នុងដំណើរការនៃការអភិវឌ្ឍនានា និងការអនុវត្តក្រមសីលធម៌ការងារ និងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍ក្នុងមុខងារសាធារណៈ។

ក្នុងគោលបំណងបង្ហាញពីកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រឆាំងអំពើពុករលួយ នៅដើមឆ្នាំ ២០១៩ មេបញ្ជាការកងរាជអាវុធហត្ថខេត្ត រតនគិរី និងស្នងការរងខេត្ត កណ្តាល ត្រូវបានសាធារណជនដាក់ការសង្ស័យ ថាអាចជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ ក្រោយពេលបង្ហោះវីដេអូលើបណ្តាញសង្គម បង្ហាញអំពីប្រើប្រាស់ទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់របស់ខ្លួន។ អង្គភាពប្រឆាំងអំពើពុករលួយ (ACU) បានបើកការស៊ើបអង្កេតលើករណីទាំងពីរខាងលើ។ លទ្ធផលនៃការស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ បានឲ្យដឹងថា ករណីខាងលើមិនមែនជាករណីបទល្មើសពុករលួយទេ គឺការសំញ៉ែងទ្រព្យសម្បត្តិរបស់ខ្លួន ប៉ុន្តែមេបញ្ជាការកងរាជអាវុធហត្ថខេត្ត រតនគិរី ត្រូវបានព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យលុបឈ្មោះចេញពីក្របខណ្ឌកងយោធពលខេមរភូមិន្ទផងដែរ។[26]

សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ គឺជាសូចនាករកម្រិតសកលឈានមុខ ទាក់ទងនឹងអំពើពុករលួយនៅក្នុងវិស័យសាធារណៈ ដោយបង្ហាញពីកម្រិតនៃអំពើពុក

---

[25] រដ្ឋបាលខេត្តកំពត រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០ នៃការអនុវត្តការងារច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ រដ្ឋបាលខេត្តកំពត https://www.interior.gov.kh/report/detail/4379 , February 24, 2020

[26] មេPMខេត្តរតនៈគិរីត្រូវបានព្រះមហាក្សត្រចេញព្រះរាជក្រឹត្យលុបឈ្មោះចេញពីក្របខណ្ឌកងខេមរភូមិន្ទថ្ងៃសៅរ៍ ទី១ ខែកុម្ភៈ ឆ្នាំ 2019 https://postnews.com.kh/local/412593

រលួយប្រចាំឆ្នាំរបស់ប្រទេសជាច្រើនជុំវិញពិភពលោក។ យោងតាមលទ្ធផលសន្ទស្សន៍ក្នុងឆ្នាំ ២០១៩ បានបង្ហាញថា ប្រទេសកម្ពុជាទទួលបាន ២០ពិន្ទុ លើពិន្ទុអតិបរមា ១០០ គឺជាពិន្ទុដដែលធៀបនឹងឆ្នាំ ២០១៨ ។ កម្ពុជាឈរនៅចំណាត់ថ្នាក់ទី ១៦២ ក្នុងចំណោមប្រទេស និងដែនដីសរុបចំនួន ១៨០ ដែលត្រូវបានដាក់បញ្ចូលក្នុងការវាយតម្លៃ។ នៅកម្រិតតំបន់ ប្រទេសកម្ពុជាបន្តស្ថិតក្នុងចំណោមប្រទេសមានពិន្ទុទាបជាងគេទី ៣ នៅតំបន់អាស៊ីប៉ាស៊ីហ្វិច នៅលើតែប្រទេសអាហ្វហ្គានីស្ថាន និងកូរ៉េខាងជើងតែប៉ុណ្ណោះ ហើយក៏ជាប្រទេសមានពិន្ទុទាបជាងគេបំផុតក្នុងតំបន់អាស៊ានផងដែរ[27]។

លទ្ធផលនេះបានបញ្ជាក់បន្ថែមថា កម្ពុជាសម្រេចបាននូវលទ្ធផលជាក់លាក់មួយចំនួនហើយ ដូចជាភាពប្រសើរឡើងនៃការកៀរគរធនធាន និងកំណែលម្អការផ្តល់សេវាសាធារណៈ។ បើទោះបីមានការប្រសើរឡើង រដ្ឋាភិបាលនៅតែមិនទាន់ទទួលបានជោគជ័យក្នុងការផ្លាស់ប្តូរទស្សនៈយល់ឃើញជារួមរបស់អ្នកជំនាញនិងធុរជននោះនៅឡើយ ជាពិសេសជុំវិញបញ្ហាអំពើពុករលួយទ្រង់ទ្រាយធំ និងអំពើពុករលួយផ្នែកនយោបាយ។ បន្ថែមពីនេះទៀតនាពេលថ្មីៗនេះ បញ្ហាបទល្មើសរូបីយបណ្ណ (លាងលុយ) កំពុងកើតមាននៅកម្ពុជា ហើយត្រូវបានគេវាតម្លៃថាមានទំនាក់ទំនងនឹងអំពើពុករលួយផងដែរ។ ប្រទេសកម្ពុជានៅតែទទួលបានពិន្ទុទាបខ្លាំង ក្នុងសន្ទស្សន៍ស្តីពីនីតិរដ្ឋរបស់គម្រោងយុត្តិធម៌ពិភពលោក (WJP) និងគម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ (VDEM) ដែលវាស់វែងពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនីមួយៗក្នុងការកែលម្អនីតិរដ្ឋ និងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យ។

ចំណែកឯអ្នកឃ្លាំមើល និងតាមដានបញ្ហាសង្គមបានលើកឡើងថា បញ្ហាប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា គឺបានអនុវត្តមិនបានទូលំទូលាយ និងពេញលេញនៅឡើយ ពោលពឹងផ្អែកលើពាក្យបណ្តឹង និងអនុវត្តបានតែលើមន្ត្រីថ្នាក់ក្រោមស្របពេល ដែលទំហំទ្រព្យសម្បត្តិរបស់មន្ត្រីនយោបាយធំៗតែងតែត្រូវបានទទួលរងការរិះគន់ពីសាធារណជនមិនត្រូវបានគេយកមកធ្វើការស៊ើបអង្កេត។ បើទោះបីជាមានសកម្មភាពប្រឆាំង និងបង្ក្រាបបទល្មើសពុករលួយរបស់អង្គភាពប្រឆាំងអំពើពុករលួយ(ACU) នាពេលកន្លងមកនេះ សកម្មភាពទាំងនោះនៅមិនទាន់ឆ្លើយតបទៅនឹងទំហំនៃអំពើពុករលួយ ដែលប្រព្រឹត្តឡើងដោយមន្ត្រីរាជការទាំងស៊ីវិល និងយោធានៅឡើយទេ[28]។

ផ្ទុយពីការលើកឡើងខាងលើ អ្នកនាំពាក្យរាជរដ្ឋាភិបាលយល់ថា ស្ថានភាពនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជាកាន់តែមានភាពល្អប្រសើរឡើង ប៉ុន្តែលោកក៏ទទួលស្គាល់ផងដែរថា វាមិនទាន់អស់នៅឡើយទេ។ រដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការបោសសម្អាតអំពើពុករលួយនេះដោយមានទាំងការ

---

[27] សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ២០១៩, 23 JAN 2020 https://www.ticambodia.org/cpi2019/

[28] Also see in: The Diplomat: The Truth About Cambodia's So-Called Corruption Crackdown, by David Hutt, August 28th 2019; https://thediplomat.com/2019/08/the-truth-about-cambodias-so-called-corruption-crackdown/

បង្ក្រាប និងការបណ្តុះនូវវប្បធម៌សុចរិត និងតម្លាភាព។ ការខ្វះខាតនៃការពង្រឹងអនុវត្តច្បាប់ និងភាពទន់ខ្សោយនៅក្នុងប្រព័ន្ធយុត្តិធម៌ បក្សពួកនិយម ក៏ដូចជាកង្វះខាតនៃគណនេយ្យភាពនៅក្នុងប្រព័ន្ធនយោបាយ គឺជាបញ្ហាសំខាន់ ដែលរួមចំណែកដល់ការអសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់អំពើពុករលួយនេះ។

### 1.3. ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ

ការបន្តដំឡើងបៀវត្ស និងប្រាក់សោធនិវត្ត ជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជាផ្នែកមួយនៃគោលនយោបាយពង្រឹងប្រសិទ្ធភាពអនុវត្តការងារផងដែរ។ ហើយការធ្វើប្រតិភូកម្មតាមរយៈយន្តការវិមជ្ឈការ និងសហវិជ្ឈការចំពោះស្ថាប័នរបស់ជាតិគ្រប់កម្រិតទៅលើអំណាចមុខងារ ធនធាន ដើម្បីទទួលបានស្វ័យភាពសមស្របក៏ត្រូវបានគេធ្វើឡើងដែរ។ រដ្ឋាភិបាលនឹងដាក់អនុវត្តនូវប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានសូចនាករច្បាស់លាស់ក្នុងការងារគ្រប់គ្រងស្ថាប័នសាធារណៈ។ ទោះយ៉ាងណា ការប៉ុនប៉ងខាងលើត្រូវបានគេអះអាងថា មានចំណុចខ្សោយច្រើននៅឡើយ ហើយមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយទេ។ ពោលគឺត្រូវគេសង្កេតឃើញថាប្រព័ន្ធរដ្ឋាភិបាលបច្ចុប្បន្ននៅតែត្រូវបានបន្តត្រួតត្រាដោយអ្នកនយោបាយ ហើយប្រព័ន្ធរបស់រដ្ឋក៏ត្រូវបានគេប្រើធ្វើជាឧបករណ៍នយោបាយយ៉ាងខ្លាំងក្លាផងដែរ។

រាជរដ្ឋាភិបាលលើកកម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធិភាពការងាររបស់មន្ត្រីអនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធារណជន និងប្រយុទ្ធប្រឆាំងនិងអំពើអយុត្តិធម៌នៅក្នុងសង្គម តាមរយៈការពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ការពង្រឹងនូវភាពស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់ ការពង្រឹងយន្តការវិន័យការងារ ការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌ ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និងការពង្រឹង និងកែលម្អយន្តការដោះស្រាយវិវាទជាដើម។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេស ក្រុមមេធាវីរបស់រដ្ឋាភិបាលត្រូវបានបង្កើតឡើង និងស្ថិតនៅក្រោមការណែនាំផ្ទាល់របស់នាយករដ្ឋមន្ត្រីដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ជនក្រីក្រ។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវបានគេរិះគន់ ថាជាការជ្រៀតជ្រែកចូលរបស់អ្នកនយោបាយទៅក្នុងប្រព័ន្ធយុត្តិធម៌បច្ចុប្បន្នពីព្រោះមេធាវីទាំងនេះអាចប្រើប្រាស់ទំនាក់ទំនងរបស់ពួកគេជាមួយនាយករដ្ឋមន្ត្រីដើម្បីអោយមានអំណាចនិងឥទ្ធិពលលើសេចក្តីសម្រេចរបស់តុលាការ។

លើសពីនេះទៀត ដំណើរការនៃប្រព័ន្ធយុត្តិធម៌កម្ពុជានាពេលបច្ចុប្បន្ន នៅតែបង្កក្តីកង្វល់ដ៏ធំធេងនៅឡើយ។ កង្វះឯករាជ្យភាពរបស់តុលាការដោយសារតែឥទ្ធិពល នៃប្រព័ន្ធនយោបាយ ត្រូវបានគេអះអាងថាជាបញ្ហាគន្លឹះដែលធ្វើឱ្យអន្តរាយដល់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។ អំពើពុករលួយ និងកង្វះការទុកចិត្តពីប្រជាជនក៏ត្រូវចាក់ឫសក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាផងដែរ។ លោក ណាន់ សេរីរ័ត្ន អ្នកសរសេរប្លុកនយោបាយ

និងអ្នកសកម្មក្នុងការជជែកបញ្ហានយោបាយបានលើកឡើងថា «ប្រជាពលរដ្ឋមិនជឿជាក់លើការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាទេ»។[29]

### 1.4. ការពង្រឹងអភិបាលកិច្ចល្អវិស័យឯកជន

ទាក់ទងនិងវិស័យឯកជន រាជរដ្ឋាភិបាលនឹងសិក្សា និងរៀបចំក្របខណ្ឌគោលនយោបាយលើកកម្ពស់អភិបាល និងការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន(Corporate´s social and environmental responsibility) ដើម្បីចូលរួមដោះស្រាយបញ្ហាសង្គម បរិស្ថាន និងតម្លៃវប្បធម៌។ ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពអតិថិជន រាជរដ្ឋាភិបាលនឹងជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការការពារអតិថិជន (Consumer Protection Law)។ នៅក្នុងវិស័យឯកជនក្នុងប្រព័ន្ធជាផ្លូវការ ដូចជានៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ការខិតខំប្រឹងប្រែងក្នុងការកែលម្អមួយចំនួនត្រូវបានបង្កើតឡើង ហើយចំណុចកែលម្អមួយចំនួនត្រូវបានដាក់ចូលនៅក្នុងច្បាប់ស្តីពីការងារ ដើម្បីធានាថាសិទ្ធិការងារត្រូវបានគោរព និងកម្មករមានសិទ្ធិចូលរួមវិភាគទានក្នុងមូលនិធិសន្តិសុខសង្គម ដែលពួកគេអ្នកទទួលបានត្រលប់មកវិញ នូវការធានារ៉ាប់រងផ្នែកសុខភាពរបស់ពួកគេ។

ទោះយ៉ាងណា សិទ្ធិកម្មករនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងបានប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចជា៖ ប្រាក់ខែកម្មករនៅតែទាប ការធ្វើការលើសម៉ោងដោយគ្មានប្រាក់ឈ្នួល ដែលត្រូវបានគេសង្កេតឃើញកើតមានឡើងបន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០១៨ ។ បញ្ហានេះបន្តកើតឡើងកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសាររដ្ឋាភិបាលប៉ុនប៉ងធ្វើឱ្យតួនាទីរបស់សហជីពចុះខ្សោយតាមរយៈការបែងចែក និងគ្រប់គ្រងរវាងសហជីពកម្មករឯករាជ្យ និងសហជីពដែលគាំទ្រដោយរដ្ឋាភិបាល។[30] បណ្តឹងនៅតុលាការដែលចោទប្រកាន់មេដឹកនាំសហជីពនៅតែបន្តកើតមាន ជាពិសេសបណ្តឹងប្រឆាំងមេដឹកនាំសហជីពឯករាជ្យសំខាន់ៗមួយចំនួន។

សម្រាប់ប្រាក់ឈ្នួលអប្បបរមាឲ្យកម្មករ ឆ្នាំ ២០១៩ ក្រសួងការងារកំណត់ ១៨២ ដុល្លារ និងត្រូវបើកជា ពីរដងក្នុងមួយខែ ដែលកើនឡើងចំនួន ១២ ដុល្លារ បើប្រៀបធៀបនឹងឆ្នាំ ២០១៨ ដែលមានត្រឹមតែ ១៧០ ដុល្លារក្នុងមួយខែ។ ទោះមានការកើនឡើងជាងឆ្នាំ ២០១៨ ក្តី ចំនួនប្រាក់ឈ្នួលអប្បបរមានេះមិនត្រូវបានទទួលការសាទរពីគ្រប់សហជីព និងសង្គមស៊ីវិលឃ្លាំមើលសិទ្ធិការងារនៅកម្ពុជានោះនៅឡើយទេ ដោយសារពួកគេបានវាយតម្លៃថាប្រាក់ឈ្នួល ១៨២ ដុល្លារអាមេរិក ក្នុងមួយខែ មិនទាន់ឆ្លើយតបនឹងតម្រូវ

[29] Quoted by Asia Times: The injustice of Cambodian justice, by David Hutt, May 17th , 2019; https://asiatimes.com/2019/05/the-injustice-of-cambodian-justice/

[30] Some Independent worker unions are placed in the government back list, as part of the Color revolution, to over thrown the government.

ការជីវភាពរស់នៅពិតប្រាកដរបស់កម្មករទេ។[31] មាត្រា១០៤ នៃច្បាប់ស្តីពីការងារចែងថា ប្រាក់ឈ្នួលកម្មករយ៉ាងហោចណាស់ ត្រូវរ៉ាប់រងកម្មករនិយោជិក គ្រប់រូបឲ្យមានកម្ពស់ជីវភាពសមរម្យទៅតាមសេចក្តីថ្លៃថ្នូររបស់មនុស្ស។

គិតត្រឹមឆ្នាំ ២០១៩ បេឡាជាតិរបបសន្តិសុខសង្គមនៃប្រទេសកម្ពុជាទទួលបានពានរង្វាន់ចំនួន ៤ លើករួចមកហើយ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) លើកទី(១) ពានរង្វាន់អង្គភាពឆ្នើម ក្នុងការអនុវត្ត របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឆ្នាំ ២០១៥ លើកទី(២) ពានរង្វាន់ឆ្នើមស្តីពីការគ្របដណ្តប់ផ្នែកការធានារ៉ាប់រងរបបសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាពខ្ពស់នៅឆ្នាំ ២០១៦ លើកទី(៣) ទទួលបានពានរង្វាន់ ស្តីពីការផ្តល់សេវាល្អសម្រាប់ របបថែទាំសុខភាពនៅឆ្នាំ ២០១៨ នៅប្រទេសវៀតណាម និងលើកទី(៤) ពានរង្វាន់ស្តីពីការផ្តល់សេវាធានារ៉ាប់រង សុខភាពសម្រាប់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅឆ្នាំ ២០១៩ (Health Care Scheme for Public Employees, Former Civil Servants, and Veterans)ប្រទេសព្រុយនេ ។[32]

នៅក្នុងឆ្នាំ ២០១៩ នេះច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មីត្រូវបានប្រកាសឱ្យប្រើប្រាស់ ដែលគ្របដណ្តប់ទៅលើការគាំពារចំនួន ៤ផ្នែក រួមមាន (១)ផ្នែកប្រាក់សោធន (២)ផ្នែកថែទាំសុខភាព (៣)ផ្នែកហានិភ័យការងារ និង (៤)ផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើតាមផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជន៍ផងដែរ។[33] ប៉ុន្តែច្បាប់នេះត្រូវបានទទួលរងការរិះគន់ថា មិនបានឆ្លងកាត់ការពិគ្រោះយោបល់ឲ្យបានទូលំទូលាយពីភាគីពាក់ព័ន្ធជាពិសេសអង្គការសង្គមស៊ីវិល និងសហជីពដែលធ្វើកំពុងធ្វើការតាមដាន និងឃ្លាំមើលសិទ្ធិសេរីភាព និងការពារអត្ថប្រយោជន៍របស់កម្មករ។ បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) កន្លងមកបាន និងកំពុងអនុវត្តនូវរបបសន្តិសុខសង្គមចំនួន ២ គឺផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ដែលចាប់តាំង ពីឆ្នាំ ២០១៩ មករបបសន្តិសុខសង្គមទាំងពីរនេះ បានគ្របដណ្តប់ទាំងកម្មករនិយោជិត និងមន្ត្រីសាធារណៈ។

---

[31] ប្រាក់ឈ្នួលអប្បបរមាក្នុងឧស្សាហកម្មកាត់ដេរនឹងត្រូវបានដំឡើងដល់១៨២ដុល្លារអាមេរិកនៅឆ្នាំ២០១៩, ហ៊ុល រស្មី, 05 តុលា 2018, https://khmer.voanews.com/a/cambodia-set-a-new-minimum-wage-for-garment-workers-in-2019/4601462.html

[32] ប្រតិភូ នៃបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា ចូលរួមកិច្ចប្រជុំសមាគមសន្តិសុខសង្គមអាស៊ានលើកទី៣៦ នៅប្រទេសប៊្រុយណេ ដោយ៖ Roeun Setharun, ចេញផ្សាយ៖ ថ្ងៃ អង្គារ ទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៩, https://bit.ly/2KZar4H

[33] ឯកឧត្តមបណ្ឌិត អ៊ុិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ លទ្ធផលការងារដែល ប.ស.ស សម្រេចបានក្នុងឆ្នាំ២០១៩ កន្លងមកនេះ ដោយ៖ Roeun Setharun, ចេញផ្សាយ៖ ថ្ងៃ សុក្រ ទី ១៧ ខែ មករា ឆ្នាំ ២០២០, https://bit.ly/35w8sP3

ដោយឡែក ទាក់ទងបញ្ហាសុខភាព និងសុវត្ថិភាពការធ្វើដំណើររបស់កម្មករ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៩ មានកម្មករនិយោជិត សន្លប់មានចំនួន ១១ រោងចក្រ និងកម្មករនិយោជិតសន្លប់ចំនួន ៨៣១ នាក់ ក្នុងនោះស្រី ៨២២ នាក់ ដែលមានការថយចុះចំនួន ៦ រោងចក្រ ស្មើនឹង ៣៥% និងកម្មករនិយោជិតសន្លប់ថយចុះចំនួន ១,២៧៨ នាក់ ស្មើនឹង ៦១% បើប្រៀបធៀបនឹងឆ្នាំ ២០១៨ ។ របាយការណ៍សង្កេត និងសិក្សាស្រាវជ្រាបានបន្ថែមថា មូលហេតុចម្បងៗដែលបណ្តាលឱ្យមានករណីសន្លប់កើតមានឡើង រួមមានដូចជា បញ្ហាចិត្តសាស្ត្រសង្គម ៣៩% បញ្ហាគីមី ១៨% បញ្ហារូបសាស្ត្រ ១៨% បញ្ហាមេកានិច ៧% បញ្ហាជីវសាស្ត្រ ៧% បញ្ហាវិទ្យាសាស្ត្ររៀបចំការងារ ៧% និងបញ្ហាការងារបន្ថែមម៉ោង ៤% ។[34]

ចំណែកករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកចំពោះកម្មករនិយោជិតក្នុងឆ្នាំ ២០១៩ កន្លងទៅនេះ បានកើតឡើងចំនួន ១,៥៥៤ ករណី (គ្រោះថ្នាក់ដោយរថយន្តចំនួន ៤៣ ករណី ដោយសារម៉ូតូចំនួន ១, ៤៣៧ ករណី រ៉ឺម៉កចំនួន ៩ ករណី, កង់ចំនួន ១២ ករណី, និងអ្នកថ្មើរជើងចំនួន ៥៣ ករណី) ដែលមានជនរងគ្រោះចំនួន ២,០០៦នាក់ បណ្តាលឱ្យស្លាប់ចំនួន ៥០ នាក់ របួសធ្ងន់ចំនួន ៣៤១ នាក់ និងរបួសស្រាលចំនួន ១,៦១៥ នាក់។ បើប្រៀបធៀបរយៈពេលដូចគ្នានៅក្នុងឆ្នាំ ២០១៨ ធៀបនឹងឆ្នាំ ២០១៩ ជាលទ្ធផលក្នុងឆ្នាំ ២០១៩ ករណីគ្រោះថ្នាក់ចរាចរណ៍មានការថយចុះចំនួន ១៥៦ ករណី ស្មើនឹង ១០% ចំណែកជនរងគ្រោះមានការកើនឡើងចំនួន ១៤៣ នាក់ ស្មើនឹង ៧% ។ ករណីដែលបង្កឱ្យករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងនេះ គឺបណ្តាលមកពីមូលហេតុចម្បងៗ មួយចំនួនដូចជា បើកបរលើសល្បឿនកំណត់ ៣៧% , និងកត្តាមិនគោរពសិទ្ធអាទិភាព ២៣% , ជែងក្នុងស្ថានភាពគ្រោះថ្នាក់ ១៨% , បត់ខ្វះការប្រុងប្រយ័ត្ន ៩.២% , មិនប្រកាន់ស្តាំ ៨% , លក្ខណៈបច្ចេកទេសយានយន្ត ៤% , និងកត្តាផ្លូវ ០.៨%។[35]

## 2. គោលនយោបាយ និងការរៀបចំអាទិភាព នៃបរិយាកាសអនុវត្តយុទ្ធសាស្ត្រចតុកោណ

ដើម្បីបង្កើតអោយមានបរិស្ថានសំរាប់អនុវត្តយុទ្ធសាស្ត្រទាំងមូលនេះបានជោគជ័យ ផែនការយុទ្ធសាស្ត្ររាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ
- បរិយាកាសអំណោយផលសម្រាប់ធុរៈកិច្ច ការវិនិយោគ និងការអភិវឌ្ឍ
- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

---

[34] ទាំងករណីសន្លប់ និងករណីគ្រោះថ្នាក់ចរាចរណ៍របស់បងប្អូនកម្មករនិយោជិតមានការថយចុះបើធៀបជាមួយឆ្នាំ២០១៨ ជាមួយនឹងឆ្នាំ ២០១៩, ដោយ៖ Roeun Setharun ថ្ងៃ សុក្រ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០, https://bit.ly/2L8ZVYY

[35] ទាំងករណីសន្លប់ និងករណីគ្រោះថ្នាក់ចរាចរណ៍របស់បងប្អូនកម្មករនិយោជិតមានការថយចុះបើធៀបជាមួយឆ្នាំ២០១៨ ជាមួយនឹងឆ្នាំ ២០១៩, ដោយ៖ Roeun Setharun ថ្ងៃ សុក្រ ទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០, https://bit.ly/2L8ZVYY

- ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មរបស់ខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

### 2.1. សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ

សកម្មភាពបដិវត្តន៍ពណ៌ត្រូវបានរាជរដ្ឋាភិបាលកំណត់ថា ជាការប៉ុនប៉ងផ្តួលរលំរដ្ឋាភិបាល ដែលអាចនឹងផ្តល់ផលអាក្រក់ដល់ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សារធារណៈ ប្រក្រតីភាពនៃស្ថាប័នសាធារណៈ និងសន្តិភាពនៅក្នុងប្រទេស ជាពិសេសក្រោយពី គណបក្សសង្គ្រោះជាតិ ត្រូវ បានគេរំលាយ។ រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងម៉ឺងម៉ាត់ចំពោះសកម្មភាពបដិវត្តន៍ និងបន្តឲ្យមានដំណើរការប្រជាធិបតេយ្យតាមរយៈការបោះឆ្នោតដែលបានកំណត់ដោយច្បាប់។

រាជរដ្ឋាភិបាលក៏នឹងបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ ចំពោះការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ដោយបន្តពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ វប្បធម៌សន្តិភាព សីលធម៌សង្គម ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមជាមួយនឹងការបន្តជំរុញអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាព និងបន្តពង្រឹងសុវត្ថិភាពចរាចរណ៍ សណ្តាប់ធ្នាប់សារធារណៈដោយលុបបំបាត់សកម្មភាព និងការប្រើប្រាស់យានយន្តខុសច្បាប់ និងបច្ចេកទេសតាមដងផ្លូវ។

រាជរដ្ឋាភិបាលបន្តដោះស្រាយ និងអនុវត្តកិច្ចសហប្រតិបត្តិការជាមួយប្រទេសអន្តរជាតិ រួមទាំងប្រទេសជិតខាងកម្ពុជា នូវកិច្ចការបទេស ដូចជា ការដោះស្រាយបញ្ហាព្រំដែន ការទប់ស្កាត់បទល្មើសឆ្លងដែន សកម្មភាពភេរវកម្ម ការជួញដូរគ្រឿងញៀន និងមនុស្ស និងអាជីវកម្មផ្លូវភេទ។ រយៈប៉ុន្មានទសវត្សរ៍កន្លងមកនេះ ចំនួនអ្នកប្រើប្រាស់គ្រឿងញៀនបានកើនឡើងយ៉ាងឆាប់រហ័ស ហើយបានកំពុងរីករាលដាលដល់តំបន់ជនបទផងដែរ។

រាជរដ្ឋាភិបាលពង្រឹងសមត្ថភាព ដើម្បីទប់ស្កាត់បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា និងពង្រឹងសកម្មភាពអនុវត្តច្បាប់សញ្ជាតិ និងច្បាប់អន្តោប្រវេសន៍ផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍របស់ក្រុមអង្គការសង្គមស៊ីវិលនៅកម្ពុជា ដែលចេញផ្សាយក្នុងឆ្នាំ ២០១៩ ស្តីពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជា បានវាយតម្លៃថា លំហរក្នុងការអនុវត្តសេរីភាពមូលដ្ឋាននៅកម្ពុជានៅតែបន្តរងការរឹតត្បិតនៅឡើយ។ ការរឹតត្បិតសេរីភាពនេះត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយចម្រុះៗមួយចំនួន ដូចជា ការធ្វើវិសោធនកម្មមាត្រាច្បាប់ និងការអនុវត្តច្បាប់មិនត្រឹមត្រូវ និងស្មើភាពគ្នា ដូចជា ការតាមដាន ឃ្លាំមើល និងជ្រៀតជ្រែកសកម្មភាពរបស់អង្គការសង្គមស៊ីវិល ជាមួយប្រជាពលរដ្ឋ ដែលធ្វើឲ្យធ្លាក់ចុះនូវលទ្ធភាពរបស់សាធារណជនក្នុងការអនុវត្តសេរីភាពរបស់ខ្លួន។ របាយការណ៍បានសង្កត់ធ្ងន់ថា ការរឹតត្បិតពីអាជ្ញាធរជាខ្លាំងក្នុងអំឡុងខែកក្កដា ឆ្នាំ ២០១៨ មុនការបោះឆ្នោតជាតិ។ សេរីភាពមូលដ្ឋានដែលត្រូវបានរងការរឹតត្បិត រួមមាន សេរីភាពការបង្កើតសមាគម សេរីភាពការបញ្ចេញមតិ និងសេរីភាពការជួបជុំ។

នៅក្នុងឆ្នាំ ២០១៩ នេះ គេកត់សម្គាល់ឃើញថា មិនសូវមានចលនាទាមទារពីសំណាក់ប្រជាពលរដ្ឋកើតមានក្នុងរាជធានីភ្នំពេញទេ បើប្រៀបធៀបទៅនឹងរយៈពេលមុន។ ទោះបីចលនាទាមទារនេះបានធ្លាក់ចុះ អាជ្ញាធរនៅតែមានការរឹតបណ្តឹងការជួបជុំសម្តែងមតិជាសាធារណៈដដែល។ នៅដើមឆ្នាំ ២០១៩ អាជ្ញាធររាជធានីភ្នំពេញបានរារាំង និងហាមឃាត់សកម្មភាពរបស់អង្គការសង្គមស៊ីវិល ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មីនា ខួបទី ១០៨។ អាជ្ញាធរមិនអនុញ្ញាតឲ្យប្រជាពលរដ្ឋដើរហែក្បួនសម្តែងមតិរបស់ខ្លួនជាសាធារណៈឡើយ។ ជាការកត់សម្គាល់ ជួបជុំហែរក្បួនផ្សេងៗរបស់មហាជនតែងត្រូវអាជ្ញាធរហាមឃាត់នៅក្នុងឆ្នាំ ២០១៩ កន្លងទៅនេះ។

ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធ័រណិត អង្គការ Freedom House បានចេញរបាយការណ៍ថ្មីមួយរបស់ខ្លួនឆ្នាំ ២០១៩ ដោយបង្ហាញឲ្យឃើញថា សេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធ័រណិតនៅកម្ពុជាបានបន្តធ្លាក់ចុះ ជាពិសេសមុន និងក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ ២០១៨ ។ ពិន្ទុនៃសេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធ័រណិតនៅកម្ពុជាធ្លាក់ចុះ ២ ពិន្ទុ ពី ៤៥ លើ១០០ សម្រាប់ឆ្នាំ ២០១៨ មកត្រឹម ៤៣ លើ ១០០ សម្រាប់ឆ្នាំ ២០១៩។ នេះបើយោងតាមរបាយការណ៍ដែលមានចំណងជើងថា Freedom on the Net: The Crisis of Social Meida របស់អង្គការអន្តរជាតិ Freedom House ដែលត្រូវបានចេញផ្សាយជាសាធារណៈ កាលពីថ្ងៃទី ១២ ខែវិច្ឆិកា។[36] អង្គការ Freedom House កំណត់ថា ពិន្ទុពី ៧០ ដល់ ១០០ មានន័យថា មានសេរីភាពពេញលេញពី ៤០ ដល់ ៦៩ មានសេរីភាពខ្លះ និងពី ០ ដល់ ៣៩ មិនមានសេរីភាពទាល់តែសោះ។ របាយការណ៍បានបន្ថែមថា ចាប់ពីខែមិថុនា ឆ្នាំ២០១៨ ដល់ខែឧសភា ឆ្នាំ ២០១៩ នៅកម្ពុជា មានករណីគាបសង្កត់មួយចំនួនដោយរដ្ឋាភិបាលកម្ពុជា លើសេរីភាពរបស់បុគ្គល និងស្ថាប័នឯករាជ្យ ក្នុងការបញ្ចេញមតិរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានយោបាយ និងសង្គម តាមប្រព័ន្ធអ៊ីនធ័រណិត ដូចជា បណ្តាញសង្គម និងការផ្សព្វផ្សាយព័ត៌មានតាមគេហទំព័រជាដើម។ ការគាបសង្កត់លើសេរីភាពបញ្ចេញមតិតាមរយៈប្រព័ន្ធអ៊ីនធ័រណិតនេះ ត្រូវបានគេវាយតម្លៃថា ជាការអនុវត្តមាត្រាច្បាប់បរិហារកេរ្តិ៍ និងច្បាប់ប្រមាថព្រះមហាក្សត្រ និងជាចេតនារបស់រដ្ឋាភិបាលកម្ពុជាក្នុងការគ្រប់គ្រងការចែករំលែកព័ត៌មានតាមប្រព័ន្ធអ៊ីនធ័រណិត និងបណ្តាញសង្គម។

[36] របាយការណ៍៖ សេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធ័រណិតបន្តធ្លាក់ចុះនៅកម្ពុជា, ទែន សុខស្រីនិត, 28 វិច្ឆិកា 2019, https://khmer.voanews.com/a/Cambodia-freedom-on-the-net-has-further-declined-report-found/5183609.html




រូបផែនទីបង្ហាញពីស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតនៅជុំវិញពិភពលោក ដោយអង្គការអន្តរជាតិ Freedom House សម្រាប់ឆ្នាំ ២០១៩។

នៅចុងឆ្នាំ ២០១៨ ក្នុងខែវិច្ឆិកា ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹង អំពីការលុបចោលការជូនដំណឹងរបស់អង្គការសង្គមស៊ីវិល ដល់អាជ្ញាធរមុននឹងអនុវត្តសកម្មភាពរបស់ខ្លួននៅមូលដ្ឋាន។ យោងលើខ្លឹមសារក្នុងសេចក្តីជូនដំណឹងនាខែវិច្ឆិកា ឆ្នាំ ២០១៨ នេះ សេចក្តីជូនដំណឹងដែលបានចេញកាលពីខែតុលា ឆ្នាំ ២០១៧ ដែលតម្រូវឲ្យអង្គការស៊ីវិលជូនដំណឹងដល់អាជ្ញាធររយៈពេលចំនួន ០៣ ថ្ងៃមុនពេលធ្វើសកម្មភាពរបស់ខ្លួនត្រូវបាននិរាករ ដោយសេចក្តីជូនដំណឹងខាងលើ។ បើទោះបីមានសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ដែលមិនតម្រូវឲ្យមានការជូនដំណឹងដល់អាជ្ញាធរក្តី ក៏អង្គការសង្គមស៊ីវិលត្រូវបានសង្កេតឃើញថា បន្តជួបការលំបាកក្នុងការធ្វើការសកម្មភាពនៅមូលដ្ឋានដដែល។ អាជ្ញាធរមូលដ្ឋានត្រូវបានគេរាយការណ៍ថា មិនបានអនុវត្តតាមសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ផ្ទុយមកវិញអនុវត្តតាមបញ្ជារបស់មន្ត្រីថ្នាក់លើរបស់ខ្លួន។ ម្យ៉ាងវិញទៀត សេចក្តីជូនដំណឹងនេះមិនត្រូវបានផ្សព្វផ្សាយទូលំទូលាយនេះទេ។

ការខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃ ក៏ដូចជារាជរដ្ឋាភិបាលត្រូវបានគេរិះគន់ថា មិនមានប្រសិទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយ ឬកែប្រែការការអនុវត្តបច្ចុប្បន្នរបស់អាជ្ញាធរ ដែលកើតចេញពីកម្សោយនៃការអនុវត្តច្បាប់ និងការមានអំពើពុករលួយ។

នៅក្នុងវិធានការបង្ក្រាបទាំងនេះ ពាក្យបដិវត្តពណ៌ត្រូវបានលើកឡើងជាមូលដ្ឋាន សម្រាប់រារាំងប្រជាពលរដ្ឋរិះគន់រដ្ឋាភិបាល ឬរៀបចំបាតុកម្មដោយសន្តិវិធី។ អង្គការមិនមែនរដ្ឋាភិបាលជាង ៤០ និងបុគ្គលមួយចំនួនត្រូវបានដាក់ក្នុងបញ្ជីខ្មៅរបស់រដ្ឋាភិបាល ដោយចាត់ទុកពួកគេថា បានគាំទ្រចលនាបដិវត្តពណ៌ដើម្បីផ្តួលរំលំរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ការចោទប្រកាន់នេះត្រូវបានសហគមន៍ជាតិ និងអន្តរជាតិរិះគន់ថា ជាឧបករណ៍ដែលរដ្ឋាភិបាលប្រើ ដើម្បីរក្សាស្ថេរភាពអំណាចរបស់គណបក្សកាន់អំណាច តែ

ប៉ុណ្ណោះ បន្ទាប់ពីគណបក្សនេះបានបាត់បង់ការគាំទ្រយ៉ាងច្រើន ក្នុងការបោះឆ្នោតនៅឆ្នាំ ២០១២ ២០១៣ និង ២០១៧ ។

គួរកត់សម្គាល់ថា ការបោះឆ្នោតនៅឆ្នាំ ២០១៨ ត្រូវបានគេរិះគន់ថា មិនមានសេរី និងយុត្តិធម៌ទេ។ ទម្រង់នៃការបំភិតបំភ័យ និងការគំរាមកំហែងជាច្រើនត្រូវបានគេសង្កេតឃើញបានកើតមានឡើងមុនការបោះឆ្នោត[37] ហើយការបោះឆ្នោតត្រូវបានធ្វើឡើង ដោយមិនមានការចូលរួមរបស់គណបក្សប្រឆាំងចម្បងណាមួយទេ។

### 2.2. បរិយាកាសអំណោយផលសម្រាប់ធុរៈកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

រាជរដ្ឋាភិបាល ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងអតិផរណាទាប នឹងបន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយហិរញ្ញវត្ថុសាធារណៈ គោលនយោបាយរូបិយវត្ថុ និងការកែទម្រង់រចនាសម្ព័ន្ធ។ ជាមួយគ្នានេះដែរ រដ្ឋាភិបាលនឹងរៀបចំយន្តការគ្រប់គ្រងវិបត្តិ និងហានិភ័យផ្នែកសេដ្ឋកិច្ចក្នុងវិស័យហិរញ្ញវត្ថុ អចលនទ្រព្យ និងវិស័យដ៏ទៃទៀត។ រាជរដ្ឋាភិបាលនឹងធ្វើវិសោធនកម្មច្បាប់ស្តីពីការវិនិយោគ និងអនុវត្តច្បាប់នេះ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសឲ្យមានប្រសិទ្ធភាពផងដែរ។

រាជរដ្ឋាភិបាលនឹងបង្កើនប្រសិទ្ធភាពប្រមូលចំណូលថវិកាជាតិ តាមរយៈកំណែទម្រង់ប្រព័ន្ធពន្ធដារ ព្រមទាំងមានគម្រោងរៀបចំច្បាប់ស្តីពីសារពើពន្ធថ្មី ដើម្បីទទួលបានបរិយាកាសប្រកួតប្រជែងដោយតម្លាភាព គណនេយ្យភាព ស្មើភាព និងយុត្តិធម៌ លើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ច ធុរៈកិច្ច និងការវិនិយោគ ព្រមទាំងធានាបាននូវសមធម៌សង្គម។

ដើម្បីលើកកម្ពស់បរិយាកាសវិនិយោគ រាជរដ្ឋាភិបាលនិងកែសម្រួលនីតិវិធី និងសាវាសាធារណៈដែលពាក់ព័ន្ធនឹងការវិនិយោគ រួមមានការកាត់បន្ថយរយៈពេលនៃការចុះបញ្ជី និងការស្នើសុំអាជ្ញាប័ណ្ណ។

សម្រាប់រយៈពេល១២ខែ ឆ្នាំ ២០១៩ រាជរដ្ឋាភិបាល ក្រោមការអនុវត្តផ្ទាល់របស់អគ្គនាយកដ្ឋានពន្ធដារ បានប្រមូលចំណូលពន្ធ-អាករ បានចំនួន ប្រមាណ ២ ៨១៩,៣៣ លានដុល្លារ អារមេរិក ដែលបានលើសផែនការប្រមាណ ២៣,២០% ត្រូវជាប្រមាណ ៥៣០,៩២ លានដុល្លារ អាមេរិក។ ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៨ ចំណូលពន្ធ-អាករកើនឡើងចំនួនប្រមាណជា ៦២១,៤៨ លានដុល្លារ ស្មើនឹង ២៨,២៨%។

ក្នុងឆ្នាំ ២០១៩ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តនូវប្រព័ន្ធអនឡាញសម្រាប់ការស្នើសុំការបង្វិលសង និងការប្រើប្រាស់ឥណទានអាករលើតម្លៃបន្ថែម តាមប្រព័ន្ធអនឡាញសម្រាប់គ្រប់គ្រងអាករលើតម្លៃបន្ថែមរបស់អគ្គនាយកដ្ឋានពន្ធដារ (E-VAT Refund) បានបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រមូលអាករលើតម្លៃបន្ថែម និងទប់ស្កាត់ការគេចវេះកេងបន្លំប្រាក់ពន្ធ ដែលជាលទ្ធផលក្នុងរយៈពេល ១២ ខែ ឆ្នាំ

[37] Also see in the Diplomat: The Dark Year Since Cambodia's 2018 Election, by Mu Sochua, July 29th , 2019; https://thediplomat.com/2019/07/the-dark-year-since-cambodias-2018-election/

២០១៩ ចំណូលអាករលើតម្លៃបន្ថែមកើនឡើង ៣១,០៥% ប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ ២០១៨ ហើយតាមរយៈវិធានការ E-VAT រួមជាមួយ វិធានការពន្ធដារសំខាន់ៗផ្សេងៗទៀតបានជំរុញកំណើនពន្ធលើប្រាក់ចំណូលប្រមាណ ២៨,៤៧% អាករពិសេស ៣០,៧២% ពន្ធប្រថាប់ត្រា ៤៣,៧៣% ពន្ធលើប្រាក់បៀរវត្សន៍ ១៨,២១% និងពន្ធលើឈ្នួលដី និងផ្ទះ ៦៨,២០% ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។[38]

ដោយឡែករាជរដ្ឋាភិបាលបានប្រមូលថវិកាជាតិពីចំណូលពន្ធគយឆ្នាំ ២០១៩ មានចំនួនប្រមាណ ៣,២១៥ លានដុល្លារ ដែលចំនួននេះលើសផែនការជិត ១ ពាន់លានដុល្លារ។ នៅឆ្នាំ ២០១៩ ប្រភេទពន្ធសំខាន់ៗ ដែលជំរុញកំណើនចំណូលគយរួមមាន ពន្ធនាំចូល ឬពន្ធគយមាន ៥៩៣ លានដុល្លារកើនឡើង ៣០.៧ ភាគរយបើធៀបនឹងឆ្នាំ ២០១៨ អាករពិសេសមានប្រមាណ ១.៣២០ លានដុល្លារ កើនឡើង៣៣ ភាគរយ អាករលើតម្លៃបន្ថែមប្រមូលបាន ១.១៥៣ លានដុល្លារ កើតឡើងជិត ២៩ភាគរយ។[39]

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងនេះហើយក្តី ក៏វិស័យឯកជននៅតែប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចជា៖ គោលនយោបាយពន្ធមិនទាន់ច្បាស់លាស់គ្រប់គ្រាន់សម្រាប់អនុវត្ត និងស្ថាប័នឯកជនជាច្រើនជួបប្រទះការលំបាកក្នុងការស្វែងយល់អំពីប្រព័ន្ធពន្ធ និងនីតិវិធីបង់ពន្ធ។ ក្រុមហ៊ុនឯកជនមួយចំនួនបានត្អូញត្អែរថា ពួកគេត្រូវចំណាយពេលច្រើនជាមួយការងាររៀបចំឯកសារ ហើយម្យ៉ាងវិញទៀត ពួកគេត្រូវរង់ចាំដំណើរការនៃការទទួលបានសេវាជាច្រើនដំណាក់ មុនពេលពួកគេឈានដល់ការបង់ពន្ធ។ តួនាទីរបស់ស្ថាប័នឯកជន រួមទាំងសហគ្រាសធុនតូច និងមធ្យម នៅតែមានភាពទន់ខ្សោយបើប្រៀបធៀបនឹងប្រទេសជិតខាង។ រដ្ឋាភិបាលមិនមានទាំងធនធាន និងជំនួយបច្ចេកទេសដើម្បីគាំទ្រដល់វិស័យនេះទេ។

នៅខែកុម្ភៈ ដើមឆ្នាំ ២០២០ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ស្នើសុំនាំចូលទំនិញ បម្រើឱ្យគម្រោងវិនិយោគ ដើម្បីកាត់បន្ថយពេលវេលាឲ្យបានរហ័ស។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះត្រូវបានគេហៅថា ប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window)។[40] ការរៀបចំដាក់ឱ្យដំណើរការនូវ ប្រព័ន្ធបញ្ជរតែមួយជាតិ ត្រូវបានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចាត់ទុកថាជាកាតព្វកិច្ចរបស់កម្ពុជាក្នុងនាមជាសមាជិកអាស៊ាន និងជាវិធានការកំណែទម្រង់មុតស្រួចរបស់រាជរដ្ឋាភិបាលសំដៅកែលម្អបរិយាកាសធុរៈកិច្ចនិងវិនិយោគ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា។ គួររំលឹកផងដែរថា

---

[38] ទំព័រ ២ នឹង៣, សេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០១៩ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្ត របស់អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២០

[39] លោក គណ ញឹម៖ ជំងឺ Covid-19 អាចរារាំងដល់ផែនការរកចំណូលរបស់គយក្នុងឆ្នាំ២០២០ ខណៈចំណូលឆ្នាំ២០១៩រកបាន៣,២១៥លានដុល្លារលើសផែនការ https://bit.ly/2L9rMrL

[40] CDC ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ស្នើសុំនាំចូលទំនិញ បម្រើឱ្យគម្រោងវិនិយោគ ដើម្បីកាត់បន្ថយពេលវេលាឲ្យបានរហ័ស, https://bit.ly/3bcQYZc

កម្ពុជា បានចូលជាសហគមន៍សេដ្ឋកិច្ចអាស៊ានដែលប្រទេសជាសមាជិកអាស៊ានទាំងអស់បានបើកទូលាយឱ្យមានរំហូរដោយសេរីនូវទំនិញ កម្លាំងពលកម្ម និងមូលធន។

នៅដំណាក់កាលទី ១ បានដាក់ឱ្យមានការតភ្ជាប់គ្នារវាងប្រព័ន្ធ ASYCUDA របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងប្រព័ន្ធចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមនៃទំនិញ របស់ក្រសួងពាណិជ្ជកម្ម។ ដំណាក់កាលទី ២ ដែលមានក្រសួង-ស្ថាប័នចំនួន ៦ ចូលរួមអនុវត្តគឺ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។ គិតមកដល់ពេលនេះ វាមានរយៈពេលខ្លីពេកក្នុងការវាយតម្លៃអំពីកម្រិតប្រសិទ្ធិភាពនៃការអនុវត្តប្រព័ន្ធថ្មីនេះ។

### 2.3. ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

រាជរដ្ឋាភិបាល ក្នុងគោលបំណងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ នឹងបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីទទួលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ ដើម្បីឲ្យកម្ពុជាចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច។ រាជរដ្ឋាភិបាលបន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃកិច្ចសហប្រតិបត្តិការនេះ។

រាជរដ្ឋាភិបាលនឹងទាក់ទាញការវិនិយោគថែមទៀត ទាំងពីវិស័យឯកជន និងស្ថាប័នអភិវឌ្ឍផ្លូវការ និងអភិវឌ្ឍវិស័យពាណិជ្ជកម្ម ជំរុញការធ្វើពិពិធភាវូបនីយកម្មឧស្សាហកម្ម និងកសិកម្ម តាមរយៈការបន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការបង្កើតបន្ថែមនូវយន្តការថ្មីៗ។

ក្នុងឆ្នាំ ២០១៩ ក្រសួងមហាផ្ទៃ បានរៀបចំឲ្យមានដំណើរការវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រោយពីក្រសួងបានចេញសេចក្តីជូនដំណឹងពីការលុបចោលនីតិវិធីជូនដំណឹងដល់អាជ្ញាធរអំពីការអនុវត្តសកម្មភាពរបស់អង្គការសង្គមស៊ីវិល។ ក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យមានធាតុចូលពីក្រុមអង្គការស៊ីវិល និងមានការជជែកពិភាក្សារវាងក្រុមការងាររបស់ក្រសួងមហាផ្ទៃ និងអង្គការសង្គមស៊ីវិលផងដែរ។ តំណាងសង្គមស៊ីវិលបានផ្តល់ធាតុចូលជាសេចក្តីស្នើវិសោធនកម្មច្បាប់នេះចំនួន ១៤ មាត្រាសំខាន់ៗ ដែលបានប៉ះពាល់ដល់សិទ្ធិសេរីភាពជាមូលដ្ឋានក្នុងការធ្វើសកម្មភាពរបស់ខ្លួន និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ សង្គមស៊ីវិលយល់ថា ច្បាប់នេះជាការដាក់កាតព្វកិច្ច និងរំលោភសិទ្ធិស្វ័យភាពបុគ្គល ដូចជា ការដាក់របាយការណ៍ជូន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នីតិវិធីបង់ពន្ធដ៏ស្មុគស្មាញ និងពាក្យពេចន៍ដែលអនុញ្ញាតឱ្យមន្ត្រីរដ្ឋមួយចំនួនធ្វើការបកស្រាយតាមកាលៈទេសៈ និងតាមស្ថានភាពនយោបាយ រួមទាំងការអនុវត្តន៍ដែលមិនឆ្លុះបញ្ចាំងពីខ្លឹមសារនៃច្បាប់ជាដើម។

ដំណើរការរៀបចំវិសោធនកម្មច្បាប់នេះបានប្រើប្រាស់រយៈពេលយូរ បើប្រៀបធៀបនឹងលទ្ធផលនៃកិច្ចប្រជុំពិភាក្សារវាងសង្គមស៊ីវិល និងក្រសួងមហាផ្ទៃ កន្លងមក។ ម្យ៉ាងវិញទៀត ក្រសួងមហាផ្ទៃ មិនបានដាក់ចេញនូវផែនការបង្ហាញផ្លូវសម្រាប់ធ្វើវិសោធនកម្មនេះឡើយ។ ការណ៍នេះបង្កើតឲ្យមានសង្ស័យអំពីឆន្ទៈរបស់ក្រសួង ឬរាជរដ្ឋាភិបាលអំពីការធ្វើឲ្យសម្រេចបាននូវវិសោធនកម្មនេះ។

ដោយវាយតម្លៃអំពីការកង្វះឆន្ទៈក្នុងធ្វើវិសោធនកម្មច្បាប់នេះ នៅដើមឆ្នាំ ២០២០ នេះ សហគមន៍ និងអង្គការសង្គមស៊ីវិល ទទូចឱ្យរាជរដ្ឋាភិបាលកម្ពុជា ធ្វើការនិរាករណ៍ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមសង្គមស៊ីវិលបានតាមដាន និងវាយតម្លៃថា កិច្ចប្រជុំរវាង ក្រសួងមហាផ្ទៃ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន មិនបានផ្តល់លទ្ធផលជាវិជ្ជមាន ចំពោះការធ្វើវិសោធនកម្មច្បាប់នេះឱ្យមានភាពល្អប្រសើរនោះទេ។ ច្បាប់គ្រាន់តែជាឧបករណ៍ដើម្បីរឹតត្បិតសេរីភាព ក្នុងការជួបជុំការបង្កើតអង្គការ និងការសម្តែងមតិផ្សេងៗរបស់សមាជិកសង្គមស៊ីវិលកម្ពុជាតែប៉ុណ្ណោះ។ ជាការឆ្លើយតប ក្រសួងមហាផ្ទៃបានច្រានចោលការចោទប្រកាន់នេះ ដោយក្រសួងបានអះអាងថា ពួកគេកំពុងដំណើរការវិសោធនកម្មច្បាប់នេះហើយ។ ក្នុងឆ្នាំទី ១ នីតិកាលទី៦ នេះ រាជរដ្ឋាភិបាលក្រោមការអនុវត្តផ្ទាល់របស់ក្រសួងមហាផ្ទៃបានរៀបចំឲ្យមានវេទិកាជួបជែកពិភាក្សាថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ក្នុងគោលបំណងសម្របសម្រួល និងបង្កើនកិច្ចសហប្រតិបត្តិការ។

ភ្លាមៗបន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ ២០១៨ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ត្រូវបានស្នើសុំឱ្យចុះបញ្ជីសារជាថ្មីនៅក្រសួងមហាផ្ទៃ។ ដូចអ្វីដែលធ្លាប់ទទួលបានពីបទពិសោធពីអង្គការក្រៅរដ្ឋាភិបាលជាច្រើន នីតិវិធីនៃដំណើរការចុះបញ្ជីនេះយឺតយ៉ាវ ហើយក្នុងករណីខ្លះអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការពាក់ព័ន្ធនឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ត្រូវបានពន្យាពេលយ៉ាងក្នុងការទទួលបានការចុះបញ្ជី។

បញ្ហាចម្បងមួយចំនួនក៏ត្រូវបានលើកឡើងដោយអង្គការអន្តរជាតិផងដែរ។ ពួកគេមានការលំបាកយ៉ាងខ្លាំងក្នុងការចុះ MOU ជាមួយរដ្ឋាភិបាល ជាពិសេស សម្រាប់អង្គការដែលកំពុងធ្វើការ ដើម្បីគាំទ្របណ្តាញមូលដ្ឋានសម្រាប់ការតស៊ូមតិ និងសិទ្ធិមនុស្ស។ រដ្ឋាភិបាលក៏ទាមទារផងដែរនូវ របាយការណ៍យ៉ាងលម្អិតទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកសកម្មភាព ពីអង្គការក្រៅរដ្ឋាភិបាល (ទាំងជាតិ និងបរទេស)។ ការទាមទារបែបនេះត្រូវបានគេដឹងថា សម្រាប់ប្រើប្រាស់ដោយចេតនានយោបាយក្នុងគ្រប់គ្រង ជាជាងក្នុងតម្រូវការការងាររដ្ឋបាល។

### 2.4. ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

រាជរដ្ឋាភិបាលបន្តពង្រឹងសកម្មភាពតភ្ជាប់ផ្នែកធុរៈកិច្ច ការផ្តល់សេវា និងភាពប្រកួតប្រជែង និងសកម្មភាពចូលរួមក្នុងកិច្ចសហប្រតិបត្តិការ និងគំនិតផ្តួចផ្តើមនៃសមារណកម្មសេដ្ឋកិច្ចអន្តរជាតិ តំបន់ និងទ្វេភាគី ព្រមទាំងកសាងសមត្ថភាពតាមដាននិន្នាការពាណិជ្ជកម្ម។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាមួយអង្គការពាណិជ្ជកម្មពិភពលោក និង សហគមន៍សេដ្ឋកិច្ចអាស៊ាន និងក្រមខណ្ឌទ្វេភាគីក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងអរូបវន្ត ការកែលម្អក្របខណ្ឌគតិយុត្ត ការកសាងសមត្ថភាពស្ថាប័ន និងមនុស្សជាដើម។ រាជរដ្ឋាភិបាលក៏ជំរុញការបង្កើតតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយតំបន់សំខាន់ៗដូចជា អឺរ៉ាស៊ី សហគមន៍អឺរ៉ុប ព្រមទាំងកិច្ចព្រមព្រៀងភាពដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងទៀត។

នៅឆ្នាំ ២០១៩ កម្ពុជាក៏ទទួលរងផលប៉ះពាល់ពីដំណើរការនៃការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ «អ្វីៗគ្រប់យ៉ាងលើលែងតែអាវុធ» (EBA) ដែលផ្តល់ដោយក្រុមប្រឹក្សា សហភាពអឺរ៉ុប តាំងពីឆ្នាំ ២០០១ និងប្រព័ន្ធផែនការអនុគ្រោះពន្ធរបស់សហរដ្ឋអាមេរិក (GSP) ។ EBA គឺជាគំនិតផ្តួចផ្តើម របស់សហភាពអឺរ៉ុប ដែលអនុញ្ញាតឱ្យ ការនាំចូលទំនិញទាំងអស់ លើកលែងតែសព្វាវុធ ទៅសហភាពអឺរ៉ុបពីប្រទេសអភិវឌ្ឍន៍តិចតួចទទួលនូវការអនុគ្រោះដោយមិនជាប់ពន្ធនាំចូលនិងកូតា។ ការធ្លាក់ចុះនូវស្ថានភាពការគោរពសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ក្រោយពីមានការវិវត្តស្ថានការណ៍នយោបាយចុងក្រោយនេះ ធ្វើឲ្យក្រុមប្រឹក្សាសហភាពអឺរ៉ុបពិចារណាពីការដកប្រព័ន្ធអនុគ្រោះពន្ធនេះពីកម្ពុជា។ ក្នុងហេតុដូចគ្នានេះដែរ សហរដ្ឋអាមេរិកក៏បាន និងកំពុងដំណើរការនីតិវិធីដកប្រព័ន្ធអនុគ្រោះពន្ធ GSPផងដែរ។

ក្នុងគោលបំណងរក្សានូវប្រព័ន្ធអនុគ្រោះពន្ធនេះសម្រាប់កម្ពុជា ក្រុមប្រឹក្សាសហភាពអឺរ៉ុបបានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលក្នុងការកែលម្អស្ថានភាពសិទ្ធិមនុស្ស សិទ្ធិការងារ និងលទ្ធិប្រជាធិបតេយ្យផងដែរ។ អង្គការសង្គមស៊ីវិល សម្ព័ន្ធសហជីពវិស័យការងារ និងវិស័យឯកជនដែលដឹកនាំដោយសភាពាណិជ្ជកម្ម បានសំដែងការព្រួយបារម្ភអំពីផលប៉ះពាល់ពីការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ EBA ។ ប្រជាពលរដ្ឋ ជាពិសេសកម្មករក្នុងវិស័យកាត់ដេរសំលៀកបំពាក់ នឹងទទួលរងគ្រោះក្នុងជីវភាពរបស់ខ្លួន។ ម្យ៉ាងការបាត់បង់នេះនឹងប៉ះពាល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។ ជារឿយៗស្ថាប័នទាំងនោះបានអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាបន្តកិច្ចសន្ទនាអំពីបញ្ហាដែលជាកង្វល់របស់សហភាពអឺរ៉ុប។

ចំពោះរាជរដ្ឋាភិបាលកម្ពុជា បើទោះបីជាមានការព្រួយបារម្ភរបស់ភាគីពាក់ព័ន្ធជាច្រើនអំពីការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធនេះ បានចាត់ទុកថា ការអនុវត្តតាមអនុសាសន៍របស់ក្រុមប្រឹក្សាសហភាពអឺរ៉ុបដើម្បីថែរក្សាប្រព័ន្ធអនុគ្រោះព័ន្ធនេះគឺជាការបាត់បង់អធិបតេយ្យរបស់កម្ពុជា។ រាជរដ្ឋាភិបាលយល់ថា លក្ខខណ្ឌរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុប គឺការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សតាមស្តង់ដារទ្វេរ និងមិនសមស្រប ដើម្បីជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងប្រទេសដទៃតាមរយៈការប្រើប្រាស់ឧបករណ៍នយោបាយ និងសេដ្ឋកិច្ច ដែលនឹងបន្តដាក់សម្ពាធធ្ងន់ធ្ងរលើប្រទេសទន់ខ្សោយរាប់ទាំងកម្ពុជាផង។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២០ ក្រុមប្រឹក្សាសហភាពអឺរ៉ុប បានចេញសេចក្តីសម្រេចអំពីប្រព័ន្ធអនុគ្រោះពន្ធ EBA សម្រាប់កម្ពុជា។ តាមរយៈសេចក្តីសម្រេចនោះ គណៈកម្មការអឺរ៉ុប សម្រេចដកការអនុគ្រោះពន្ធ «ជាបណ្តោះអាសន្ន» ពីកម្ពុជា លើទំនិញចំនួន៤០ប្រភេទ ដែលភាគច្រើនជាសម្លៀកបំពាក់។

ផលិតផលទាំងអស់នេះ នាំចេញពីកម្ពុជាទៅអឺរ៉ុបក្នុងតម្លៃសរុបប្រមាណ ១ ពាន់លានអឺរ៉ូ (២០%) ជារៀងរាល់ឆ្នាំ។[41]

ទន្ទឹមនឹងការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធទាំងពីរខាងលើ រដ្ឋាភិបាលកម្ពុជាបានប្រកាសនៅក្នុងខែវិច្ឆិកាថា ប្រទេសកម្ពុជា និងចិនបាន និងកំពុងពិចារណានិងសន្ទនាដើម្បីឈានទៅបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTA) ។ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជាចិន មានទំហំ ៧ ពាន់លានដុល្លារ កាលពីឆ្នាំ ២០១៨ នេះបើយោងតាមក្រសួងពាណិជ្ជកម្ម។ នៅក្នុងនោះ កម្ពុជាមានឱនភាពដោយសារតែការនាំចូលពីប្រទេសចិនមានទំហំប្រមាណ ៦ ពាន់លានដុល្លារទៅហើយ។ ប្រទេសទាំងពីរគ្រោងបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីដល់ ១០ ពាន់លានដុល្លារត្រឹមឆ្នាំ ២០២៣ ។

យ៉ាងណាក្តីដំណឹងអំពីការរៀបចំកសាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ទ្វេភាគីរវាងកម្ពុជា និងចិននេះ បាននាំឱ្យមានប្រតិកម្មចម្រុះពីអ្នកពាក់ព័ន្ធ និងអ្នកតាមដាន។ ក្រសួងពាណិជ្ជកម្មកម្ពុជា បានលើកឡើងថា កម្ពុជាមានក្តីសង្ឃឹមរំពឹងថានឹងទាញបានផលចំណេញពីការធ្វើពាណិជ្ជកម្មសេរីជាមួយប្រទេសចិន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយចិន ត្រូវបានរំពឹងទុកថា នាំទៅបង្កើនការនាំចេញទំនិញកសិកម្មជាច្រើនមុខពីកម្ពុជា។

លោកបណ្ឌិត Bradley Jansen Murg អ្នកជំនាញសេដ្ឋកិច្ចនយោបាយ នៅសាកលវិទ្យាល័យ Seattle Pacific (SPU) បានលើកឡើងថា ខណៈដែលខាងកម្ពុជាកំពុងសំឡឹងមើលនិងរំពឹងបង្កើនការនាំចេញផលិតផលកសិកម្ម តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ ភាគីចិនក៏មិនឃើញអ្វីខាតបង់នោះដែរ។ អ្នកជំនាញរូបនេះក៏បានបន្ថែមដែរថា «និយាយក្នុងន័យនយោបាយ សម្រាប់ប្រទេសចិន នេះជាជ័យជម្នះមួយរបស់គេ ខណៈដែលការណ៍នេះនឹងនាំកម្ពុជាទៅកាន់តែកៀកក្នុងគន្លងគោចររបស់ចិន ដែលចិនមើលទៅមិនត្រូវបង់តម្លៃអ្វីជាដុំកំភួនទាល់តែសោះ។ ខណៈដែលចិនកំពុងតែស្វះស្វែងរកការបង្កើនឥទ្ធិពលរបស់ខ្លួននៅកម្ពុជា»។

ប៉ុន្តែរាជរដ្ឋាភិបាលនីតិកាលទី៦ នេះ ក៏ត្រូវបានរងការសង្ស័យអំពីឥទ្ធិពលភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ចរបស់ចិន ពីសំណាក់បណ្តារដ្ឋាភិបាលបស្ចិមលោក រួមមានសហរដ្ឋអាមេរិកជាដើម។ កន្លងមកមានការសង្ស័យថាចិនមានលទ្ធភាពប្រើប្រាស់ឥទ្ធិពលខ្លួន ដើម្បីដាក់ពង្រាយវត្តមានយោធាចិននៅ

[41] សំណុំរឿងEBA៖ សហភាពអឺរ៉ុបដកការអនុគ្រោះពន្ធខ្លះពីកម្ពុជា គិតជាតម្លៃប្រមាណ១ពាន់លានអឺរ៉ូ, 12/02/2020, https://bit.ly/3dmstdj

កម្ពុជា ហើយកម្ពុជាអាចនឹងបាត់បង់អធិបតេយ្យភាព។ ទាំងចិន ទាំងកម្ពុជា សុទ្ធតែបានបដិសេធការសង្ស័យខាងលើ។[42]

## 3. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍធនធានមនុស្ស

នៅក្នុងគោលនយោបាយសំរាប់ការការអភិវឌ្ឍធនធានមនុស្សនេះ ផែនការយុទ្ធសាស្រ្តរាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា
- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ
- ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម

### 3.1. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា

រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា នឹងបន្តដំឡើងប្រាក់បៀវត្ស និងប្រាក់លើកទឹកចិត្តចំពោះគ្រូបង្រៀន និងបុគ្គលិកអប់រំ លើកកម្ពស់សមត្ថភាពក្នុងការងារគ្រប់គ្រង ការងារបង្រៀន និងការស្រាវជ្រាវ។ រាជរដ្ឋាភិបាលនឹងវិនិយោគលើការកសាងសាលាបឋមសិក្សាឲ្យបានដល់គ្រប់ភូមិ និងអនុវិទ្យាល័យឲ្យបានដល់គ្រប់ឃុំ បង្កើនការវិនិយោគអភិវឌ្ឍកុមារតូច និងថ្នាក់មតេយ្យសិក្សា និងបន្តផ្តល់នូវអាហារូបករណ៍សិក្សាដល់សិស្សក្រីក្រ និងជួបការលំបាក។ រាជរដ្ឋាភិបាលនឹងពង្រឹងការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលា និងគុណភាពអប់រំនៅគ្រឹះស្ថានសិក្សាចំណេះទូទៅ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ។

រាជរដ្ឋាភិបាល នឹងយកចិត្តទុកដាក់ការអនុវត្តគោលនយោបាយអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិដើម្បីតំរង់ទិសសិក្សារបស់សិស្សទៅរកអាជីព រៀបចំកម្មវិធីបង្កើនគំនិតសហគ្រិនភាព និងភាសាបរទេស ពង្រឹងការអប់រំផ្នែក STEM តាមរយៈបង្កើតឲ្យមានមជ្ឈមណ្ឌលអប់រំ និងវិទ្យាសាស្រ្ត និងកម្មវិធីបំណិនជីវិត។ រាជរដ្ឋាភិបាលនឹងរៀបចំក្របខណ្ឌកម្មវិធីសិក្សាគ្រប់ជ្រុងតាមរយៈ បន្ថែមមុខវិជ្ជា STEM និងគុណភាព ការទទួលស្គាល់នៅថ្នាក់ឧត្តមសិក្សា មូលនិធិអាហារូបករណ៍ និងឥទានសម្រាប់និសិត្សថ្នាក់ឧត្តមសិក្សា។

រាជរដ្ឋាភិបាលនិងបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាសំខាន់ៗ ប្រភេទកីឡាអាទិភាព ទាំងគ្រូបង្វិក និងកីឡាករ ដើម្បីលើកស្ទួយវិស័យកីឡា និងត្រៀមប្រកួតស៊ីហ្គេម (SEA Games) ឆ្នាំ ២០២៣ ។ រដ្ឋាភិបាលនឹងជំរុញចលនា «យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត»។

---

[42] កិច្ចសន្ទនាពាណិជ្ជកម្មសេរីកម្ពុជា-ចិននាំនូវក្តីសង្ឃឹមនិងក្តីបារម្ភ, <u>អូន ឆេងប៉រ</u>, 28 វិច្ឆិកា 2019, https://bit.ly/2yzlWxh

រយៈពីរបីឆ្នាំកន្លងមកនេះ វិស័យអប់រំក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើងគួរអោយកត់សម្គាល់។ ក្រសួងអប់រំយុវជន និងកីឡា កាន់តែឈានខិតជិតដល់ការសម្រេចបាននូវការផ្តល់សេវាសកលនៃការអប់រំថ្នាក់បឋមសិក្សា តាមរយៈការទទួលបាននូវអាត្រាសិស្សចុះឈ្មោះចូលរៀនចំនួន ៩៧.៧% ក្នុងឆ្នាំ ២០១៦ ។ ប្រទេសកម្ពុជាក៏បានពង្រឹងសមភាពផ្នែកយេនឌ័រក្នុងវិស័យអប់រំផងដែរ ដោយក្នុងនោះមានកុមារីចំនួន ៤៨.២% បានចុះឈ្មោះនៅថ្នាក់បឋមសិក្សា។ ប្រទេសកម្ពុជាបានកសាងនូវសាលារៀនថ្មីចំនួនជិត ១០០០ ខ្នងក្នុងកំឡុងពេលដប់ឆ្នាំកន្លងមកនេះ ហើយបានវិនិយោគធនធានដ៏មានសារៈសំខាន់ជាច្រើន ដើម្បីពង្រីកការទទួលបាននូវសេវាអប់រំប្រកបដោយគុណភាពមួយ។

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងអនុវត្តនូវកំណែទម្រង់វិស័យអប់រំដោយផ្តោតលើសសរស្តម្ភចំនួនប្រាំគឺ ទី១៖ ការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយគ្រូបង្រៀន ទី២៖ ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សា ព្រមទាំងការធ្វើអោយប្រសើរឡើងនូវបរិស្ថានសាលារៀន ទី៣៖ ការធ្វើអធិការកិច្ចទី៤៖ ការពង្រឹងការវាយតម្លៃការសិក្សា និងទី៥៖ ការធ្វើកំណែទម្រង់ការសិក្សាថ្នាក់ឧត្តមសិក្សា។ បើទោះបីជាទទួលបាននូវសមិទ្ធិផលទាំងនេះក៏ដោយ ប្រទេសកម្ពុជាមានអត្រាសិស្សក្នុងថ្នាក់រៀនច្រើនជាងគេក្នុងតំបន់ ហើយមានតែ ៣២% នៃសិស្សស្រីប៉ុណ្ណោះ (៣៨%នៃសិស្សប្រុស) ដែលអាចអាន និងសរសេរភាសាខ្មែរបាន។

ការអប់រំនៅឧត្តមសិក្សា មានការរីកចម្រើន ដូចជាការចូលរៀនរបស់និស្សិតកើនឡើង ព្រមទាំងការកើនឡើងនៃចំនួនគ្រឹះស្ថានឧត្តមសិក្សា ដែលសម្រេចបានតាមបទដ្ឋាននៃការទទួលស្គាល់។ អគ្គនាយកដ្ឋានឧត្តមសិក្សានិងគ្រឹះស្ថានឧត្តមសិក្សាបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ក្នុងការងារកសាងផែនការនិងពិនិត្យតាមដាន ការគ្រប់គ្រងមូលនិធិស្រាវជ្រាវ និងអាហារូបករណ៍ និងមានលទ្ធភាពទាញយកមូលធិនិកាន់តែច្រើនដើម្បីធ្វើការពង្រីកកម្មវិធី។ សកម្មភាពគោលនយោបាយសំខាន់ៗមួយចំនួនដែលត្រូវបានអនុវត្តដូចជាការអនុម័តផែនការគោលស្តីពីការស្រាវជ្រាវ ព្រះរាជក្រឹត្យស្តីពីចំណាត់ថ្នាក់សាស្ត្រាចារ្យ និងការរៀបចំទស្សនៈវិស័យឆ្នាំ ២០៣០ ។ ការបង្កើតក្រុមការងារបច្ចេកទេស ឧត្តមសិក្សា ជាដំណាក់កាលសំខាន់មួយ ក្នុងការបង្កើតវេទិកាមួយសម្រាប់ការជជែក និងពិភាក្សាអំពីបញ្ហានៅកម្រិតឧត្តមសិក្សា ។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមចម្បងនៅក្នុងការអប់រំនៅឧត្តមសិក្សា គឺការដោះស្រាយពីភាពខុសគ្នារវាងតម្រូវការទីផ្សារការងារ ជាពិសេសជំនាញ សមត្ថភាពក្នុងការគិតពិចារណា ចំណេះដឹងជាមួយនិងទីផ្សារការងារនាពេលបច្ចុប្បន្ន។ ការខ្វះខាតសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ ត្រូវបានចាត់ទុកជាចំណុចខ្សោយចំបងក្នុងកម្មវិធីសិក្សានៅមហាវិទ្យាល័យ ដើម្បីផលិតបាននូវធនធានមនុស្សដែលសមស្របទៅតាមតម្រូវការទីផ្សារការងារ។

កត្តានេះទាមទារឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងអំពីទីផ្សារការងារ ការសម្របសម្រួលល្អប្រសើរជាងមុន និងមានតំណភ្ជាប់ជាមួយនឹងវិស័យឧស្សាហកម្ម និងព័ត៌មានកាន់តែប្រសើរឡើងសម្រាប់និស្សិត ដូច្នេះពួកគេអាចជ្រើសរើសវគ្គសិក្សាដែលសមស្រប។ ដើម្បីរក្សាបាននូវកម្មវិធីដែលមានគុណភាព

ខ្ពស់ដែលអាចទទួលស្គាល់ជាអន្តរជាតិ ការកំណត់តម្លៃមួយដែលមានកម្រិតសមរម្យ ក៏ជាបញ្ហាប្រឈមមួយផងដែរ។ ការបង្កើនកិច្ចខិតខំប្រឹងប្រែងនិងការផ្តល់ធនធានបន្ថែមជាកត្តាចាំបាច់ ដើម្បីធានាថា សិស្សដែលមានទេពកោសល្យ និងមកពីក្រុមជួបការលំបាកនឹងអាចចូលសិក្សានៅឧត្តមសិក្សា តាមរយៈកម្មវិធីអាហារូបករណ៍ ឬ គម្រោងប្រាក់កម្ចីសិក្សា។ ការជ្រើសរើសសិស្សទទួលបានអាហាររូបបករណ៍ ក្នុងករណីខ្លះត្រូវបានគេផ្តល់អោយដោយផ្អែកលើភាពទំនាក់ទំនង ដែលមានជាមួយគណបក្សនយោបាយជាពិសេសគណបក្សកាន់អំណាច ច្រើនជាងការខ្វះខាតផ្នែកជីវភាព និងសមត្ថភាពរបស់សិស្សនោះផ្ទាល់។

សម្រាប់ការអប់រំចំណេះទូទៅ សកម្មភាពគោលនយោបាយមួយចំនួនត្រូវបានរៀបចំដូចជា ផែនការគោលស្តីពីការអភិវឌ្ឍមធ្យមសិក្សា និងសៀវភៅប្រតិបត្តិសម្រាប់ដំណើរការមជ្ឈមណ្ឌលធនធានសម្រាប់មធ្យម សិក្សា គោលនយោបាយស្តីពីសាលាកុមារមេត្រីនៅមធ្យមសិក្សា ដែលត្រូវបានបង្កើតក្នុងឆ្នាំ ២០០៧ ដោយក្រសួងអប់រំ យុវជន និងកីឡា[43] និងការកែលម្អកម្មវិធីសិក្សា។ ប្រព័ន្ធវិក្រឹតការគ្រូបង្រៀន លើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រត្រូវបានរៀបចំ។ កម្មវិធីបំណិនជីវិតបច្ចេកវិទ្យា ព័ត៌មាន និងទេសចរណ៍ត្រូវបានអនុម័ត និងស្តង់ដារបណ្ណាល័យនៅមធ្យមសិក្សាកំពុងរៀបចំជាសេចក្តីព្រាង។

យោងលើរបាយការណ៍របស់ក្រសួងអប់រំ ការចូលរៀន និងគុណភាពនៅកម្រិតអប់រំចំណេះទូទៅមានការប្រែប្រួលតិចតួច បើទោះបីជាសកម្មភាពគោលនយោបាយមួយចំនួនត្រូវបានរៀបចំដើម្បីអភិវឌ្ឍវិស័យនេះក៏ដោយ។ អត្រាត្រួតថ្នាក់បានថយចុះ តិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សាមិនមានប្រែប្រួលទេ។ សិស្សភាគច្រើនបានជ្រើសរើសយកមុខវិជ្ជា វិទ្យាសាស្ត្រពិត។ ការប្រឡងថ្នាក់ជាតិនៅថ្នាក់ទី ៩ និងទី ១២ ត្រូវបានអនុវត្តជាទៀងទាត់។

ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើង។ សាលាមធ្យមសិក្សាបឋមភូមិ បានអភិវឌ្ឍទៅជាសាលាមធ្យមសិក្សាទុតិយភូមិ។ មជ្ឈមណ្ឌលធនធាននៅមធ្យមសិក្សាត្រូវបានក៏សាងនៅគ្រប់រាជធានី ខេត្ត។ សាលាមធ្យមសិក្សាបឋមភូមិចំនួន ១៤១ ក្នុងខេត្ត ៨ មានបន្ទប់កុំព្យូទ័រ។ គោលនយោបាយសាលាកុមារមេត្រីត្រូវបានអនុវត្តយ៉ាងហោចណាស់នៅសាលាចំនួន ៨២៣ (៥០,៧៤ ភាគរយនៃសាលាមធ្យមសិក្សាបឋមភូមិ)។

ការអប់រំចំណេះដឹងទូទៅ នៅតែមានបញ្ហាប្រឈមផងដែរ។ ការបង្កើនសមធម៌ក្នុងការចូលរៀននៅមធ្យមសិក្សា តាមរយៈបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិឱ្យបានគ្រប់ឃុំ សង្កាត់និងវិទ្យាល័យនៅគ្រប់ស្រុក ខណ្ឌ។ គុណភាពរបស់សិស្សបញ្ចប់ថ្នាក់ទី ១២ ត្រូវលើកកម្ពស់ និងផ្តល់នូវចំណេះដឹងពាក់ព័ន្ធដទៃទៀត សម្រាប់ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា។ សាលាមធ្យមសិក្សាភាគច្រើន ជាពិសេសនៅតំបន់ជនបទខ្វះខាតធាតុចូលដែលមានគុណភាពដូចជា គ្រូបង្រៀនតាមមុខវិជ្ជា សម្ភារៈបង្រៀននិងគ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រនិងភាសា និងបរិក្ខារបណ្ណាល័យ។

[43] Ministry of Education: Child Friendly Policy, December 2007;

ជំនាញប្រើប្រាស់កុំព្យូទ័រត្រូវការជាចាំបាច់ ស្របពេលដែលសិស្សសាលាវិទ្យាល័យបានឲ្យដឹងថា ពួកគេមិនទាន់ស្ទាត់ជំនាញនឹងការប្រើប្រាស់កុំព្យូទ័រឡើយ។

វិធីសាស្ត្រក្នុងការបង្រៀនក្នុងពេលបច្ចុប្បន្នអនុវត្តតាមរបៀប ជាមេរៀន ចម្លងតាម ដកស្រង់ និងការចងចាំ។ វិធីសាស្ត្រទាំងនេះគួរត្រូវបញ្ចូលនូវការគិត និងជំនាញវិភាគ។ ស្តង់ដារគ្រូបង្រៀនគួរត្រូវពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍជាប្រចាំ ខណៈពេលប្រាក់បៀវត្សរ៍គ្រូបង្រៀនកើនឡើង គេសង្កេតឃើញមានបញ្ហាប្រឈមមួយចំនួនបានកើតឡើងទាក់ទងសមត្ថភាពរបស់ក្រសួងអប់រំក្នុងការធ្វើការធ្វើអធិការកិច្ចអំពីគុណភាពនៃការបង្រៀនផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា បានឲ្យដឹងថា សម្រាប់ការប្រលងមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ ២០១៩ បេក្ខជនប្រឡងជាប់មានចំនួន ៧៩,០៥២ នាក់ ស្មើនឹង ៦៨.៦២ ភាគរយ ធៀបនឹងឆ្នាំ ២០១៨ ដែលអ្នកជាប់មានប្រមាណ ៦៧.០៧ ភាគរយ។ បេក្ខជន ដែលទទួលបាននិទ្ទេស A មានចំនួន ៤៤៣ នាក់ ធៀបនឹងឆ្នាំ ២០១៨ មានតែ ៤០៨ នាក់ និទ្ទេស B មានចំនួន ២.៤៣០នាក់ ធៀបនឹងឆ្នាំ ២០១៨ មានចំនួន ២.២២២ នាក់ និទ្ទេស C មានចំនួន ៥.៨៤៧ នាក់ និទ្ទេស D មានចំនួន ១៤.១០០ នាក់ និងនិទ្ទេស E មានចំនួន ៥៦.២៣២ នាក់។ នៅក្នុងឆ្នាំកន្លងទៅសិស្សនិទ្ទេស A ត្រូវទទួលបានការលើកទឹកចិត្តទាំងផ្នែកស្មារតី និងសំភារៈរួមទាំងថវិកាផ្ទាល់របស់មន្ត្រីរដ្ឋាភិបាលនិងគ្រឹះស្ថានសិក្សានានាផងដែរ។

ដោយឡែកសម្រាប់បឋមសិក្សា កុមារបានចូលរៀននៅបឋមសិក្សាកាន់តែច្រើន និងមិនត្រូវបានវាយតម្លៃថា មានគម្លាតយេនឌ័រនោះទេ។ អត្រាត្រួតថ្នាក់ និងសិស្សបោះបង់ការសិក្សាបានថយចុះ។ គោលនយោបាយសាលាកុមារមេត្រី ត្រូវបានអនុវត្តនៅតាមសាលារៀនភាគច្រើន ហើយជាលទ្ធផលការសិក្សារបស់សិស្សបានល្អប្រសើរ ជាពិសេសមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ដំបូង ស្របពេលដែលគ្រូបង្រៀនជាច្រើននាក់ត្រូវបានបំប៉នអំពី ប្រសិទ្ធភាពនៃការរៀននិងបង្រៀន។

ទោះយ៉ាងណា គម្លាតភូមិសាស្ត្រ និងសាលាបឋមសិក្សាមិនគ្រប់កម្រិតនៅតែជាឧបសគ្គសម្រាប់ការចូលរៀនរបស់កុមារ ជាពិសេសការចូលរៀនត្រឹមត្រូវតាមអាយុកំណត់។ លទ្ធផលសិក្សារបស់សិស្សលើសអាយុទាបជាងសិស្សរៀនត្រឹមត្រូវតាមអាយុ។ ដៃគូអភិវឌ្ឍជាច្រើនបានបន្តផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ការអប់រំនៅបឋមសិក្សា ដែលបានផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍសមត្ថភាពនៅគ្រប់កម្រិត ហើយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល បានអនុវត្តនូវកម្មវិធីផ្តួចផ្តើមមួយចំនួន ដែលនឹងផ្តល់ជាធាតុចូលសម្រាប់ការពិភាក្សាកម្រិតគោលនយោបាយ និងការពង្រីកវិសាលភាពផងដែរ។

សម្រាប់ការអប់រំកុមារតូច គេសង្កេតឃើញមានវឌ្ឍនភាពកើតឡើងច្រើនដោយសារការពង្រីកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មត្តេយ្យក្នុង បឋមសិក្សា មត្តេយ្យឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ តាមខ្នងផ្ទះ។ ទោះជាយ៉ាងណា វិសាលភាពនៃការពង្រីកនេះនៅមានកម្រិតនៅឡើយដោយសារកង្វះធនធានរូបវន្តនិងហិរញ្ញវត្ថុ ព្រមទាំងសមត្ថភាព។ តម្រូវការនិងគុណភាពនៃសេវាអប់រំនៅកម្រិតនេះ នៅមាន

កម្រិត និងមានគម្លាតរវាងទីតាំងភូមិសាស្ត្រមួយទៅភូមិសាស្ត្រមួយទៀត ជាពិសេសនៅតំបន់ដែលមានការចូលរៀននៅបឋមសិក្សាមានកម្រិតទាប និងបោះបង់ការសិក្សាខ្ពស់។ អនុវិស័យនេះបាន ផ្តោតការយកចិត្តទុកដាក់តិចតួចលើបញ្ហា អាហារ-រូបត្ថម្ភ ការគាំពារ វិធីសាស្ត្រអប់រំកុមារពីសំណាក់មាតាបីតា និងសុខភាពរបស់កុមារតូច។

### 3.2. ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

តាមរយៈគោលដៅជាយុទ្ធសាស្ត្រគឺសំដៅថា «យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត» រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥ តាមរយៈកិច្ចសហការរវាងសាលា និងសហគ្រាស។ រដ្ឋាភិបាលនឹងបន្តរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ ដើម្បីចូលរួមគាំទ្រការអភិវឌ្ឍវិស័យឧស្សាហកម្ម និងបន្តអនុវត្តសកម្មភាពតម្រង់ទិសវិជ្ជាជីវៈនៅគ្រឹះស្ថានអប់រំចំណេះទូទៅ។

នៅខែមិថុនាឆ្នាំ ២០១៧ រដ្ឋាភិបាលបានអនុម័តលើគោលនយោបាយអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ឆ្នាំ ២០១៧-២០២៥ របស់កម្ពុជាដែលអាចត្រូវបានប្រើជាមគ្គុទេសក៍សម្រាប់ការបង្កើត និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជំនាញនៅក្នុងប្រទេស។[44] តាមរយៈការអនុវត្តន៍គោលនយោបាយនេះ វាត្រូវបានគេរំពឹងទុកថា សិស្សដែលបញ្ចប់ការសិក្សានៅសាលាទាំងនេះ អាចរកការងារបាន។

គោលនយោបាយនេះត្រូវបានប្រើជាការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជំនាញ និងជួយសម្រួល ឲ្យមានទំនក់ទំនងកាន់តែប្រសើរឡើង ចំពោះអង្គពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញនៅកម្ពុជា។ គោលនយោបាយនេះត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយមានគោលដៅនៃការផ្លាស់ប្តូរ និងធ្វើទំនើបកម្មចំពោះប្រព័ន្ធអភិវឌ្ឍន៍ជំនាញនៅកម្ពុជា ដើម្បីយកទៅប្រើប្រាស់ឲ្យកាន់ប្រសើរឡើងចំពោះកម្លាំងពលកម្មថ្មី និងកម្មករពេលបច្ចុប្បន្ន និងការអភិវឌ្ឍនាពេលអនាគតរបស់ប្រទេសកម្ពុជា។[45] ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រីឯក្រសួងផ្សេងៗទៀតដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចការនារី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏មានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរបស់ក្រសួងផ្ទាល់ដែលត្រូវបានបង្កើតឡើង ដោយផ្អែកលើតម្រូវការជាក់លាក់។

[44] ASEAN Development Bank: Cambodia’s New Technical and Vocational Training Policy; February 2018; https://www.adb.org/publications/cambodia-new-tvet-policy
[45] ASEAN Development Bank: Cambodia’s New Technical and Vocational Training Policy; February 2018; https://www.adb.org/publications/cambodia-new-tvet-policy

ក្រសួងបានលើកឡើងថា " នៅចុងឆ្នាំ ២០១៩ ក្រសួងនឹងរៀបចំផែនការមេដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធ មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) នៅទូទាំងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ កម្មវិធីអប់រំបច្ចេកទេសដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន មិនទាន់ត្រូវបានគេវាយតម្លៃថាធានាបាននូវគុណភាពគ្រប់គ្រាន់នៅឡើយ ហើយការទំនាក់ទំនងរវាងប្រព័ន្ធអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីផ្សារការងារនៅមានកម្រិត។ កង្វះខាតធនធានមនុស្សដែលទទួលបានការបណ្តុះបណ្តាល តាមរយៈកម្មវិធី TVET និងការខ្វះខាតការវិភាគបែបទិន្នន័យសម្រាប់តម្រូវការទីផ្សារការងារ ត្រូវបានចាត់ទុកជាបញ្ហាប្រឈមក្នុងកម្មវិធី TVET[46].

កម្មវិធី TVET ក៏ត្រូវបានរារាំងដោយសារកង្វះសិស្សដែលចាប់អារម្មណ៍ចំពោះការបណ្តុះបណ្តាលផ្នែកជំនាញ។ សិស្សភាគច្រើនបានបន្តការសិក្សាថ្នាក់សាកលវិទ្យាល័យ ឬក៏បានស្វែងរកការងារធ្វើ ជាជាងការចូលរៀននៅក្នុងសាលា ឬគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ បន្ទាប់ពីពួកគេបានបញ្ចប់ ឬបោះបង់ការសិក្សាចំណេះដឹងទូទៅ។

### 3.3. ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ

រដ្ឋាភិបាលនឹងលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសមធម៌នៃសេវាសុខភាពតាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០ ។ រដ្ឋាភិបាលនឹងបង្កើនវិសាលភាពគ្រប់ដណ្តប់នៃមូលនិធិសមធម៌សុខាភិបាល បន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដោយបញ្ចូលបុគ្គលស្វ័យនិយោជន៍ក្នុងរបបនេះផង។ រដ្ឋាភិបាលនឹងដាក់ឲ្យដំណើរការកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃ និងកុមារអាយុក្រោម ២ ឆ្នាំក្នុងគ្រួសារក្រីក្រ។

រដ្ឋាភិបាលនឹងបង្កើនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល និងបច្ចេកទេសវិជ្ជសាស្ត្រ និងពង្រឹងសមត្ថភាពការងារអធិការកិច្ច និងលើកកម្ពស់ សមត្ថភាព និងការស្រាវជ្រាវសុខាភិបាល។ រដ្ឋាភិបាលនឹងពង្រឹងការអនុវត្តច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងការប្រើប្រាស់ឱសថ សារធាតុគីមី គ្រឿងស្រវឹង និងថ្នាំជក់។ រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តវិធានការទប់ស្កាត់ បង្កា និងកាត់បន្ថយជម្ងឺ តាមរយៈការអប់រំផ្សព្វផ្សាយ។

ក្នុងឆ្នាំ ២០១៩ នេះរាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភប្រាក់ដល់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ដើម្បីលើកកម្ពស់អាហារូបត្ថម្ភ និងជំរុញដល់ការលូតលាស់កាយសម្បទា និងបញ្ញាស្មារតីដល់គ្រួសារក្រីក្រ។ កម្មវិធីឧបត្ថម្ភនេះផ្តល់ប្រាក់ឧបត្ថម្ភនេះដល់ស្ត្រីមានផ្ទៃពោះនៃគ្រួសារក្រីក្រដែលមានប័ណ្ណសមធម៌ និងមានប័ណ្ណ Post-ID របស់ក្រសួងសុខាភិបាល ទោះបីជាស្ត្រីនោះជាកម្មករនិយោជិតក៏ដោយ។ ស្ត្រីមានផ្ទៃពោះក្រីក្រនឹងទទួលបានប្រាក់ ក្នុងដំណាក់កាលទី១ ចំនួន ៤០.០០០ រៀល ក្នុងមួយដង នៅពេលមកពិនិត្យផ្ទៃពោះ ៤ ដង មុនពេលសម្រាលកូន។ ដំណាក់កាលទី ២ គឺទទួល

[46] Ibid...

បាន ២០០.០០០ រៀល ក្នុង ១ ដងគត់នៅពេលសម្រាលកូន និងដំណាក់កាលទី៣ ទទួលបាន ៤០.០០០ រៀល ក្នុង ១ ដង នៅពេលមកពិនិត្យសុខភាពក្រោយពេលសម្រាលកូន ៤ ដង និង ៦ ដង ចុងក្រោយនៅពេលនាំកូនមកចាក់ថ្នាំបង្ការក្នុង ១ លើកៗរហូតដល់កូនអាយុ ២ ឆ្នាំ។[47] នៅឆ្នាំ ២០១៩ មូលនិធិសម្រាប់ទ្រទ្រង់ស្ត្រីមានផ្ទៃពោះ ត្រូវបានផ្ទេរពីមណ្ឌលសុខភាពទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលទទួលបន្ទុកការងារស្ត្រី និងកុមារ ជាអ្នកគ្រប់គ្រង និងអនុវត្ត។ ជាលទ្ធផល ក្នុងរយៈពេលឆ្នាំចុងក្រោយនេះ ដំណើរការទទួលបាននូវថវិការនេះត្រូវបានគេរិះគន់ថាមានភាពយឺតយ៉ាវ និងចំណាយពេលយូរ។

ពាក់ព័ន្ធនឹងបញ្ហាខាងលើ សង្គមស៊ីវិលដែលលើកស្ទួយសិទ្ធិស្ត្រីយល់ថា បើកម្មវិធីនេះដំណើរការនោះតើស្ត្រីទាំងនោះនឹងប្រើប្រាស់ថវិកាបានត្រឹមត្រូវក្នុងរបបចំណីអាហារនោះទេ ក្នុងករណីគ្រួសារនោះមានអំពើហិង្សា ផលប៉ះពាល់ពីគ្រឿងស្រវឹង និងជាប់បំណុល។ ដើម្បីនាធាបាននូវប្រសិទ្ធភាពខ្ពស់ រដ្ឋាភិបាលគួរ ពង្រឹងសេវាសុខភាពនៅតាមមណ្ឌលសុខភាព ដោយសារមណ្ឌលសុខភាពមិនទាន់បានផ្តល់ឱ្យទៅតាមអ្វីដែលប្រជាពលរដ្ឋចង់បានទេ។

នៅចុងឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានគ្រោងចំណាយថវិកាសរុបចំនួន ៨៣ លានដុល្លារ ដើម្បីធ្វើទំនើបកម្មមន្ទីរពេទ្យកាល់ម៉ែតនៅរាជធានីភ្នំពេញឲ្យក្លាយទៅជាមន្ទីរពេទ្យបង្អែករបស់ជាតិ។ ថវិកានេះជួយដល់មន្ទីរពេទ្យក្នុងការបន្តការសាងសង់អគារកម្ពស់ ១២ ជាន់ដែលមន្ទីរពេទ្យនេះកំពុងដំណើរការសាងសង់បាន ១៧ ភាគរយលើគម្រោងដែលមានស្រាប់ ៣៩ លាន ៧ សែនដុល្លារ។[48] អ្វីដែលជាការកត់សម្គាល់នោះ ថវិកាប្រមាណ ៥៣ លានដុល្លារនៃថវិកាសរុប គឺបានកមពីការចូលរួមរបស់សប្បុរសជន ក្រោយមានការអំពាវនាវរបស់លោកនាយករដ្ឋមន្ត្រីដែលបានវាយតម្លៃថា មន្ទីរពេទ្យក៏ដូចជាក្រសួងសុខាភិបាលខ្វះលទ្ធភាពខាងថវិកាសម្រាប់ការសាងសង់អគារថ្មី និងទិញសម្ភារសម្រាប់បំពាក់ទាំងអគារថ្មី និងអគារដែលមានរួចមកហើយ។

ទោះបីមានការខិតខំទាំងនេះក្តី ប្រព័ន្ធគាំពារសុខភាពនៅកម្ពុជា នៅតែមិនអាចទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋមានជីវភាពធូរធារ និងមធ្យម បានបង្ហាញនូវការជឿទុកចិត្តខ្ពស់ចំពោះសេវាផ្នែកថែទាំសុខភាពពីប្រទេសជិតខាងដូចជា ប្រទេសថៃ និងប្រទេសវៀតណាម។ នៅឆ្នាំ ២០១៦ ប្រជាពលរដ្ឋកម្ពុជាប្រមាណពី ២៤% ទៅ ៣០% នៃចំនួន ១,២ ទៅ ១,៤ លាននាក់ បានទៅប្រទេសថៃ និងប្រទេសវៀតណាមក្នុងគោលបំណងទទួលបានសេវាពិនិត្យសុខភាព និងព្យាបាលសុខភាព។ តាមរយៈការដកស្រង់សម្តីរបស់លោក Jiaranai Boonprasatsuk ប្រធានផ្នែកទីផ្សារ នៃមជ្ឈមណ្ឌលបេះដូង នៅ

[47] ស្ត្រីមានផ្ទៃពោះ និងកុមារក្រីក្រនឹងទទួលបានថវិកាពីរដ្ឋាភិបាលនៅខែមិថុនាខាងមុខ, កែវ សុខា, ថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០១៩, https://bit.ly/2L68fsj

[48] លោក ហ៊ុន សែន ផ្តល់ថវិកា ៨៣ ដុល្លារលាន បន្ថែមលើការសាងសង់ និងធ្វើទំនើបកម្មមន្ទីរពេទ្យកាល់ម៉ែត, សុទ្ធ គឹមសឿន,26 November 2019, https://bit.ly/2yxOd7i

មន្ទីរពេទ្យ Phyathai 2 ក្នុងទីក្រុងបាងកក " ប្រជាពលរដ្ឋកម្ពុជាជាប់ចំណាត់លេខ ១ ក្នុងចំនួនច្រើនជាងគេនៃអ្នកជម្ងឺបរទេសដែលទទួលការព្យាបាលនៅមន្ទីពេទ្យនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ"[49] ។

លើសពីនេះទៀត ក្រុមគ្រួសារអ្នកមានទ្រព្យស្តុកស្តម្ភ និងក្រុមគ្រួសារនៃមន្ត្រីរដ្ឋាបាលមានឋានៈខ្ពស់ តែងតែទៅទទួលយកការត្រួតពិនិត្យ និងការព្យាបាលសុខភាពរបស់ពួកគេនៅក្នុងប្រទេសសិង្ហបុរី ឬបណ្តាប្រទេសលោកខាងលិច។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ មេដឹកនាំកម្ពុជារួមទាំងព្រះមហាក្សត្រនរោត្តមសីហមុនី បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំងដើម្បីពិនិត្យសុខភាព ដោយឡែកលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើដំណើរទៅ ប្រទេសសិង្ហបុរីដើម្បីពិនិត្យសុខភាព ជាទៀងទាត់។[50] ការអនុវត្តបែបនេះបង្ហាញថាការខ្វះទំនុកចិត្តចំពោះប្រព័ន្ធថែទាំសុខភាពនៅកម្ពុជាមិនត្រឹមតែកើតមានក្នុងចំណោមប្រជាជនទូទៅប៉ុណ្ណោះទេ ប៉ុន្តែវាក៏ត្រូវបានបង្ហាញដោយថ្នាក់ដឹកនាំរដ្ឋាភិបាល ផងដែរ។

### 3.4. ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម

រាជរដ្ឋាភិបាលមានគោលដៅយុទ្ធសាស្ត្រមួយគឺការពង្រឹងសមាសភាពយេនឌ័រ និងការគាំពារសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គម-សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ ក្នុងនីតិកាលទី៦ នេះ រាជរដ្ឋាភិបាលនឹងបន្តលើកកំពស់តួនាទីស្ត្រីតាមរយៈការបង្កើនសមាមាត្រ និងពង្រឹងសមត្ថភាពស្ត្រីក្នុងជួរថ្នាក់ដឹកនាំ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងកម្រិតនយោបាយ និងកម្រិតជំនាញ។ អ្វីគួរកត់សម្គាល់នោះ គឺចំនួនស្ត្រីក្នុងសមាសភាពគណរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលបានកើនឡើងក្នុងអំឡុងពេល ២ នីតិកាលចុងក្រោយនេះ។ រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានលើកឡើងថា «រដ្ឋមន្ត្រីជាស្ត្រីបានកើនឡើងពីសូន្យ ដល់ចំនួន ៣ រដ្ឋលេខាធិការជាស្ត្រីកើនដល់ចំនួន ៥៣ នៅត្រឹមឆ្នាំ២០១៩ ចំណែកអនុរដ្ឋលេខាធិការជាស្ត្រីបានកើនលឡើងពីចំនួន ២ រូប ដល់ ៧០ រូបក្នុងរយៈពេលដូចគ្នា។ បន្ថែមលើសពីនេះទៀត មកដល់ពេលបច្ចុប្បន្ន មានអភិបាលខេត្តជាស្ត្រីមួយរូប និងអភិបាលរងខេត្ត/រាជធានីជាស្ត្រីចំនួន ២៦ រូប ហើយមានអភិបាលក្រុង/ស្រុកជាស្ត្រីចំនួន ៦ រូប និងអភិបាលរងក្រុង/ស្រុកជាស្ត្រីចំនួន ១៩៤ រូប។[51]

ដោយធ្វើបច្ចុប្បន្នភាព និងអនុវត្ត«ផែនការយុទ្ធសាសស្រ្តនារីរតនៈ» រាជរដ្ឋាភិបាលជំរុញការប

---

[49] Cambodia's Medical System is Due for a Check Up; Phnom Penh Post, Wednesday, 10 July 2019;

[50] [50] PM's Medical Trip Raises Doubts Over Cambodia Health Care, By Lauren Crothers, 23.01.2016, Phnom Penh, Cambodia. https://www.aa.com.tr/en/todays-headlines/pm-s-medical-trip-raises-doubts-over-cambodia-health-care/509415

[51] Phnom Penh Post: Calls for more women in leadership positions, by Niem Chheng, 12 Mach 2020; ; https://www.phnompenhpost.com/national/calls-more-women-leadership-positions?

ញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍គ្រប់ផ្នែក គ្រប់វិស័យ និងគ្រប់កម្រិត លើកកម្ពស់សហគ្រិនភាពស្ត្រី និងលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី សំដៅទប់ស្កាត់ការជួញដូរ និងអំពើហឹង្សាលើស្ត្រី និងកុមារ។

ក្នុងកិច្ចការពារសង្គម រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្ត«ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ » ដោយដាក់ឲ្យដំណើរការរបបហានិភ័យការងារមន្ត្រីសាធារណៈ និងរបបសោធនសម្រាប់កម្មករនិយោជិតក្រោមច្បាប់ការងារ ព្រមទាំងការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ និងគោលនយោបាយជាតិស្តីពីមនុស្សចាស់ ២០១៧-២០៣០ ។

## 4. គោលនយោបាយ និងការធានាអាទិភាព នៃការធ្វើពិពិធកម្មសេដ្ឋកិច្ច

នៅក្នុងគោលនយោបាយសំរាប់ការការធ្វើពិពិធកម្មសេដ្ឋកិច្ច ផែនការយុទ្ធសាស្ត្ររាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល
- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ
- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តឧស្សាហកម្មទី ៤
- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ

### 4.1. កែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

រាជរដ្ឋាភិបាលបានប្រឹងប្រែងកែលម្អហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការតភ្ជាប់ផ្នែកដឹកជញ្ជូនដោយធ្វើសមាហរណកម្មផ្ទៃក្នុងប្រទេស ការពង្រីកវិសាលភាពនៃការតភ្ជាប់ផ្នែកថាមពល និងការតភ្ជាប់ផ្នែកឌីជីថល។ ក្នុងនីតិកាលទី៦ រាជរដ្ឋាភិបាលនឹងអនុម័ត និងអនុវត្តផែនការមេសម្រាប់ដឹកជញ្ជូនពហុមធ្យោបាយ និងឡូជីស្ទីកដើម្បីបង្កើនល្បឿនសមាហរណកម្ម ការតភ្ជាប់ប៉ូលសេដ្ឋកិច្ចសំខាន់ៗ និងអភិវឌ្ឍរបៀងសេដ្ឋកិច្ចគន្លឹះនៅក្នុងតំបន់ និងពិភពលោក។ រាជរដ្ឋាភិបាល នឹងស្តារកសាង និងអភិវឌ្ឍនហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ទាំងផ្លូវគោក ស្ពាន ផ្លូវដែក ផ្លូវទឹក និងផ្លូវអាកាសព្រមទាំងផ្លូវល្បឿនលឿន តាមរយៈបន្តបង្កើនថវិកាវិនិយោគ និងកៀរគរហិរញ្ញប្បទាន។

រាជរដ្ឋាភិបាលនឹងបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រឹងបណ្តាញគ្រប់ដណ្តប់ និងបង្កើនស្ថិរភាពអគ្គិសនីដោយសាងសងអនុស្ថានីយ៍បន្ថែម ឲ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់ និងបន្តអភិវឌ្ឍការតភ្ជាប់ផ្នែកឌីជីថល តាមរយៈការពង្រឹង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកជាបណ្តាញចែកចាយហេដ្ឋារចនាសម្ព័ន្ធខ្សែកាប្លិ៍អុបទិកឆ្អឹងខ្នង និងខ្សែកាប្លិ៍អុបទិកបាតសមុទ្រ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទូរស័ព្ទចល័ត។

សម្រាប់ឆ្នាំទី ១ នៃនីតិកាលទី៦ រាជរដ្ឋាភិបាលបានបន្តកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ តាមរបាយការណ៍របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងរយៈពេលពីខែកញ្ញា ឆ្នាំ ២០១៨ ដល់ ខែសីហា ឆ្នាំ ២០១៩ រាជរដ្ឋាភិបាលបានជួសជុល និងកសាងផ្លូវថ្នល់ចំនួន ៨០៩,៨៩ គ.ម ដែលក្នុងនោះផ្លូវបេតុងមានប្រវែង ៣០,៧៩ គ.ម ផ្លូវប្រភេទ AC មានប្រវែង ៨,៩៦ គ.ម ផ្លូវប្រភេទ DBST មានប្រវែង ៤០៤,៥៥ គ.ម និងផ្លូវគ្រោះក្រហម មានប្រវែង ៣៦៥,៥៩ គ.ម។ ចំណែកការងារកសាង និងជួសជុលស្ពានលូវិញ ក្នុងរយៈពេលដូចគ្នា រាជរដ្ឋាភិបាលសម្រេចបាន ៣២.១៩៩,៧៩ ម៉ែត្រ ដែលក្នុងនោះស្ពានបេតុងមានប្រវែង១.៣៦០ ម ប្រឡាយមានប្រវែង ១៤.៤៧៤ ម លូមូលមានប្រវែង១៥៧១០ម និងលូជ្រុងមានប្រវែង ៦៥៥,៧៩ ម។

នៅចុងឆ្នាំ ២០១៨ រាជរដ្ឋាភិបាលបានប្រកាសពីការបញ្ចុះតម្លៃអគ្គិសនីសម្រាប់ឆ្នាំ ២០១៩ និង ២០២០ ដើម្បីសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋមួយកម្រិតទៀត ដែលស្របតាមចក្ខុវិស័យរបស់រដ្ឋាភិបាល ក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។[52] តម្លៃប្រើប្រាស់អគ្គិសនីនៅក្នុង ត្រូវបានបញ្ចុះថ្លៃទៅតាមប្រភេទនៃការប្រើប្រាស់នីមួយ។ ការបញ្ចុះថ្លៃអគ្គិសនីនេះមាន ៦ ប្រភេទដូចខាងក្រោម៖

| គោលដៅនៃការកាត់បន្ថយថ្លៃអគ្គិសនី | ថ្លៃកំពុងអនុវត្ត ២០១៨ | អត្រាថ្លៃដែលត្រូវបន្ថយ នៅឆ្នាំ ២០១៩ | អត្រាថ្លៃដែលត្រូវបន្ថយ នៅឆ្នាំ ២០២០ |
|---|---|---|---|
| ១.អ្នកប្រើប្រាស់ធំគ្រប់ប្រភេទ ទិញពីអនុស្ថានីយ ៖ | | | |
| - ទិញតាមទ្វារចរន្តតង់ស្យុងខ្ពស់ | 0,1240$/kwh (៥០៣៛) | 0,1170$/kwh (៤៧៤៛) | 0,1170$/kwh (៤៧៤៛) |
| - ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយក្នុងភ្នំពេញ | 0,1475$/kwh (៥៩៨៛) | 0,1350$/kwh (៥៤៧៛) | 0,1330$/kwh (៥៣៩៛) |
| - ទិញតាមទ្វារចរន្តតង់ស្យុងមធ្យមតាមនុស្ថានីយតាមខេត្ត | 0,1260$/kwh (៥១១៛) | 0,1220$/kwh (៤៩៤៛) | 0,1220$/kwh (៤៩៤៛) |
| ២.អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្មដែលទិញតាមខ្សែបណ្តាញរង និងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | - នៅ ភព 0,1650$/kwh (៦៧៦៛)<br>- នៅខេត្ត 0,1640$/kwh (៦៧២៛) | 0,1470$/kwh (៥៩៦៛) | 0,1460$/kwh (៥៩២៛) |
| ៣.អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម និងរដ្ឋបាល ដែលទិញតាមខ្សែបណ្តាញរង និងតាមខ្សែតង់ស្យុងមធ្យមនៃតំបន់ចែកចាយ | - នៅ ភព 0,1650$/kwh (៦៧៦៛)<br>- នៅខេត្ត 0,1640$/kwh (៦៧២៛) | 0,1590$/kwh (៦៤៤៛) | 0,1580$/kwh (៦៤០៛) |
| ៤.ប្រជាពលរដ្ឋប្រើប្រាស់ជាប្រភេទលំនៅឋាន | | | |
| - លំនៅឋានប្រើពី ១ ដល់ ១០ kwh ក្នុង ១ ខែ | - ភព ៦១០៛, ខេត្ត ៤៨០៛/kwh | ៣៨០៛/kwh | ៣៨០៛/kwh |
| - លំនៅឋានប្រើពី ១១ ដល់ ៥០ kwh ក្នុង ១ ខែ | - ទូទាំងប្រទេស ៦១០៛/kwh | ៤៨០៛/kwh | ៤៨០៛/kwh |
| - លំនៅឋានប្រើពី ៥១ ដល់ ២០០ kwh ក្នុង ១ ខែ | - ភព ៧២០៛, ខេត្ត ៧៧០៛/kwh | ៦១០៛/kwh | ៦១០៛/kwh |
| - លំនៅឋានប្រើលើសពី ២០០ kwh ក្នុង ១ ខែ | - ភព ៧៥០៛, ខេត្ត ៧៧០៛/kwh | ៧៤០៛/kwh | ៧៣០៛/kwh |
| ៥.ទិញសម្រាប់បូមទឹកធ្វើកសិកម្ម ពី ម៉ ៩ យប់ ដល់ ម៉ ៧ ព្រឹក | ៤៨០៛/kwh | ៤៨០៛/kwh | ៤៨០៛/kwh |
| ៦.សាលារៀន, មន្ទីរពេទ្យ និង មណ្ឌលសុខភាព | ៧៧០៛/kwh | ៦១០៛/kwh | ៦១០៛/kwh |

កំណត់សម្គាល់ «ភព» មានន័យថា ភ្នំពេញ, "kwh" មានន័យថា គីឡូវ៉ាត់ម៉ោង, ថ្លៃជារៀលនៅក្នុងវង់ក្រចក គឺជាថ្លៃគណនាពីអត្រាថ្លៃគោល តាមអត្រាប្តូរប្រាក់ ១ ដុល្លារ ស្មើនឹង ៤១០០ រៀល ។

[52] រាជរដ្ឋាភិបាលនឹងបញ្ចុះតម្លៃអគ្គិសនី ជាបន្តបន្ទាប់នៅឆ្នាំខាងមុខ ជាមួយផែនការឲ្យគ្រប់ភូមិរបស់ប្រជាពលរដ្ឋ មានអគ្គិសនីប្រើប្រាស់យ៉ាងយូរឆ្នាំ ២០២០!, https://bit.ly/35E4Gmx

នៅចុងឆ្នាំ២០១៨ដែរ រាជរដ្ឋាភិបាលបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីសេសានក្រោម២ នៅខេត្តស្ទឹងត្រែង ដែលមានថាមពលអនុភាព ៤០០ មេហ្គាវ៉ាត់។ វារីអគ្គិសនី ជាការវិនិយោគរួមគ្នារវាងក្រុមហ៊ុនចំនួនបី រួមមានក្រុមហ៊ុន Hydrolancang International Energy របស់ចិន ៥១ ភាគរយ ក្រុមហ៊ុន Royal Group របស់ខ្មែរ ៣៩ ភាគរយ និងក្រុមហ៊ុន EVNI របស់វៀតណាម ១០ ភាគរយនៃទុនវិនិយោគសរុបជិត ៨០០ លានដុល្លារអាមេរិក។ ការវិនិយោគនេះតាមរូបភាពសាងសង់-ដំណើរការ-ផ្ទេរ (BOT) មានរយៈពេលសម្បទាន៤៥ឆ្នាំ ដែលក្នុងនោះរយៈពេល៥ឆ្នាំសម្រាប់ដំណើរការសាងសង់ និង៤០ឆ្នាំ សម្រាប់ធ្វើអាជីវកម្ម។[53]

ទាក់ទងនឹងតម្រូវការប្រើប្រាស់អគ្គិសនី នៅខែកញ្ញា ឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចព្រមព្រៀងទិញថាមពលអគ្គិសនីសរុប ២៩០០ មេហ្គាវ៉ាត់ ពីប្រទេសឡាវ ដើម្បីបំពេញកង្វះខាតអគ្គិសនីនាពេលបច្ចុប្បន្ន និងដើម្បីបញ្ចុះថ្លៃអគ្គិសនីនាពេលអនាគត។ ការទិញថាមពលអគ្គិសនីសរុប ២៩០០ មេហ្គាវ៉ាត់ ដែលប្រើប្រាស់ទំហំទុនសរុបចំនួន ៤៩៧០ លានដុល្លារអាមេរិក និងមានអាណត្តិនៃកិច្ចព្រមព្រៀងទិញលក់អគ្គិសនីរយៈពេល៣០ឆ្នាំ រួមមាន ៖ ការនាំចូលអគ្គិសនីអនុភាព ៥០០ មេហ្គាវ៉ាត់ ពីវារីអគ្គិសនីអាត់តាពើ ការទិញពីក្រុមហ៊ុន TSBP SEKONG POWER AND MINERAL COMPANY LIMITED អនុភាព៦០០ មេហ្គាវ៉ាត់ និងការទិញពីក្រុមហ៊ុន XEKONG THERMAL POWER PLANT COMPANY LIMITED អនុភាព១៨០០ មេហ្គាវ៉ាត់។[54]

គម្រោងទិញអគ្គិសនីនេះ ត្រូវបានរាជរដ្ឋាភិបាលឲ្យដឹងថា នឹងផ្តល់អត្ថប្រយោជន៍ចំពោះប្រទេសកម្ពុជាដោយទទួលបានថ្លៃអគ្គិសនីតត្រឹមតែ ៧,៧ សេនដុល្លារអាមេរិក/គីឡូវ៉ាត់ម៉ោងប៉ុណ្ណោះ ដែលនេះជាតម្លៃទាបធៀបនឹងបណ្តារោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មផ្សេងទៀតនៅកម្ពុជា។ ហើយគម្រោងនេះនឹង ជួយកាត់បន្ថយការទិញថាមពលអគ្គិសនីតម្លៃខ្ពស់ពីប្រទេសវៀតណាម និងប្រទេសថៃនាពេលបច្ចុប្បន្ន ក៏ដូចជានឹងជួយធានាបានការផ្គត់ផ្គង់ថាមពលបន្ថែមដល់ប្រព័ន្ធអគ្គិសនីជាតិឲ្យមានស្ថិរភាព ជាពិសេសនៅរដូវប្រាំង។ ជាមួយគ្នានេះដែរ គម្រោងនេះ នឹងផ្តល់លទ្ធភាពឲ្យរាជរដ្ឋាភិបាលកម្ពុជាវិនិយោគលើការសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ៥០០ គីឡូវ៉ុលថ្មីបន្ថែមទៀត ដែលនេះនឹងអនុញ្ញាតឲ្យប្រទេសកម្ពុជាអាចទិញថាមពលដែលមានតម្លៃទាបសមរម្យពី បណ្តុំស្ថានីយវារីអគ្គិសនីផ្សេងៗទៀត នៅភាគខាងត្បូងនៃប្រទេសឡាវ។

នៅខែមេសា ឆ្នាំ ២០១៩ អំឡុងដំណើរទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់ទីក្រុងប៉េកាំង រដ្ឋាភិបាលកម្ពុជាបានចុះអនុស្សារណៈនៃការយោគយល់មួយជាមួយក្រុមហ៊ុន Huawei ដើម្បីបើកផ្លូវឱ្យសាជីវកម្មខ្នាតធំរបស់ចិនមួយនេះជួយកសាងហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាទូរគមនា គមន៍5G នេះនៅកម្ពុជា[55] ខណៈដែលការប្រកួតប្រជែងជាសាកលលើបច្ចេកវិទ្យាទូរគមនាគមន៍ 5G នេះកំពុងមានការ

---

[53] សម្តេចតេជោ ហ៊ុន សែន អញ្ជើញសម្ពោធវារីអគ្គិសនីសេសានក្រោម២នៅខេត្តស្ទឹងត្រែង, 17 ធ្នូ, 2018, https://pressocm.gov.kh/archives/40741

[54] កម្ពុជាសម្រេចអនុម័តទិញថាមពលអគ្គិសនី ២៩០០ មេហ្គាវ៉ាត់ ពីឡាវ, ១២ កញ្ញា ២០១, https://bit.ly/3bd138e

[55] កម្ពុជា-Huawei ចុះកិច្ចព្រមព្រៀងលើការប្រើប្រាស់ 5G មុនគេក្នុងតំបន់អាស៊ាន, ច័ន្ទ, 29 មេសា 2019 09:44, https://kleykley.sabay.com.kh/article/1137337

កើនឡើង។ តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជាត្រូវបានរំពឹងទុកថានឹងក្លាយជាប្រទេសដំបូងគេក្នុងតំបន់អាស៊ាន ដែលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត 5G នេះ។

ពាក់ព័ន្ធនឹងការរីកចំរើនផ្នែកបច្ចេកវិទ្យារបស់ចិនតាមរយៈក្រុមហ៊ុន Huawei សហរដ្ឋអាមេរិក និងបណ្តាប្រទេសជាសម្ព័ន្ធមិត្តរបស់ខ្លួន បានដាស់តឿនបណ្តាប្រទេសក្នុងសកលលោកឱ្យប្រយ័ត្នប្រយែងក្នុងការចាប់ដៃគូកសាងបណ្តាញអ៊ីនធឺណិតជំនាន់ថ្មីលឿនរហ័សនេះ ជាមួយនឹងក្រុមហ៊ុន Huawei ដែលត្រូវបានសង្ស័យថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ នឹងរដ្ឋាភិបាលចិនកុម្មុយនីស្ត និងស្ថាប័នយោធានិងចារកម្មប្រទេសចិន។

គួរបញ្ជាក់ផងដែរថាតាមរយៈកាសែត Daily Telegraph របស់អង់គ្លេសបានចេញផ្សាយទិន្នន័យឯកសារធនធានមនុស្សរបស់ ក្រុមហ៊ុន Huawei ហើយរកឃើញថា បណ្តាបុគ្គលិកមួយចំនួនដែលបម្រើការឱ្យក្រុមហ៊ុននេះ មានការងារនៅក្នុងជួរកងទ័ពរំដោះប្រជាជនចិន ក្រសួងសន្តិសុខរដ្ឋ ដែលជាមន្ទីរចារកម្មធំបំផុតរបស់ចិន និងខ្លះទៀតធ្លាប់ជាប់ពាក់ព័ន្ធនឹងអង្គភាពដែលមានប្រវត្តិធ្លាប់វាយប្រហារតាមអ៊ីនធឺណិតលើសហរដ្ឋអាមេរិកថែមទៀតផង។[56]

ពាក់ព័ន្ធនឹងបញ្ហាខាងលើ នៅខែកក្កដា ក្រុមហ៊ុនទូរស័ព្ទចល័តនាំមុខមួយនៅកម្ពុជា គឺក្រុមហ៊ុនស្មាត (Smart) បានបង្ហាញការសាកល្បងប្រព័ន្ធបណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ជំនាន់ទី៥ ឬ 5G របស់ខ្លួនជាសាធារណៈដោយចាប់ដៃគូជាមួយក្រុមហ៊ុន Huawei ដែលជាក្រុមហ៊ុនផលិតទូរស័ព្ទមកពីប្រទេសចិន។ លោក Thomas Hundt នាយកប្រតិបត្តិក្រុមហ៊ុន Smart Axiata បានលើកឡើងថាការសាកល្បងនូវប្រព័ន្ធអ៊ីនធឺណិត 5G នេះបានបង្ហាញពីការវិវត្តជឿនលឿនផ្នែកឧស្សាហកម្ម និងសេដ្ឋកិច្ច ហើយលោកថា ក្រុមហ៊ុនលោកគ្រោងនឹងបោះទុនវិនិយោគប្រាក់រាប់រយលានដុល្លារ លើបណ្តាញបច្ចេកវិទ្យាទូរគមនាគមន៍ជំនាន់ទី៥ នេះ។

### 4.2. ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ

រាជរដ្ឋាភិបាលនឹងការបន្តជំរុញការអនុវត្ត «គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥» ពិសេសជំរុញការអភិវឌ្ឍខេត្តព្រះសីហនុឲ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ទន្ទឹមនឹងការវាយតម្លៃពាក់កណ្តាលអាណត្តិ។ រាជរដ្ឋាភិបាលការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រការអភិវឌ្ឍវិស័យកាត់ដេរ និងផលិតស្បែកជើង ដើម្បីបង្កើនភាពប្រកួតប្រជែង បង្កើតតម្លៃបន្ថែម បង្កើតឧស្សាហកម្មគាំទ្រ និងអភិវឌ្ឍខ្សែច្រវាក់តម្លៃ។ រាជរដ្ឋាភិបាលបន្តជំរុញកិច្ចដំណើរការ និងទាក់ទាញការវិនិយោគនៅ

[56] ឯកសារជាច្រើនបង្ហាញថាបុគ្គលិករបស់Huaweiធ្វើការជាមួយអ្នកស្រាវជ្រាវរបស់កងទ័ពជាតិចិន, ចុះផ្សាយនៅថ្ងៃ: 27/06/2019 កែប្រែថ្ងៃទី: 27/11/2019

តាមតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកសាងមូលដ្ឋានឧស្សាហកម្ម រួមទាំងការកែច្នៃកសិផល ការផ្គុំ និងដំឡើង ការផលិតគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ក្នុងលំនៅដ្ឋាន ការផលិតវត្ថុអនុស្សាវរីយ៍បម្រើវិស័យទេសចរណ៍ ជាដើម។

រាជរដ្ឋាភិបាលនឹងរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ ដោយផ្តោតលើការធ្វើពិពិធកម្មផលិតផល និងគោលដៅទេសចរណ៍ ការទាក់ទាញភ្ញៀវចំណាយខ្ពស់ និងការលើកទឹកចិត្តឧស្សាហកម្មគាំទ្រវិស័យទេសចរណ៍ និងជំរុញការអភិវឌ្ឍវិស័យសេវាផ្នែកកំសាន្ត អក្សរសិល្ប៍ សិល្បៈ គំនូរជីវចល និងភាពយន្ត ព្រមទាំងការលើកកំពស់ការផលិត និងការប្រើប្រាស់ផលិតផលក្នុងស្រុក ពិសេសផលិតផលមានលក្ខណៈប្រពៃណីខ្មែរ និងផលិតផលសម្គាល់ភូមិសាស្ត្រ។

រាជរដ្ឋាភិបាលនឹងជំរុញការអភិវឌ្ឍវិស័យប្រេងកាត និងឧស្ម័ន ជាពិសេសការដាក់ឲ្យដំណើរការអណ្តូងប្រេងកាតឲ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូលដែលបានមកពីធនធានទាំងនេះ ប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព។

វិស័យទេសចរណ៍កម្ពុជា ក្រៅពីតំបន់សៀមរាបអង្គរ ដែលជាតំបន់បេតិកភណ្ឌវប្បធម៌ កម្ពុជា ក៏មានតំបន់ឆ្នេរមុទ្រ និងតំបន់អេកូទេសចរណ៍ជាច្រើនកន្លែងទៀតនៅទូទាំងប្រទេស។ កម្ពុជា កំពុងកែច្នៃតំបន់ទេសចរណ៍ចម្រុះបន្ថែមទៀត ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ ឲ្យមកកម្សាន្តបានកាន់តែច្រើន។ តាមការឲ្យដឹងពី ក្រសួងទេសចរណ៍ នៅឆ្នាំ ២០១៨ កម្ពុជា ទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ៦,២ លាននាក់ កើនឡើង ១០% និងនាំមកនូវប្រាក់ចំណូលប្រមាណ ៤,៣ ពាន់លានដុល្លារអាមេរិក ដែលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប (GDP) ប្រមាណ ១២ភាគរយ ហើយកម្លាំងពលកម្មបម្រើឲ្យវិស័យនេះមានជាង ៦២ ម៉ឺននាក់ ហើយនៅឆ្នាំ ២០១៩ កម្ពុជារំពឹងទទួលភ្ញៀវទេសចរអន្តរជាតិប្រមាណ ៦,៦លាននាក់ ហើយនៅឆ្នាំ ២០៣០ ប្រមាណ ១៥ លាននាក់ ដោយរំពឹងរកចំណូលបានប្រមាណ ១០ ពាន់លានដុល្លារអាមេរិក និងបង្កើតឱកាសការងារប្រមាណ ២ លានកន្លែង។[57]

ចំនួនភ្ញៀវទេសចរបរទេស ដែលចូលមកកម្សាន្តនៅក្នុងប្រទេសកម្ពុជា មានកើនឡើងជាបន្តបន្ទាប់ ហើយនៅក្នុងឆ្នាំ ២០១៩ កម្ពុជា រំពឹងនឹងទទួលបានភ្ញៀវទេសចរណ៍ប្រមាណ ៦,៦ លាននាក់។ ប៉ុន្តែបើយើងមើលពី ចំណូលបានមកពី ការលក់សំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ គិតត្រឹមរយៈពេល ១១ខែ ដើមឆ្នាំ ២០១៩ នេះ គឺមានការធ្លាក់ចុះប្រមាណ ១៤ ភាគរយ ពោលគឺ ធ្លាក់មកនៅ ៨៩ លានដុល្លារអាមេរិក ក្នុងនោះ ភ្ញៀវទេសចរបរទេសជាង ១,៩ លាននាក់ បានទិញសំបុត្រចូលទស្សនា ដែលតួលេខនេះ មានការធ្លាក់ចុះប្រមាណ ១៤ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ ២០១៨។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ គ្រឹះស្ថានអង្គរ។

[57] វិស័យទេសចរណ៍កម្ពុជាក្នុងឆ្នាំ២០១៩ ទទួលរងគ្រោះអ្វីខ្លះ? ដោយ សន ពុទ្ធិ https://cambonomist.com/news/cambodia-tourism-2019-/

ដោយឡែក បើយោងតាមរបាយការណ៍របស់ក្រសួងទេសចរណ៍ បានបង្ហាញឲ្យដឹងថា វិស័យទេសចរណ៍នៅកម្ពុជា នៅតែរក្សាបាននូវភាពទាក់ទាញ សម្រាប់ភ្ញៀវទេសចរបរទេស គិតត្រឹមរយៈពេល ១០ខែ ដើមឆ្នាំ ២០១៩ នេះ ប្រទេសកម្ពុជា ទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ៥,២ លាននាក់ ដែលមានកំណើន ៩ភាគរយ ធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ ២០១៨ ហើយនៅក្នុងនោះ ចំនួនភ្ញៀវទេសចរចិន បន្តកើនឡើងដល់ជាង ២ លាននាក់ ដែលមានកំណើន ២៤ ភាគរយ ឈរលើកំពូលតារាងតែម្តង។

អ្វីដែលគួរឲ្យកត់សម្គាល់គឺ ភ្ញៀវទេសចរអន្តរជាតិ ដែលធ្វើដំណើរតាមផ្លូវអាកាសមកកាន់ តំបន់មាត់សមុទ្រកម្ពុជា មានជាង ១ លាននាក់ កើនឡើងជាង ៤២ ភាគរយ ខណៈដែលការធ្វើដំណើរទៅកាន់ ខេត្តសៀមរាប មានជាង ១,៨ លាននាក់ ធ្លាក់ចុះប្រមាណ ១៣ ភាគរយ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៨។

យោងតាមទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការវិនិយោគពី ឆ្នាំ ២០១៦ ដល់ខែសីហា ឆ្នាំ ២០១៩ មាន ៨១៣ គម្រោង មានទុនវិនិយោគសរុបប្រមាណជាង ២២ ពាន់លានដុល្លារអាមេរិក ក្នុងនោះ គម្រោងទេសចរណ៍ និងផ្នែកពាក់ព័ន្ធ មានចំនួន ៣៨ គម្រោង ដែលមានទុនវិនិយោគប្រមាណជាង ៩ ពាន់លានដុល្លារអាមេរិក។

បើតាមរបាយការណ៍ពី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា CDC បានបង្ហាញថា ក្នុងរយៈពេល ១០ខែ ដើមឆ្នាំ ២០១៩ នេះ គម្រោងវិនិយោគដែលត្រូវបានអនុម័ត មានចំនួន ២៦៨ គម្រោងដែលមានទុនវិនិយោគសរុបជាង ៦,៨ ពាន់លានដុល្លារអាមេរិក ក្នុងនោះ វិស័យទេសចរណ៍ គឺមានតែ ១៨ គម្រោងប៉ុណ្ណោះ តែមានទុនវិនិយោគសរុបជាង ៤,៨ ពាន់លានដុល្លារអាមេរិក ដែលធ្វើឲ្យតួលេខនេះ វ៉ាដាច់វិស័យផ្សេងៗតែម្តង ហើយការកើនឡើងដ៏លើសលុបនៃ ទុនក្នុងវិស័យទេសចរណ៍នេះគឺដោយសារតែមាន គម្រោងវិនិយោគធំៗជាច្រើន នៅតាមតំបន់ឆ្នេរសមុទ្រ ហើយវានឹងត្រូវការពេលវេលាច្រើន សម្រាប់ការអភិវឌ្ឍផងដែរ។[58]

ទន្ទឹមនឹងការអភិវឌ្ឍន៍ បញ្ហាប្រឈមមួយចំនួនក៏កើតមានឡើងផងដែរ។ ការអភិវឌ្ឍន៍លឿនពេកក្នុងឆ្នាំកន្លង នៅគោលដៅទេសចរណ៍តំបន់ឆ្នេរ ធ្វើឱ្យអាជ្ញាធរសមត្ថកិច្ចនិងស្ថាប័នពាក់ព័ន្ធពិបាកគ្រប់គ្រងផ្នែកសំណល់ និងបរិស្ថាន។ ខ្វះខាតការផ្គត់ផ្គង់តម្រូវការទេសចរណ៍ ដូចជា បញ្ហាទឹកស្អាតផ្តល់ឱ្យតាមសណ្ឋាគារ ផ្ទះសំណាក់ និងតាមសេវាកម្មទេសចរណ៍នានាមិនគ្រប់តាមតម្រូវការ និងមានភាពយឺតយ៉ាវជាទីបំផុត។ ការសាងសង់ស្ថានីយ៍ប្រេង សង់ផៃ និងសង់រីសតន៍នៅជាប់នឹងឆ្នេរដោយគ្មានអាងចម្រោះទឹកស្អាត។ 59 កត្តា

[58] វិស័យទេសចរណ៍កម្ពុជាក្នុងឆ្នាំ២០១៩ ទទួលរងគ្រោះអ្វីខ្លះ?,ដោយ សន ពុទ្ធិកា 4 ខែមុន, https://cambonomist.com/news/cambodia-tourism-2019-/

[59] បញ្ហាប្រឈមក្នុងវិស័យទេសចរណ៍ត្រូវបានលាតត្រដាងដើម្បីដោះស្រាយ,ដោយៈមូលសម្បត្តិApril 4, 2019, 12:50 PM, https://bit.ly/2WFEWCu

ដែលនាំឲ្យភ្ញៀវទេសចរបរទេសធ្លាក់ចុះនៅខេត្តសៀមរាប គឺសេវាកម្មទេសចរណ៍របស់កម្ពុជាមិនទាន់មានភាពសម្បូរបែប បើធៀបនឹងប្រទេសជិតខាង ដូចជាទីកន្លែងកម្សាន្ត និងមជ្ឈមណ្ឌលទំនិញ និងខ្វះការផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីគោលដៅទេសចរណ៍។ ការយកចិត្តទុកដាក់ខ្ពស់ចំពោះទេសចរជនជាតិចិន ជាងទេសចរនៃប្រទេសលោកខាងលិចក៏បានបង្កឲ្យកើតមានបញ្ហាព្រួយបារម្ភក្នុងវិស័យទេសចរណ៍ផងដែរ។

### 4.3. ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

រាជរដ្ឋាភិបាលរៀបចំ និងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រសេដ្ឋកិច្ចឌីជីថលរយៈពេលវែង និងដាក់វិស័យឌីជីថលជាអនុវិស័យក្នុងប្រព័ន្ធគណនីជាតិ។ រាជរដ្ឋាភិបាលបន្តធ្វើបច្ចុប្បន្នភាព និងអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ផែនការមេបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ការរៀបចំ និងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។

ទាក់ទងនឹងឧស្សាហកម្មទី៤ រាជរដ្ឋាភិបាលតាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន បានអនុវត្តសកម្មភាពមួយចំនួនក្នុងឆ្នាំ ២០១៩ នេះរួមមាន៖ ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មបច្ចេកវិទ្យាចំពោះការផ្តល់សេវាសាធារណៈលើការងារដឹកជញ្ជូនផ្លូវគោក ការបង្កើតកម្មវិធីនៅលើទូរសព្ទទំនើបសម្រាប់មន្ត្រីជំនាញយល់ដឹងពីទ្រឹស្តីនៃការបើកបរ និងច្បាប់ចរាចរផ្លូវគោក និងត្រួតពិនិត្យព័ត៌មានយានយន្ត និងប័ណ្ណបើកបរ ការអនុញ្ញាតឲ្យប្រើប្រាស់សេវាដឹកជញ្ជូនចែករំលែក (Ride Sharing) តាមរយៈក្រុមហ៊ុនឯកជនដូចជា Pass App និង Grab ការរៀបចំដាក់ឲ្យប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យកំពង់ផែ (Port EDI System) ការដាក់ឲ្យរៀបចំប្រើប្រាស់កម្មវិធីនៅលើទូរស័ព្ទទំនើបសម្រាប់ថែទាំផ្លូវថ្នល់ (Road Care App) និងការសិក្សាកម្មវិធីនៅលើទូរស័ព្ទទំនើបសម្រាប់ដីចំណីផ្លូវ។

រាជរដ្ឋាភិបាលបន្តពង្រឹង និងពង្រីងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រចាំបាច់រួមមាន៖ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និងដឹកជញ្ជូនបញ្ញើរហ័សក្នុងស្រុក ព្រមទាំងឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធទូទាត់ការសងប្រាក់អេឡិចត្រូនិច ព្រមទាំងពិនិត្យលទ្ធភាពកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ ចូលប្រព័ន្ធអ៊ីនធ័រណិតថ្នាក់ជាតិ (National Internet Gateway)។ រាជរដ្ឋាភិបាលជំរុញ និងបង្កើតមូលដ្ឋានគតិយុត្តិគាំទ្រដល់ការអភិវឌ្ឍវិស័យឌីជីថល ដោយរួមទាំងការជំរុញការអនុវត្តយុទ្ធសាស្ត្ររដ្ឋាភិបាលឌីជីថល និងសន្តិសុខព័ត៌មានច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ច្បាប់ស្តីពីបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងវិសោធកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលគាំទ្រ និងជំរុញការរីកចម្រើន និងការពារហានិភ័យក្នុងវិស័យនេះ។

ក្នុងឆ្នាំ២០១៩ ក្រោមជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងធនាគារពិភពលោក (Wold Bank) រាជរដ្ឋាភិបាលបានបង្កើត ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលត្រូវរំពឹងថានឹងផ្តល់លទ្ធ

ភាពយ៉ាងច្រើនដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាក្នុងការភ្ជាប់ខ្លួនទៅខ្សែចង្វាក់ផលិតកម្មទីផ្សារក្នុងស្រុក និងអន្តរជាតិ នឹងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជាក្នុងការត្រៀមទទួលយកបដិវត្តន៍ឧស្សាហកម្មទី៤ បើយោងតាមសេចក្តីថ្លែងហេតុរបស់រដ្ឋាភិបាល។

បើទោះបីជាច្បាប់បង្កើតឡើងក្នុងគោលបំណងគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជានេះមិនទាន់បានអនុវត្តក៏ដោយ គេរំពឹងទុកថាច្បាប់នេះនឹងផ្តល់នូវលទ្ធភាពឲ្យសហគ្រាសធុនតូច និងមធ្យម (SME) នៅកម្ពុជាអាចភ្ជាប់ខ្លួនទៅនឹងខ្សែចង្វាក់ផលិតកម្ម និងទីផ្សារក្នុងស្រុក និងអន្តរជាតិក៏ដូចជាជំរុញឲ្យមានការច្នៃប្រឌិត និងការបង្កើតទំនិញ និងសេវាថ្មីៗបន្ថែមទៀត។[60] រាជរដ្ឋាភិបាលបានអះអាងថាច្បាប់ស្តីពី «ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច» នេះផ្តល់សារៈប្រយោជន៍សំខាន់ៗចំនួន ៥ រួមមាន៖

១៖ សម្រួល និងជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងក្នុងប្រទេស និងអន្តរជាតិ តាមរយៈការបង្កើតភាពប្រាកដប្រជា ផ្នែកគតិយុត្ត និងការទទួលស្គាល់យថាភូតភាព សុក្រឹតភាព និងភាពអាចជឿទុកចិត្តបាន នៃទម្រង់អេឡិចត្រូនិក និងទំនាក់ទំនងអេឡិចត្រូនិកសម្រាប់ការធ្វើពាណិជ្ជកម្មកម្ពុជា និងជាមួយអន្តរជាតិ, ការលុបបំបាត់របាំង និងលក្ខខណ្ឌតម្រូវមិនចាំបាច់ទាំងឡាយ ដែលជាឧបសគ្គដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការបង្កើនទំនុកចិត្តដល់អន្តរការី បុគ្គលផ្តល់សេវា ពាណិជ្ជករ និងអ្នកប្រើប្រាស់ ក្នុងការធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាព និងអាចជឿទុកចិត្តបាន។

២៖ បង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ពីសំណាក់ក្រសួង-ស្ថាប័នរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក និងសម្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជី ការបង្កើត ឬការរក្សាទុកក្នុងទម្រង់អេឡិចត្រូនិកជាមួយក្រសួង ស្ថាប័នរដ្ឋ តាមរយៈការទទួលស្គាល់សកម្មភាព និងប្រអេឡិចត្រូនិក។

៣៖ លើកកំពស់ទំនុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់ទំនាក់ទំនងអេឡិចត្រូនិកក្នុងសកម្មភាព និងប្រតិបត្តិការនានា តាមរយៈការទទួលស្គាល់សុពលភាព អានុភាពគតិយុត្ត និងភាពអាចអនុវត្តបាននៃទម្រង់អេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក ភស្តុតាងអេឡិចត្រូនិក ហត្ថលេខាអេឡិចត្រូនិក និងធានាដល់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកបានឆាប់រហ័ស និងមានសុវត្ថិភាព។

៤៖ លើកកំពស់កិច្ចការពារអ្នកប្រើប្រាស់នៅក្នុងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការការពារព័ត៌មានឯកជនដល់អ្នកប្រើប្រាស់ និងការទទួលបានព័ត៌មានច្បាស់លាស់ និងគ្រប់គ្រាន់អំពីទំនិញ ឬសេវាដាក់លក់តាមប្រព័ន្ធអេឡិចត្រូនិក។

[60] ច្បាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានអនុម័ត, ហ៊ឹន ពិសី। Publication date 09 October 2019, https://bit.ly/3futeDh

៥៖ រារាំងការប្រព្រឹត្តអំពើទាំងឡាយ ដែលបង្កឱ្យមានការប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ប្រកបដោយសុវត្ថិភាព និងទំនុកចិត្ត។[61]

ក្នុងឆ្នាំ២០១៩នេះ រាជរដ្ឋាភិបាលបានរៀបចំសេចក្តីព្រាងច្បាប់បទល្មើសបច្ចេកវិទ្យាព័ត៌មាន។ បើតាមរដ្ឋាភិបាល សេចក្តីព្រាងច្បាប់នេះបង្កើតឡើងក្នុងគោលបំណងធានាសុច្ចរិតភាពនៃការប្រើប្រាស់ ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ និងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការការពារសិទ្ធិសេរីភាពបុគ្គល ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបការប្រព្រឹត្តបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា។ ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលប្រព្រឹត្តនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលអំពើនោះធ្វើឱ្យប៉ះពាល់ដល់រូបវន្តបុគ្គល នីតិបុគ្គល សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាននេះមាន ៧ ជំពូក ៤៨ មាត្រា ដែលកំពុងទទួលយកធាតុចូលផ្សេងៗដែលពាក់ព័ន្ធដើម្បីដាក់ចូលទៅក្នុងសេចក្តីព្រាងច្បាប់។[62] តែទោះបីជាយ៉ាងណាក្តីច្បាប់នេះត្រូវបានទទួលរងការរិះគន់ថាអាចនឹងត្រូវរដ្ឋាភិបាលយកមកប្រើសំរាប់គ្រប់គ្រងសេរីភាពក្នុងការបញ្ចេញមតិ នៅក្នុងបណ្តាញសង្គមផងដែរ។ សូមបញ្ជាក់ផងដែរថានៅពេលកន្លងមកមានការចាប់ខ្លួនពលរដ្ឋមួយចំនួនដែលបានរិះគន់រដ្ឋាភិបាលតាមប្រព័ន្ធបណ្តាញហ្វេសបុកផងដែរ។

រាជរដ្ឋាភិបាលអភិវឌ្ឍជំនាញ និងការអប់រំ ការបណ្តុះណ្តាល ដោយផ្តោតលើលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឲ្យបានទូលាយ និងបញ្ចូលការប្រើប្រាស់ និងការយល់ដឹងបច្ចេកវិទ្យាឌីជីថលក្នុងកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារការងារ រួមទាំងការបង្កើតយន្តការភាពជាដៃគូរវាងធុរៈកិច្ច និងគ្រឹះស្ថានអប់រំ និងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ។ រាជរដ្ឋាភិបាលអភិវឌ្ឍសហគ្រិនភាព និងប្រព័ន្ធអេកូឡូស៊ីឌីជីថល ដែលជាបរិស្ថានអំណោយផលដល់ការបង្កើតធុរៈកិច្ចថ្មីៗ ការជំរុញការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងធុរៈកិច្ច និងការបង្កើតយន្តការសហប្រតិបត្តិការសហគ្រិនភាព ក្នុងក្របខណ្ឌរាជរដ្ឋាភិបាល ឬភាពជាដៃគូជាមួយវិស័យឯកជន។

### 4.4. ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ

រាជរដ្ឋាភិបាលបន្តអនុវត្ត «យុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥» បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃច្រកចេញ-ចូលទូទាត់ និងជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ដោយប្រើបច្ចេកវិទ្យាហិរញ្ញវត្ថុ និងធនាគារ ឲ្យស្របតាមការរីកចំរើននៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសមាហរណ

[61] គណៈរដ្ឋមន្ត្រីអនុម័តទាំងស្រុងហើយ លើសេចក្តីព្រាងច្បាប់ស្តីពី «ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច», https://bit.ly/2Wxjgs8

[62] ក្រសួងមហាផ្ទៃ បើកកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន, ដោយ សោភា, ច័ន្ទ, 9 ធ្នូ 2019 13:15, https://kleykley.sabay.com.kh/article/1178694

កម្មប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ទៅក្នុងតំបន់ និងអន្តរជាតិ។ រាជរដ្ឋាភិបាល បន្តធានាស្ថិរភាពហិរញ្ញវត្ថុ ពិសេសតាមរយៈការពង្រឹងយន្តការគ្រប់គ្រង និងត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និងធនាគារ។

រាជរដ្ឋាភិបាលបន្តពង្រឹងវិស័យធនាគារដើម្បីកៀរគរធនធានហិរញ្ញវត្ថុនៅក្នុងស្រុក និងសិក្សា និងរៀបចំគោលនយោបាយ និងយន្តការដើម្បីពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុ ព្រមទាំងពង្រីកគោលការណ៍គាំពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលបន្តអភិវឌ្ឍទីផ្សារមូលបត្រដោយជំរុញ និងលើកទឹកចិត្តដល់សហគ្រាស និងក្រុមហ៊ុនឲ្យបោះផ្សាយមូលបត្រជាសាធារណៈ ការលើកកម្ពស់យន្តការជួញដូរដោយបង្កើតឲ្យមានវិនិយោគិនស្ថាប័ន និងបង្កើតប្រតិបត្តិករទីផ្សារមូលបត្រអនាគត ព្រមទាំងការសិក្សា និងបង្កើតយន្តការគ្រប់គ្រងការជួញដូរទ្រព្យឌីជីថល។ បន្ថែមលើសពីនេះរាជរដ្ឋាភិបាលនឹងសិក្សា និងរៀបចំឲ្យមានទីផ្សារសញ្ញាបណ្ណរដ្ឋ ដើម្បីជាមូលដ្ឋានសម្រាប់កំណត់អត្រាការប្រាក់គោល ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់វិនិយោគសាធារណៈ និងការជួយពង្រឹងគោលនយោបាយរូបិយវត្ថុ។ រាជរដ្ឋាភិបាលជំរុញ និងលើកទឹកចិត្តដល់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុដើម្បីលើកកម្ពស់ប្រតិបត្តិការធនាគារឲ្យកាន់តែទំនើប មានប្រសិទ្ធភាព សុវត្ថិភាព និងមានតម្លៃសមរម្យ។

រាជរដ្ឋាភិបាលនឹងលើកម្ពស់ និងបង្កើតសមត្ថភាពវិភាគ តាមដាន និងត្រួតពិនិត្យកិច្ចការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឲ្យកាន់តែទូលំទូលាយតាមរយៈការបង្កើតគោលនយោបាយថ្នាក់ជាតិ។ រាជរដ្ឋាភិបាលបន្តពង្រឹង និងពង្រីកផលិតផលធានារ៉ាប់រងថ្មីៗ ពិសេសសេវាធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូច។

គិតត្រឹមចុងឆ្នាំ ២០១៩ នៅកម្ពុជាមាន គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរួមមានធនាគារពាណិជ្ជចំនួន ៤៦ ធនាគារឯកទេស ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើរពីសារធារណជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើរពីសារធារណជន ៧៥ គ្រឹះស្ថានឥទានជនបទ ២៤៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ និងគ្រឹះស្ថានផ្តល់សេវាទូទាត់ ២០។ តាមរបាយការណ៍របស់ធនាគារជាតិឆ្នាំ២០១៩ ធនាគារកាន់តែមានទំហំវិសាលភាពធំក្នុងសេដ្ឋកិច្ចដោយទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានកើនឡើង ២៤,៥% ។ ជាមួយគ្នានេះ បណ្តាញប្រតិបត្តិការនៅរាជធានីខេត្តរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានបន្តកើនឡើង និងរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានកើនឡើងដល់ ២.៤៥០ សាខា ម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ដល់ ២.៥២០ ម៉ាស៊ីន និងបានផ្តល់សេវាប្រាក់បញ្ញើ ៧.៥៨៧.០៤៨ គណនី និងសេវាឥទាន ៣.០៦៦.៨៨០ គណនី។ លើសពីនេះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុកាន់តែសកម្ម ដើម្បីសម្រួលដល់ដល់អតិថិជនជាមួយនឹងការប្រើប្រាស់ប័ណ្ណជំនួសសាច់ប្រាក់ ការផ្តល់សេវាផ្ទេរប្រាក់ និងការទូរទាត់សងប្រាក់អេឡិចត្រូនិក។

ពាក់ព័ន្ធនឹងវិស័យធនាគារ ក្នុងឆ្នាំ ២០១៩ ធនាគារពាណិជ្ជក្នុងស្រុកដែលមានសក្តានុពលគឺធនាគារអេស៊ីលីដាបានគ្រោងបោះផ្សាយលក់ភាគហ៊ុន បន្ទាប់ពីទើបទទួលបានការយល់ព្រមពីធនាគារជា

តិ។ ធនាគារនេះនឹងក្លាយជាធនាគារ ពាណិជ្ជទី១ នៅកម្ពុជា ដែលនឹងបញ្ចុះបញ្ជីលក់ភាគហ៊ុន ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ត្រូវបានចាត់ទុកជា "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈជូនប្រជាពលរដ្ឋ"[63] ដែលលើកទឹកចិត្តដល់វិនិយោគិនរូបវន្តបុគ្គល និងសាធារណជនក្នុងការទិញភាគហ៊ុនទៅតាមលទ្ធភាពរបស់ខ្លួន។ គិតត្រឹមដំណាច់ ខែកញ្ញា ឆ្នាំ ២០១៩ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាធនាគារធំជាងគេបំផុតនៅកម្ពុជា ដែលមានសំពៀតឥណទានសរុប ៣,៦១ ប៊ីលានដុល្លារអាមេរិក និងមូលធនសរុប ៨៩៨,៥៦ លានដុល្លារអាមេរិក ទ្រព្យសកម្មសរុប ៦,០៩ ប៊ីលានដុល្លារអាមេរិក និងប្រាក់បញ្ញើសរុប ៤,២៤ ប៊ីលានដុល្លារអាមេរិក។

ដោយឡែក ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ ដែលគេនាំគ្នាហៅថា ធនាគារ ABA និង ធានាគារ LOLC ក៏ទទួលបានការសម្រេចផ្តល់ការអនុញ្ញាតលើលទ្ធភាពចុះបញ្ជីលក់សញ្ញាបណ្ណសាជីវកម្ម (មូលបត្របំណុល) នៅលើផ្សារមូលបត្រកម្ពុជាផងដែរ។ តាមការរំពឹងទុក ABA អាចនឹងបើកការជួញដូរនៅពាក់កណ្តាលខែសីហា ឆ្នាំ ២០១៩ ដែលទំហំទឹកប្រាក់ ១០០ ពាន់លានរៀល ដែលស្មើនឹងប្រមាណ ២៥ លានដុល្លារអាមេរិក។[64]

ស្របពេលដែលវិស័យធនាគារ និងហិរញ្ញវត្ថុមានការរីកចម្រើននោះ ការសិក្សាស្រាវជ្រាវមួយបានរកឃើញថាប្រជាពកលរដ្ឋកម្ពុជាបាន និងកំពុងរងគ្រោះដោយសារបំណុលពីគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា។ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ និងសមាគមធាងត្នោត ធ្វើការសិក្សាស្រាវជ្រាវលើការរំលោភបំពានសិទ្ធិមនុស្សក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាជាង ២ លាននាក់បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ដោយយោងតាមរបាយការណ៍រួមរបស់អង្គការ លីកាដូ និងសមាគមធាងត្នោត បានរកឃើញថា ប៉ុន្មានឆ្នាំចុងក្រោយនេះ កម្រិតនៃបំណុលរបស់ប្រជាពលរដ្ឋបានកើនឡើងកាន់តែខ្លាំងឡើងៗ ដែលនេះបណ្តាលឱ្យអាចកើតមានការរំលោភបំពានសិទ្ធិមនុស្សជាច្រើន រួមមានការបង្ខំឱ្យលក់ដី ការកេងប្រវ័ញ្ចកំលាំងពលកម្មកុមារ ការធ្វើចំណាកស្រុកដោយសារបំណុល និងការបញ្ចាំខ្លួនដើម្បីដោះបំណុល។[65] គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ធ្វើប្រតិបត្តិការកម្ចីដោយអត្រាការប្រាក់ខ្ពស់ ដែលតម្រូវឱ្យដាក់បញ្ចាំប្លង់ដីជាទ្រព្យបញ្ចាំ ហើយស្ថាប័ននេះដាក់គោលដៅលើអតិថិជនក្រីក្រដែលងាយរងគ្រោះក្នុងការបាត់បង់ដីធ្លី រហូតផ្តល់ផលប៉ះពាល់អវិជ្ជមានដល់សុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសសហគមន៍ដែលងាយរងគ្រោះ។ ការកំណត់ពិដានអត្រាការប្រាក់ប្រចាំឆ្នាំ ត្រឹម

---

[63] ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រោងនឹងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ច័ន្ទ, 2 ធ្នូ 2019 09:05, https://bit.ly/2W9dSfM

[64] ABA ទទួលបានការអនុញ្ញាតឲ្យចុះបញ្ជីលក់មូលបត្របំណុល នៅលើផ្សារមូលបត្រកម្ពុជា, https://bit.ly/3dpAxdm

[65] សេចក្តីថ្លែងការណ៍ "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា", ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៩, https://opendevelopmentcambodia.net/km/announcements/statement-on-collateral-damage-land-loss-and-abuses-in-cambodias-microfinance-sector/

១៨% សម្រាប់កម្ចីថ្មី ដែលបានកំណត់ឡើងដោយរាជរដ្ឋាភិបាលកាលពីខែមីនា ឆ្នាំ ២០១៧ មិនបានកាត់បន្ថយការកើនឡើងនៃទំហំការប្រាក់ ឬជួយដោះស្រាយបញ្ហាប្រជាពលរដ្ឋបានឡើយ។

នៅដើមឆ្នាំ ២០២០ តាមរយៈធនាគារជាតិកម្ពុជា ព្រះរាជាណាចក្រកម្ពុជា និងថៃ បានដាក់កម្មវិធីឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនតាមរយៈ QR Code។ ការដាក់ឱ្យដំណើរការគម្រោងនេះ មានអត្ថប្រយោជន៍ណាស់សម្រាប់លើកកម្ពស់ការទូទាត់រូបិយវត្ថុជាតិ ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុ សម្រួលការធ្វើពាណិជ្ជកម្មឆ្លងដែន និងកំណើនភ្ញៀវទេសចរទៀតផង។[66]

## 5. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍវិស័យឯកជន និងការងារ

នៅក្នុងគោលនយោបាយសំរាប់ការអភិវឌ្ឍវិស័យឯកជន និងការងារ ផែនការយុទ្ធសាស្ត្ររាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- ការអភិវឌ្ឍទីផ្សារការងារ
- ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព
- ការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន
- ការពង្រឹងការប្រកួតប្រជែង

### 5.1. ការអភិវឌ្ឍទីផ្សារការងារ

រាជរដ្ឋាភិបាលនឹងបន្តពង្រឹងវេទិកាយន្តការ «វេទិកាការងារ» ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ និងការពង្រីកការផ្តល់សេវារកការងារ និងការផ្សព្វផ្សាយ ព្រមទាំងការបញ្ជ្រាបព័ត៌មានទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស។ រាជរដ្ឋាភិបាល បន្តអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឲ្យមានប្រសិទ្ធិភាព តាមរយៈគោលការណ៍ដែលបាន និងកំពុងអនុវត្តសម្រាប់ចរចារតំឡើងប្រាក់ឈ្នួលដល់កម្មករ និយោជិតជារៀងរាល់ឆ្នាំស្របតាមស្ថានភាពសង្គម សេដ្ឋកិច្ច និងផលិតភាព និងរៀបចំបើកប្រាក់ឈ្នួលប្រចាំខែក្នុងរយៈពីរសប្តាហ៍ម្តង និងការទូរទាត់ប្រាក់អតីតភាពការងារប្រចាំឆ្នាំឲ្យបានទៀងទាត់ដល់កម្មករ និយោជិត។

រាជរដ្ឋាភិបាលពង្រឹង និងពង្រីកការអនុវត្តកម្មវិធីហ្វឹកហ្វឺនកូនជាង/កម្មសិក្សាដោយធ្វើវិសោធកម្មច្បាប់ស្តីពីការងារ និងធ្វើស្ថាប័នីយកម្មប្រព័ន្ធហ្វឹកហ្វឺនកូនជាង/កម្មសិក្សា ដោយភ្ជាប់ជាមួយប្រព័ន្ធលើកទឹកចិត្តដល់សហគ្រាស និងគ្រឹះស្ថានដែលអនុវត្តប្រព័ន្ធនេះ។ រាជរដ្ឋាភិបាលពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារតាមរយៈការអនុវត្តឲ្យបានពេញលេញនូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទដ្ឋានការងារអន្តរជាតិ ដើម្បីធានាសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ លក្ខខណ្ឌការងារ

[66] កម្មវិធីដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនតាមរយៈ QR Code រវាងព្រះរាជាណាចក្រកម្ពុជា និងថៃ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ១៨ កុម្ភៈ ២០២០, https://bit.ly/2Wxm6NO

សុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ ក៏ដូចជាសុវត្ថិភាពដឹកជញ្ជូនកម្មករ និយោជិត ព្រមទាំងអត្ថប្រយោជន៍កម្មករនិយោជិត និងពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្មករនិយោជិកដើម្បីគ្រប់គ្រងការផ្តល់បណ្ណការងារ និងការបើកប្រាក់រង្វាន់អតីតភាពការងារ និងប្រាក់សោធននិវត្តន៍។

រាជរដ្ឋាភិបាលពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទការងារ ការអនុវត្តច្បាប់ស្តីពីសហជីព និងការបកស្រាយលិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងអនុសញ្ញាអន្តជាតិស្តីពីការងារ។ រាជរដ្ឋាភិបាលបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់ លើកកម្ពស់ការគាំពារសិទ្ធិ ផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលក្នុងការទំនាក់ទំនងជាមួយគ្រួសារ និងការរៀបចំធ្វើសមាហរណកម្មពលករទេសសន្តរប្រវេសន៍ដែលធ្វើមាតុភូមិនិវត្តន៍តាមរយៈការទទួលស្គាល់ជំនាញ ការផ្ទេររបបសន្តិសុខសង្គមក្នុងប្រទេស ការផ្តល់ការប្រឹក្សាការងារធ្វើ និងការបង្កើតមុខរបរដោយខ្លួនឯង។

រាជរដ្ឋាភិបាលបន្តពង្រីកការតភ្ជាប់បណ្តាញអគ្គិសនី និងទឹកស្អាតដោយតម្លៃទាបសមរម្យជូនកម្មករនិយោជិត សិស្ស និស្សិតនៅតាមផ្ទះជួល ការជំរុញការរៀបចំកន្លែងស្នាក់នៅ និងមធ្យោបាយធ្វើដំណើរសម្រាប់កម្មករ និយោជិតដោយសុវត្ថិភាព ការអនុញ្ញាតឈប់លំហែរមាតុភាពរយៈពេល ៣ ខែដោយទទួលបានប្រាក់ឈ្នួលពលកម្ម ១២០% ការផ្តល់សេវាថែទាំសុខភាព និងការពិនិត្យផ្ទៃពោះដល់កម្មការិនីដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យ ឬមណ្ឌលសុខភាពរដ្ឋ ការផ្តល់ការឧបត្ថម្ភដល់កម្មការីនីដែលមានផ្ទៃពោះ និងសម្រាលកូនរួច និងការបន្តកែសម្រួលប្រាក់ឈ្នួលអប្បរមាដែលត្រូវជាប់ពន្ធ និងការអនុគ្រោះពន្ធចំពោះប្រាក់អត្ថប្រយោជន៍បន្ថែម។

ទាក់ទងនឹងវិស័យការងារ កម្ពុជាត្រូវបានគេមើលឃើញថាមានការកើតឡើងនូវកង្វះ និងគម្លាតជំនាញ ដោយសារយន្តការគាំទ្រដោយលំហូរព័ត៌មានរវាងភាគីពាក់ព័ន្ធ ជាពិសេសអ្នកស្វែងរកការងារ និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលមិនទាន់ត្រូវបានអភិវឌ្ឍន៍ល្អពេញលេញ។ រាជរដ្ឋាភិបាលបានអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ដោយបង្កើតឱ្យមានឡើងនូវប្រព័ន្ធព័ត៌មានទីផ្សារការងារជាតិមួយ គឺទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដែលដើរតួនាទីក្នុងការប្រមូលវាយតម្លៃ និងផ្តល់ព័ត៌មានទីផ្សារទូលំទូលាយ សំដៅធ្វើឱ្យមានតម្លាភាពទូទាំងប្រទេស ពាក់ព័ន្ធនឹងការផ្គត់ផ្គង់ និងតម្រូវការនៅលើទីផ្សារការងារ ផ្តល់ភាពងាយស្រួលឆាប់រហ័សដល់អ្នកស្វែងរកការងារ និងនិយោជកក្នុងការទទួលបានព័ត៌មាន និងការផ្គូផ្គងរវាងឱកាសការងារ និងដំណឹងជ្រើសរើសកម្លាំងពលកម្ម ព្រមទាំងផ្តល់ការគាំទ្រផ្សេងទៀត ដើម្បីជួយឱ្យទីផ្សារការងារមានដំណើរការកាន់តែប្រសើរ ។

របាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា ២០១៨ នេះ វិស័យការងារបន្តអភិវឌ្ឍរីកចម្រើន អត្រាមានការងារធ្វើ ៩៩,៣ ភាគរយនៃកម្លាំងពលកម្មសរុបប្រមាណជិត ១០

លាននាក់ ទូទាំងប្រទេស។[67] របាយការណ៍បានបន្តថា ការបន្តរីកលូតលាស់ផ្នែកសេដ្ឋកិច្ចក៏បានបន្តលទ្ធភាពឲ្យរាជរដ្ឋាភិបាលអាចអភិវឌ្ឍ និងពង្រីកជាបន្តបន្ទាប់នូវប្រព័ន្ធគាំពារសង្គម សម្រាប់កម្មករនិយោជិតសំដៅធានាឲ្យកាន់តែបាននូវស្ថិរភាព សន្តិសុខ និរន្តរភាពការងារ ប្រាក់ចំណូល ភាពកក់ក្តៅក្នុងចិត្តសម្រាប់កម្មករនិយោជិត និងគ្រួសារដោយបានដាក់ឲ្យអនុវត្តនូវរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។ សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួនសរុប ១,២ ម៉ឺន គ្រឹះស្ថាន និងមានកម្មករនិយោជិតចំនួន ១,៥ លាននាក់។ សហគ្រាស គ្រឹះស្ថាននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធមានប្រមាណ ៦ សែនគ្រឹះស្ថាន មានកម្មករនិយោជិតប្រមាណ ២,៤ លាននាក់។ វិស័យកសិកម្មមានកម្មករនិយោជិតជាង ៤ លាននាក់ ពលករធ្វើការនៅក្រៅប្រទេសមាន ១,២ លាននាក់ និងមន្ត្រីសាធារណៈប្រមាណ ៥ សែននាក់។

ទោះបីយ៉ាងណា អ្នកឃ្លាំមើលចាត់ទុកការលើកឡើងនេះគឺជាទិន្នន័យដែលមិនបានសិក្សាស្រាវជ្រាវច្បាស់លាស់ និងគិតសរុបទាំងអ្នកមានការងារតិចតួច។ លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាថ្លែងថាប្រទេសកម្ពុជាបច្ចុប្បន្នអ្នកគ្មានការងារធ្វើច្រើន ទាំងអ្នកមានជំនាញ ទាំងសិស្សនិស្សិត កំពុងសិក្សានៅសាកលវិទ្យាល័យ ហើយការងារដែលធ្វើនោះក៏គ្មានគុណភាពថែមទៀត។ យោងលើទិន្នន័យរបស់អង្គការ ILO បានបង្ហាញថា ១ គ្រួសារមានប្រជាពលរដ្ឋជាមធ្យម ៥,៣ នាក់ក្នុងនោះអត្រាអ្នកមានការងារធ្វើជាង ២,៥០ ដូចនេះមានន័យថា ១ នាក់កន្លះ។ តាមទិន្នន័យនេះក្នុងមនុស្សម្នាក់ត្រូវចិញ្ចឹមមនុស្សម្នាក់ទៅហើយ។ បើយករបាយការណ៍នោះមកប្រៀបធៀបអត្រាអត់ការងារធ្វើ ០,៧ គឺមិនត្រូវទេ។[68]

បើទោះបីប្រជាពលរដ្ឋកម្ពុជាប្រមាណជាង ៩០ ភាគរយមានការងារធ្វើពិតមែនទោះ លោក ទុន សោភ័ណ អ្នកសម្របសម្រួលថ្នាក់ជាតិប្រចាំអង្គការពលករអន្តរជាតិ (ILO) យល់ថាបញ្ហានៃគុណភាពការងារទាំងនោះនៅតែត្រូវការយកចិត្តទុកដាក់ ដោយសារនៅមានប្រជាជនរងគ្រោះក្រោមបន្ទាត់ក្រីក្រច្រើន បើទោះបីពួកគេ ធ្វើការងារហើយ។ ហើយបញ្ហាមួយទៀតនោះកម្ពុជានៅមានអ្នកធ្វើការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធច្រើន ដែលគួរត្រូវបានទទួលបានសេវាការពារផ្នែកច្បាប់ ទទួលបានប្រាក់ឈ្នួលកំណត់ត្រឹមត្រូវ និងទទួលបានសេវាគាំពារសង្គមផងដែរ។[69]

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ធ្វើការវិភាគព្យាករណ៍ និងបង្ហាញអំពីការវិវត្តរបស់ទីផ្សារការងារនៅកម្ពុជា ដោយផ្តោតសំខាន់ទៅលើឱកាសការងារតាមប្រភេទនៃមុខរបរ។ របាយការណ៍បានបង្ហាញដែរថា ប្រភេទការងារដែលអាចឲ្យអ្នកស្វែងរកការងារងាយនឹងទទួលបាននោះមានដូចជាវិស្វករឧស្សាហកម្ម និងផលិតកម្ម, វិស្វករទូរគមនាគមន៍, អ្នកឯកទេសផ្នែកវិទ្យាសាស្ត្រ និងថតកាំរស្មីអ៊ិច, អ្នកបកប្រែអត្ថបទ និង

---

[67] មន្ត្រីថា អត្រាមានការងារធ្វើឆ្នាំនេះ ៩៩,៣% តែអ្នកឃ្លាំមើលមិនយល់ស្រប, វ៉ន ដារ៉ា | Publication date 29 October 2018 | 08:33 ICT, https://bit.ly/2Wchy0f

[68] Ibid

[69] Ibid

អ្នកបកប្រែផ្ទាល់មាត់, អ្នកបច្ចេកទេសផ្នែកសេវាគាំទ្រព័ត៌មានវិទ្យា, វិស្វករគីមី, អ្នកបញ្ជាម៉ាស៊ីនចំហុយទឹក, ជាងធ្វើកញ្ចក់, ជាងដំឡើងបំពង់ទុយោ និងបំពង់បង្ហូរ និងអ្នកដំឡើងម៉ាស៊ីនយានយន្ត។[70]

## 5.2. ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព

រាជរដ្ឋាភិបាលនឹងបញ្ចប់ការរៀបចំ និងជំរុញការអនុវត្ត«គោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម» ឲ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលពង្រឹងការអនុវត្តយន្តការគាំទ្រ ដើម្បីជួយសម្រួលដល់ការចុះបញ្ជី ការផ្តល់សេវាសម្របសម្រួល ការផ្សព្វផ្សាយព័ត៌មានទីផ្សារឲ្យបានទូលំទូលាយ និងទាន់ពេលវេលា ការផ្សព្វផ្សាយ និងបញ្ជ្រាបបច្ចេកវិទ្យាថ្មី និងការបន្តខិតខំស្វែករ និងជ្រៀតចូលទីផ្សារនាំចេញសម្រាប់ផលិតផលកម្ពុជា។ រាជរដ្ឋាភិបាលនឹងបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម ដើម្បីផ្តល់ហិរញ្ញប្បទាន ព្រមទាំងជំរុញការរៀបចំ និងអនុវត្តនូវជម្រើសហិរញ្ញប្បទាននានា រួមទាំងយន្តការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម (Collective Investment Scheme) ផង។ រាជរដ្ឋាភិបាលបង្កើតមូលនិធិជាតិសហគ្រិនភាព និងមជ្ឈមណ្ឌលអភិវឌ្ឍសហគ្រិនភាពដោយសហការជាមួយវិស័យឯកជន សំដៅលើកកម្ពស់សហគ្រិនភាព និងប្រសិទ្ធភាពធុរៈកិច្ច។

រាជរដ្ឋាភិបាលពង្រឹង និងពង្រីកបន្ថែមការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រដូចជាមន្ទីរពិសោធន៍ថ្នាក់ជាតិ ការបន្តកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម ការកែលម្អប្រព័ន្ធឡូជីស្ទីក ព្រមទាំងការបន្តលើកទឹកចិត្ត និងការទាក់ទាញវិនិយោគក្នុងការបង្កើតចង្កោមសហគ្រាសធុនតូច និងមធ្យម (SME Cluster)។ រាជរដ្ឋាភិបាលព្រមទាំងជំរុញការលើកកម្ពស់គុណភាពផលិតផលនៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការពង្រីកអនុលោមភាពលក្ខខណ្ឌអនាម័យ និងភូតគាមអនាម័យ និងស្តង់ដារ ព្រមទាំងការលើកទឹកចិត្តនវានុវត្តន៍ តាមរយៈការការពារកម្មសិទ្ធបញ្ញា និងការផ្តល់ប្រកាសនីយបត្រតក្កកម្ម (Patents).

វិស័យសហគ្រាសធុនតូច និងមធ្យមបានផ្លាស់ប្តូរចលនាសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងជាគន្លឹះយ៉ាងសំខាន់ក្នុងការស្រោចស្រង់ការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅពេលមានវិបត្តិសេដ្ឋកិច្ចម្តងៗ ព្រមទាំងបានស្រូបយកវត្ថុធាតុដើមក្នុងស្រុកមួយចំណែកធំឲ្យក្លាយជាផលិតផលសម្រាប់ប្រើប្រាស់ផលិតកម្មក្នុងស្រុក។ វិស័យនេះក៏បានដើរតួក្នុងការអភិវឌ្ឍ និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងសាកលផងដែរ ដោយការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មីៗ និងចំណេះដឹងដ៏សម្បូរបែប។ ចាប់តាំងពីឆ្នាំ ១៩៩៣ មក ផលិតផលសរុបក្នុងស្រុកបានកើនឡើងជាបន្តបន្ទាប់ ចាប់ពី ១២,៦% រហូតដល់ ២៦,២% នៅឆ្នាំ ២០០៦ ។ ចាប់ពីពេលនោះមក វិស័យឧស្សាហកម្មបានចាប់ផ្តើមថមថយ និងស្ថិតក្នុងសភាពទ្រឹងក្នុងរង្វង់ ២២% ។ ដោយសារការប្រែប្រួលរបបពាណិជ្ជកម្មអន្តរជាតិ និងវិបត្តិសេដ្ឋកិច្ចសាកលលោក ។ នៅឆ្នាំ ២០១៣ វិភាគទាននៃវិស័យឧស្សាហកម្មចំពោះ ផ.ស.ស. ចាប់ផ្តើមរើបឡើងវិញ ដែលប៉ាន់ស្មានស្ថិតក្នុងរង្វង់ ២៤% ។ បើគិតកំណើនវិញ ក្នុងរយៈ

[70] មន្ត្រីថា អត្រាមានការងារធ្វើឆ្នាំនេះ ៩៩,៣% តែអ្នកឃ្លាំមើលមិនយល់ស្រប, វ៉ន ដារ៉ា | Publication date 29 October 2018 | 08:33 ICT, https://bit.ly/2Wchy0f

ពេល ១៥ ឆ្នាំចុងក្រោយ (១៩៩៨-២០១៣) វិស័យឧស្សាហកម្មមានកំណើនជាមធ្យម ១២,៤% ក្នុងមួយឆ្នាំ ធៀបនឹង ៤,៧% សម្រាប់វិស័យកសិកម្ម និង ៨,៥% សម្រាប់វិស័យសេវាកម្ម ពោលគឺមានកំណើនខ្ពស់បំផុត។

នៅចុងឆ្នាំ ២០១៨ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានឲ្យដឹងថាហគ្រាសខ្នាតតូច និងមធ្យម បានគ្របដណ្តប់ ៩៩% នៃចំនួនសហគ្រាសទាំងអស់នៅកម្ពុជា ហើយវិស័យនេះកំពុងដើរតួយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានកំណើនសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ សហគ្រាសធុនតូច និងមធ្យមបានចងក្រងជាក្រុម និងកសាងបណ្តាញជាមួយអតិថិជនរបស់ខ្លួនជាមួយក្រុមដទៃទៀត ដែលជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើម គ្រឿងចក្រ គ្រឿងម៉ាស៊ីន អ្នកផ្តល់បច្ចេកវិទ្យាថ្មីៗបានស្គាល់ដៃគូប្រកួតប្រជែងរបស់ខ្លួន និងវិនិយោគនានា សំដៅធ្វើឲ្យកម្ពុជាក្លាយទៅជាទីកន្លែងសម្រាប់បង្កើតធុរៈកិច្ចផ្សេងៗដល់វិនិយោគិនក្នុង និងក្រៅប្រទេស។

ក្រសួងបានឲ្យដឹងដែរថា ក្នុងចំណោមសហគ្រាសប្រមាណ ៥១ ម៉ឺន សហគ្រាសកម្មន្តសាលមានតែប្រមាណ ៧ ម៉ឺនសហគ្រាស ឬស្មើនឹង ១៤% ដែលក្នុងនោះ ៤៥% កែច្នៃចំណីអាហារ និងភេសជ្ជៈ ហើយ ៣៤% ខាងតម្បាញ និងកាត់ដេរសម្លៀកបំពាក់។[71] ក្នុងចំណោមសហគ្រាសខ្នាតធំៗក្នុងវិស័យឧស្សាហកម្មប្រមាណ ៨០% ស្ថិតក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ។ រចនាសម្ព័ន្ធផ្នែកកម្មន្តសាលបែបនេះ ស្ថិតក្នុងកម្រិតអភិវឌ្ឍន៍ទាបនៅឡើយ ដោយសារផលិតកម្មចំណីអាហារ និងសម្លៀកបំពាក់ជាទូទៅមានតម្លៃបន្ថែមទាប និងមិនសូវស្មុគស្មាញ។

ក្រសួងក៏បានលើកឡើងពីបញ្ហាប្រឈម នៃស្ថានភាពឧស្សាហកម្មកម្ពុជាថាមានសភាពទន់ខ្សោយនៅឡើយ ដែលឆ្លុះបញ្ចាំងពីរចនាសម្ព័ន្ធផលិតកម្មសាមញ្ញ និងតូចចង្អៀត ព្រមទាំងប្រមូលផ្តុំជុំវិញផលិតផលសម្លៀកបំពាក់ និងការកែច្នៃអាហារ មូលដ្ឋានផលិតកម្ម ដែលភាគច្រើនមានលក្ខណៈគ្រួសារ កង្វះសហគ្រិនភាព និងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិតនៅឡើយសម្រាប់ប្រកួតប្រជែងលើទីផ្សារអន្តរជាតិ។

នៅចុងឆ្នាំ ២០១៨ នេះផងដែរ បានមានវិធានរាជរដ្ឋាភិបាលជំរុញការលើកកម្ពស់វិស័យសហគ្រាសធុនតូចនិងមធ្យម។តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានចាប់ផ្តើមបានរៀបចំបង្កើតមូលនិធិអភិវឌ្ឍន៍ជំនាញ, ធនាគារសហគ្រាសធុនតូច និងមធ្យម, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និង មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាព ដើម្បីជួយទៅដល់វិស័យការលើកកម្ពស់វិស័យសហគ្រាសធុនតូចនិងមធ្យមឲ្យមានប្រសិទ្ធភាព យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានឲ្យដឹងថា សហគ្រាសធុនតូច និងមធ្យម អាចទទួលបាននូវការលើកទឹកចិត្តដូចជា៖

---

[71] **សហគ្រាសធុនតូច និងមធ្យមមានតួនាទីជំរុញកំណើនសេដ្ឋកិច្ចជាតិ**, bopha bopha, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥, https://kohsantepheapdaily.com.kh/article/134287.html

១ លើកលែងពន្ធលើប្រាក់ចំណូលចំនួន ៣ ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាស ចុះបញ្ជីថ្មី ឬចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន។

២ លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃដែលចុះបញ្ជីពន្ធដារសម្រាប់សហគ្រាសចុះបញ្ជីថ្មី ឬ ចាប់ពីថ្ងៃដែលសហគ្រាសមកធ្វើបច្ចុប្បន្នកម្មសម្រាប់សហគ្រាសដែលបានចុះបញ្ជីពន្ធដាររួចហើយ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ដែលបំពេញលក្ខខណ្ឌណាមួយ ដូចខាងក្រោមៈ ប្រើវត្ថុធាតុដើមក្នុងស្រុក ចាប់ពី ៦០%ឡើងទៅ ឬបង្កើនចំនួននិយោជិតបន្ថែមយ៉ាងតិច ២០% ឬមានទីតាំងក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម (SME Cluster)។

៣ លើកលែងការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បរមា ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ។

៤ លើកទឹកចិត្តចំណាយដែលអាចកាត់កងបាន ដូចខាងក្រោមៈ ក អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការប្រើប្រាស់បញ្ជីគណនេយ្យតាមប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន, ខ អនុញ្ញាតកាត់កងចំណាយ ២០០% ចំពោះចំណាយលើការបណ្តុះបណ្តាលការកាន់បញ្ជីគណនេយ្យ ឬ ការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់និយោជិត, និងគ អនុញ្ញាតកាត់កងចំណាយ ១៥០% ចំពោះចំណាយវិនិយោគលើម៉ាស៊ីន ឬឧបករណ៍បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍ សម្រាប់បម្រើនិងលើកកម្ពស់ផលិតភាពផលិតកម្ម ។

វិស័យអាទិភាពសម្រាប់ផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារខាងលើរួមមានៈ ទី(១) ផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្ម, ទី(២) ផលិត និងកែច្នៃម្ហូបអាហារ, ទី(៣) កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុកកែច្នៃកាកសំណល់, និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍, ទី(៤) កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យ កម្មន្តសាលដទៃទៀត, ទី(៥) ស្រាវជ្រាវ និង អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មាន ដែលមានលក្ខណៈនវានុវត្តន៍ និង (៦) សហគ្រាសដែលស្ថិតក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម, និង សហគ្រាសដែលអភិវឌ្ឍតំបន់នេះ។[72]

## 5.3. ការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងវិស័យឯកជន

រាជរដ្ឋាភិបាលបន្តអនុវត្ត គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ ២០១៦ ដល់ ២០២០ និងការរៀបចំគោលនយោបាយអនុវត្ត

[72] សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសេដ្ឋកិច្ច https://www.mef.gov.kh/documents/news/press-release-sme-workshop-20190103.pdf

គម្រោងវិនិយោគសាធារណៈក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់រយៈពេលវែង។ រាជរដ្ឋាភិបាលបន្តអនុវត្តការងារអាទិភាពមួយចំនួនទៀតដូចខាងក្រោម៖

ការបន្តរៀបចំក្របខណ្ឌគតិយុត្ត និងបទប្បញ្ញត្តិពាក់ព័ន្ធ ការដាក់ឲ្យអនុវត្តនីតិវិធិគ្រប់គ្រងប្រតិបត្តិការរួម ព្រមទាំងការពិនិត្យលទ្ធភាពរៀបចំបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុនានា តាមការចាំបាច់ និងស្របតាមបរិការណ៍អភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ការបន្តអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សតាមក្រសួងស្ថាប័នពាក់ព័ន្ធលើការគ្រប់គ្រង និងអនុវត្តគម្រោងតាមរូបភាពយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ការបន្តអភិវឌ្ឍគម្រោងវិនិយោគសាធារណៈតាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីឲ្យហិរញ្ញប្បទានវិស័យឯកជនអាចចូលរួមបង្កើន និងពន្លឿនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព សំដៅគាំទ្រដល់កំនើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក៏ដូចជាគាំទ្រដល់ការបន្ធូរបន្ទុកថវិកាជាតិ និងបំណុលសាធារណៈ។

នៅដើមឆ្នាំ ២០១៩ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំបង្កើតសេចក្តីព្រាងច្បាប់ស្តីពី យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គម្រោងវិនិយោគ សាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ហៅកាត់ជាភាសាអង់គ្លេសថា PPP។ សេចក្តីព្រាងច្បាប់ស្តីពី យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺជាឧបករណ៍ដ៏សំខាន់សម្រាប់គ្រប់គ្រងការបែងចែង និងការប្រើប្រាស់ធនធនជាតិ ទាំងធនធានហិរញ្ញវត្ថុទាំងធនធានមនុស្ស និងធនធានបញ្ញាឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងបរិការណ៍មួយដែលកម្ពុជា មានការវិវត្តន៍ឈានឡើងកាន់តែខ្ពស់ ដែលធ្វើឱ្យមានតម្រូវការប្រើប្រាស់ធនធាន លើការវិនិយោគសាធារណៈកាន់តែធំ ជាពិសេស លើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងខណៈដែលធនធានរបស់រដ្ឋនៅមានកម្រិតនៅឡើយ។

ការរៀបចំសេចក្តីព្រាងច្បាប់នេះ គឺឆ្លើយតបនឹងគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាព ជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីចុងឆ្នាំ ២០១៦ កន្លងទៅសំដៅ៖ (១).ការរៀបចំស្ថាប័ន និងការទទួលខុសត្រូវដើម្បីធានាការប្រើប្រាស់គម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ឱ្យបានត្រឹមត្រូវ និងជាប្រយោជន៍ជូនសាធារណៈ; (២).ការបង្កើតក្របខ័ណ្ឌសម្រាប់ការ រៀបចំការអនុវត្ត និងការត្រួតពិនិត្យគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP; (៣).ការបង្កើតនីតិវិធីលទ្ធកម្ម សម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការ PPP; និង (៤).កំណត់យន្តការគាំទ្រនានាពីភាគីរដ្ឋ ការលើកទឹកចិត្តលើការវិនិយោគ និងកាតព្វកិច្ចដទៃដែលមានចែងក្នុងកិច្ចសន្យា។

ក្នុងដំណើរការរបង្កើតច្បាប់នេះ រាជរដ្ឋាភិបាលប្រមូលធាតុចូលសំខាន់ៗ បន្ថែមទៀតពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, អ្នកវិនិយោគ ពីវិស័យពាក់ព័ន្ធ ព្រមទាំងសភា

ពាណិជ្ជកម្មជាតិ និងអន្តរជាតិ ដើម្បីឲ្យសេចក្ដីព្រាងច្បាប់គ្រប់ជ្រុងជ្រោយ, សង្គតិភាព និងអាចអនុវត្តបាន ប្រកប ដោយប្រសិទ្ធភាពខ្ពស់។

ក្រសួងបានឲ្យដឹងថា កម្ពុជាដើម្បីក្លាយទៅជាប្រទេសចំណូលមធ្យមខ្ពស់នៅឆ្នាំ ២០៣០ ត្រូវបង្កើន ការវិនិយោគសាធារណៈក្នុងរង្វង់ប្រមាណ ៤០% នៃផសស ក្នុងមួយឆ្នាំ ដូចបណ្ដាប្រទេស ក្នុងតំបន់ ក៏ប៉ុន្តែ ទំហំនៃការវិនិយោគសារធារណៈសរុបរបស់កម្ពុជា (ទាំងរដ្ឋ និងឯកជន) បច្ចុប្បន្នមានត្រឹមតែប្រមាណពី ២៨% ទៅ ២៩ % ប៉ុណ្ណោះ ក្នុងនោះ ការវិនិយោគសាធារណៈ របស់មានត្រឹមតែ ៨% នៃ ផសស។[73] ក្នុង ន័យនេះ កម្ពុជាគ្មានជម្រើសអ្វីផ្សេងក្រៅពីការទាក់ទាញទុនបន្ថែមពីឯកជន ទាំងទុនដែលមាននៅក្នុងប្រទេស ស្រាប់ និងទុនមកពីក្រៅប្រទេស សម្រាប់យកទៅធ្វើការវិនិយោគសាធារណៈ ដើម្បីបង្កើនទំហំនៃការវិនិយោ គ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ក្រៅពីអាចធានាបាននូវយុត្តិធម៌សង្គមកាន់តែប្រសើរ តាមយន្តការនេះ, រាជរដ្ឋាភិបាលមានជំនឿថា វិស័យឯកជនក៏អាចនឹងនាំ មកនូវប្រសិទ្ធភាព, នវានុវត្តន៍, ចំណេះដឹង និងចំណេះធ្វើ ដែលនឹងធ្វើឱ្យសេដ្ឋកិច្ចកាន់តែមានប្រសិទ្ធភាព និងមានតម្លៃបន្ថែមកាន់តែខ្ពស់ ថែមទៀត។

ក្រសួងបានទទួលស្គាល់ថា យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានចំណុចខ្លាំង និងចំណុច ខ្សោយ ប៉ុន្តែជានិន្នាការប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក កំពុងតែកំពុងពេញនិយមពេញប្រើប្រាស់ នូវយន្តការនេះ រួមទាំងដៃគូក៏កំពុងជំរុញកិច្ចការនេះផងដែរ។ ដូចនេះ ការរៀបចំសេចក្ដីព្រាងច្បាប់នេះ គឺជា ជំហានមួយឆ្ពោះ ទៅរកការកសាងក្របខ័ណ្ឌមួយ ប្រកបដោយតម្លាភាព និងយុត្តិធម៌ សម្រាប់គ្រប់គ្រង និង ចែករំលែកហានិភ័យ និងផលចំណេញ ដើម្បីទាក់ទាញការវិនិយោគបន្ថែមពីឯកជន។

ដោយឡែក នៅក្នុងវេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៨ នៅដើមខែមេសា ២០១៩ ក្នុងស្មារតីនៃការធានាចីរភាព នៃកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន តាមរយៈការបន្តពង្រឹង និងពង្រីក ភាពប្រកួតប្រជែង ក៏ដូចជាជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ នៅក្នុងល្បឿន និងជវភាពមួយកាន់តែខ្ពស់ ថែមទៀត រាជរដ្ឋាភិបាលបានដាក់ចេញនូវកញ្ចប់ជាវិធានការដោះស្រាយនូវបញ្ហាជារចនាសម្ព័ន្ធធំៗ ក៏ដូចជា បញ្ហាប្រឈមជាក់ស្ដែងសំខាន់ៗផ្សេងទៀត ដែលបណ្ដាវិនិយោគិន និងធុរជន បាន និងកំពុងជួបប្រទះនៅ ក្នុងកិច្ចការអាជីវកម្មរបស់ខ្លួន នៅកម្ពុជា។ វិធានការជាក់លាក់ដែលបានដាក់ចេញទាំងនោះមានដូចជា៖

១. ការរំកិលកាំកុងត្រូលចេញពីច្រកទ្វារព្រំដែន និងការលុបចោលកាំសាប។ វិធានការនេះគឺជាការ កែទម្រង់ជារចនាសម្ព័ន្ធដ៏មុតស្រួចមួយ ដែលរាជរដ្ឋាភិបាលបានដាក់ចេញក្នុងបំណងកាត់បន្ថយបន្ទុក ចំណាយ និងបន្ទុករត់ការឯកសារ ជួយឲ្យចំណេញពេលវេលា និងការសម្រួលឲ្យបានជាអតិបរមាក្នុងការធ្វើ ពាណិជ្ជកម្ម។

---

[73] រាជរដ្ឋាភិបាល កំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពី «យន្តការ ភាពជាដៃគូរវាងរដ្ឋ និងឯកជន»
http://freshnewsasia.com/index.php/en/localnews/111680-2019-01-28-09-49-58.html

២. ការលុបចោលនូវការចេញ CO សម្រាប់ប្រទេសមមិនមានតម្រូវការ និងកម្រៃផ្សេង ២ ទៀត ផ្លូវការ និងមិនផ្លូវការ ដូចជាការកាត់ស្តុក និងការបង់ថ្លៃ Reference CO ជាដើម។

៣. ការកាត់បន្ថយថ្លៃឡជីស្ទីក, ថ្លៃសេវាលើកដាក់ និង ថ្លៃសេវានៅផែទាំងពីរ គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពុងផែស្វយ័តភ្នំពេញ។ថ្លៃលើកដាក់នៅចំណត (Terminal Handling charge-THC)ត្រូវបានបញ្ចុះពី ៥ ដុល្លារ/TEU លើសេវាលើកដាក់កុងតឺន័រលើចំណតតាមរយៈការចរចាររបស់ក្រសួងសាធារណការ។

៤. ការកាត់បន្ថយថ្លៃអគ្គិសនីចាប់ពីឆ្នាំ ២០១៩ ចំនួន ២ សេនដុល្លារក្នុង ១ គីឡូវ៉ាត់ម៉ោង សម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ដែលទិញតាមខ្សែបញ្ជូនរង និងខ្សែតង់ស្យុងមធ្យមនៅតំបន់ចែកចាយផង។

៥. ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម តាមរយៈដាក់ចេញនូវគោលនយោបាយជាកញ្ចប់ដើម្បីលើកកម្ពស់ការអភិវឌ្ឍ ពង្រឹងភាពប្រកួតប្រជែង និងបង្កើនសមត្ថភាពផលិតកម្ម។ គោលនយោបាយជាកញ្ចប់ ដែលរាជរដ្ឋាភិបាលបានដាក់ចេញរួមមានដូចខាងក្រោម[74]៖

១- ការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ សហគ្រាសធុនតូច និងមធ្យម។

២- ការលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូច និងមធ្យម

៣- ការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញ

៤- ការរៀបចំដាក់អោយដំណើរការនៅក្នុងឆ្នាំ ២០១៩ នូវធនាគារសហគ្រាសធុនតូច និងមធ្យម (SME Bank) ដែលមានកញ្ចប់ទឹកប្រាក់ដំបូង ប្រមាណ ១០០ លានដុល្លារ

៥-ការរៀបចំគោលនយោបាយជាកញ្ចប់សម្រាប់លើកស្ទួយវិស័យសហគ្រាសធុនតូច និងមធ្យម (SMEs)

៦- ការបង្កើតមូលនិធិសហគ្រិនភាព ដែលមានថវិកា ៥ លានដុល្លារ ក្នុងមួយឆ្នាំ

៦- ការសម្រួលពាណិជ្ជកម្ម ស្ថិតក្រោមដែនសមត្ថកិច្ចគយ

៧. ការសម្រួលដល់ធុរៈកិច្ចនៅក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋានពន្ធដារ

៨. ការកាត់បន្ថយថ្លៃឈប់សម្រាកបុណ្យ និងទិវា

៩. ការពិនិត្យ និងរៀបចំជាបញ្ជីស្លាប័ន និងពេលវេលាចុះត្រួតពិនិត្យតាមរោងចក្រ

១០. ការកំណត់អត្រាភាគទាន នៃរបបសោធន

១១. ការកំណត់នូវពេលវេលា និងចំនួនថ្ងៃបើកប្រាក់បំណាច់អតីតភាពការងារ

១២. ការពិនិត្យលទ្ធភាពកែសម្រួលច្បាប់ការងារ ដើម្បីឲ្យស្របទៅនឹងបរិបទថ្មី នៃសេដ្ឋកិច្ច

១៣. ការកំណត់ប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកាត់ដេរ

[74] សុន្ទរកថាគន្លឹះ និងមតិបូកសរុប ថ្លែងក្នុងវេទិការាជរដ្ឋាភិបាល វិស័យឯកជន លើកទី ១៨ http://km.cnv.org.kh/2019/%E1%9E%9C%E1%9E%B7%E1%9E%9F%E1%9F%90%E1%9E%99%E1%9E%AF%E1%9E%80%E1%9E%87%E1%9E%93-%E1%9E%9B%E1%9E%BE%E1%9E%80%E1%9E%91%E1%9E%B8-%E1%9F%A1%E1%9F%A8/

១៤. ការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈការអនុគ្រោះពន្ធអាករ និងពន្ធដារ

១៥. ការប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ ទៅជាធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

១៦. ការដឹកជញ្ជូនតាមផ្លូវដែក

វិធានការចខាងលើ ត្រូវបានរាជរដ្ឋាភិបាលដាក់ចេញ និងកំពុងត្រូវបានចាត់ចែងជំរុញអនុវត្ត។ ក្រៅពីវិធានការខាងលើ រាជរដ្ឋាភិបាលបានអះអាងថាបាន និងកំពុងរៀបចំវិធានការផ្សេងៗសម្រាប់ពេលអនាគតផងដែរ។

### 5.4. ការពង្រឹងការប្រកួតប្រជែង

រាជរដ្ឋាភិបាល និងអនុវត្តគោលនយោបាយ និងការងារអាទិភាពដូចខាងក្រោម៖

ការជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការប្រកួតប្រជែង(Anti-trust/ competition law) ដែលជាក្របខណ្ឌសម្រាប់ជំរុញការប្រកួតប្រជែង ពង្រឹងរចនាសម្ព័ន្ធឧស្សាហកម្ម រៀបចំយន្តការសម្រាប់អនុវត្តច្បាប់ និងលើកកម្ពស់វប្បធម៌ប្រកួតប្រជែង។

ការពិនិត្យឡើងវិញ និងធ្វើវិសធនកម្មច្បាប់ស្តីពីក្ស័យធនដែកជំរុញការទទួកយកហានិភ័យ និងការការពារសហគ្រិនភាព។

ការជំរុញអនុវត្តយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (Commercial Arbitration) ដែលមានសមត្ថភាព អាចជឿទុកចិត្តបាន និងដោះស្រាយជម្លោះធុរៈកិច្ចដែលអាចទទួលយកបាន។

ការបន្តជំរុញការរៀបចំ និងអនុវត្តស្តង់ដារទំនិញ សេវា និងការគ្រប់គ្រង ហើយលើកកម្ពស់ស្តង់ដារទាំងនោះជាប្រចាំ ដើម្បីជំរុញការចាប់យកបច្ចេកវិទ្យាថ្មី និងការលើកកម្ពស់គុណភាព។

ការជំរុញរៀបចំ និងអនុម័តច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (Consumer Protection Law) និងរៀបចំយន្តការអនុវត្ត ដើម្បីការពារសិទ្ធិ និងសុវត្ថិភាពអ្នកប្រើប្រាស់ លើកកម្ពស់សុខភាព ពង្រឹងស្តង់ដារទំនិញ និងសេវា ព្រមទាំងលើកកំពស់ការប្រកួតប្រជែង។

ការពង្រឹងយន្តការជំរុញការប្រកួតប្រជែងដោយស្មើភាព ជាពិសេសក្នុងការបំពេញកាតព្វកិច្ចពន្ធអាករ និងការអនុវត្តលទ្ធកម្មសាធារណៈ ប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ។

## 6. គោលនយោបាយ និងការងារអាទិភាព នៃការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន

នៅក្នុងគោលនយោបាយសំរាប់ការអភិវឌ្ឍ ប្រកបដោយចីរភាព និងបរិយាប័ន្ន ផែនការយុទ្ធសាស្ត្ររាជរដ្ឋាភិបាលបានចែកចេញជា ៤ ផ្នែកសំខាន់ៗដូចខាងក្រោម៖

- ការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍជនបទ
- ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព
- ការពង្រឹងការគ្រប់គ្រងនគររូបនីយកម្ម
- ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

### 6.1. ការលើកស្ទួយវិស័យកសិកម្ម និងអភិវឌ្ឍជនបទ

រាជរដ្ឋាភិបាលនឹងអនុវត្តគោលនយោបាយ និងការងារអាទិភាពរបស់ខ្លួនដូចជា៖ ការជំរុញការរៀបចំ និងដាក់ឲ្យអនុវត្តផែនការមេសម្រាប់អភិវឌ្ឍវិស័យកសិកម្មឆ្ពោះទៅឆ្នាំ ២០៣០ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យកសិកម្មឆ្នាំ ២០១៩-២០២៣ ។

ការបន្តជំរុញការរៀបចំអនុមតិ និងអនុវត្ត ច្បាប់ស្តីពីការការពាររុក្ខជាតិ និងភូតគាមអនាម័យ និងច្បាប់ស្តីពីផលិកម្មកសិកម្មតាមកិច្ចសន្យា។

ការបង្កើតផលិតភាព គុណភាព និងពិពិធកម្ម តាមរយៈការបង្កើនថវិកាវិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍពូចដំណាំ ពូជសត្វ នងការចិញ្ចឹមត្រី ដែលផ្តល់តម្លៃបន្ថែមខ្ពស់ ការជំរុញអភិវឌ្ឍកសិដ្ឋានគំរូ (Model Farm) ការជំរុញការផ្តល់សេវាបច្ចេកទេសកសិកម្ម ការពង្រីកការគ្រប់គ្រងសហគមន៍កសិករ ការរៀបចំយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា ការបន្តកាត់បន្ថយថ្លៃ និងពង្រឹងគុណភាពនៃធាតុចូលកសិកម្ម ការសិក្សារៀបចំឲ្យមានសេវាធានារ៉ាប់រងផលិតកម្មកសិកម្ម ការរៀបចំឲ្យមានផលិតផលហិរញ្ញវត្ថុសម្រាប់ផលិតកម្មកសិកម្ម និងការជំរុញឲ្យប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាត និងឌីជីថល។

ការលើកកម្ពស់ឧស្សាហកម្មកែច្នៃតាមរយៈការជំរុញឲ្យមានការវិនិយោគឯកចនលើកសិផលដែលមានសក្តានុពលដូចជាស្រូវ ដំឡូងមី ស្វាយ ស្វាយចន្ទី ចេក កៅស៊ូ បន្លែ ជាដើមតាមរយៈការរៀបចំយុទ្ធសាស្រ្តតាមមុខដំណាំនីមួយៗ។

ការបន្តជំរុញដាំបន្លែគ្រប់ប្រភេទជំនួសឲ្យការនាំចូល និងការរៀចំបង្កើតទីផ្សារបោះដុំ និងចែកចាយបន្លែដែលមានស្តងដារ និងអនាម័យខ្ពស់។

ការជំរុញពាណិជ្ជបនីយកម្មកសិកម្មតាមរយៈការបន្តពង្រឹងប្រព័ន្ធអនាម័យ និងភូតគាមអនាម័យ (SPS) ការសម្រួលពាណិជ្ជកម្ម ការវិនិយោគបន្ថែមលើមន្ទីរពិសោធន៍គុណភាពសម្រាប់ការនាំចេញ ព្រមទាំងការជំរុញផលិតផលកសិកម្មក្នុងស្រុក។

ការជំរុញការចិញ្ចឹមសត្វ និងវារិវប្បកម្មតាមរយៈការបន្តអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្រមខណ្ឌផែនការយុទ្ធសាស្រ្តអភិវឌ្ឍវិស័យបសុសត្វឆ្នាំ ២០១៦-២០២៥ និងផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍវារីវប្បកម្មឆ្នាំ ២០១៦-២០៣០។

ការពង្រឹងការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច ការបន្តជំរុញការបោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការផ្តល់ដីសម្បទានសង្គមកិច្ចពិសេសដល់គ្រួសារក្រីក្រសម្រាប់ធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

ការធ្វើវិចារណកម្មក្នុងការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ដោយយកចិត្តទុកដាក់លើការបង្កើនការតភ្ជាប់ទៅនឹងផលិតកម្មកសិកម្ម ការថែទាំជាប្រព័ន្ធ និងការពង្រឹងការគ្រប់គ្រង។

ការបន្តជំរុញការអភិវឌ្ឍជនបទឲ្យរស់រវើក ដោយបន្តវិនិយោគលើផ្លូវជនបទ ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការពង្រីកការគ្រប់ដណ្តប់ការប្រើប្រាស់អគ្គិសនី ការពង្រីកការទទួលបានទឹកស្អាត ការលើកកម្ពស់អនាម័យ ការរៀបចំភូមិ និងលំនៅដ្ឋាន ព្រមទាំងការលើកកម្ពស់ជីវភាពប្រជាជនតាមរយៈការបន្តអនុវត្ត «ចលនាភូមិមួយ ផលិតផលមួយ» និង«ចលនាភូមិថ្មី»។

វិស័យកសិកម្ម ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានកំណើនទាប ហើយតម្លៃផលិតផលកសិកម្មក៏មានការប្រែប្រួលមិនច្បាស់លាស់ ទោះបីជាកម្ពុជាអាចផលិតបាននូវផលិតផលកសិកម្មបានច្រើនក៏ដោយ។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញជាវិធានការពន្ធដារជាច្រើន ដើម្បីជួយដល់វិស័យនេះ រួមមានជាអាទិ៍៖ (១)- បានចាត់ទុកជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមលើការនាំចូល និងផ្គត់ផ្គង់ទំនិញមួយចំនួនដូចជា ជីគ្រប់ប្រភេទ ពូជដំណាំគ្រប់ប្រភេទ បសុឱសថ ចំណីសត្វ និងចំណីបន្ថែម ពូជសត្វគ្រប់ប្រភេទ ព្រមទាំងគ្រឿងយន្ត និងឧបករណ៍កសិកម្ម (២)- បានដាក់ចេញនូវយន្តការអនុគ្រោះអាករលើតម្លៃបន្ថែមចំពោះអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់អង្ករសម្រាប់បម្រើការនាំចេញអង្ករ ដោយក្នុងនោះរួមមាន ការចាត់ទុកជាបន្ទុករបស់រដ្ឋនូវអាករលើតម្លៃបន្ថែមកលើការនាំចូលនូវធាតុចូលផលិតកម្ម និងសំភារៈបរិក្ខាផលិតកម្ម សម្រាប់ផលិតអង្ករបម្រើឲ្យការនាំចេញអង្ករ និងការកំណត់អត្រាសូន្យភាគរយនៃអាករលើតម្លៃបន្ថែម សម្រាប់ការផ្គត់ផ្គង់ដោយផ្ទាល់នូវអង្ករ ឬសេវាផលិតអង្ករសម្រាប់បម្រើឲ្យការនាំចេញអង្ករ និង (៣)- បានដាក់ចេញ ក្នុងពេលថ្មីៗកន្លងទៅនេះ នូវការអនុគ្រោះព្យួរទុកជាបណ្តោះអាសន្ននូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលរយៈពេល ៥ ឆ្នាំ គិតចាប់ពីខែ មករា ឆ្នាំ ២០១៩ លើផលិតផលកសិកម្មស្រូវ-អង្ករ ពោត សណ្តែក ម្រេច គ្រាប់ស្វាយចន្ទី ដំឡូងមី និងកៅស៊ូ។

ដើម្បីឆ្លើយតបនឹងសំណូមពរពីវិស័យឯកជន ពាក់ព័ន្ធនឹងការបង់អាករលើតម្លៃបន្ថែម ពន្ធកាត់ទុកលើសេវាដឹកជញ្ជូន និងពន្ធអប្បបរមា រាជរដ្ឋាភិបាលបានសម្រេចឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ចេញនូវវិធានការបន្ថែមមួយចំនួន ដូចខាងក្រោម៖[75]

ទី ១- ដាក់អាករលើតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ ឬសេវាដល់សហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ នូវស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ ជាបន្ទុករដ្ឋ រហូតដល់ដំណាច់ឆ្នាំ ២០២៣។]

ទី ២- អនុគ្រោះដល់សហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ នូវស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ ឲ្យរួចផុតពីកាតព្វកិច្ចកាត់ទុកប្រាក់ពន្ធលើការទូទាត់ ចំពោះការផ្គត់ផ្គង់សេវាដោយបុគ្គលមិនស្ថិតក្នុងរបបស្វ័យប្រកាស រហូតដល់ដំណាច់ឆ្នាំ ២០២៣ ។

ទី ៣- អគ្គនាយកដ្ឋានពន្ធដារចេញវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋ ដល់សហគ្រាសផលិតផ្គត់ផ្គង់ក្នុងស្រុក ឬនាំចេញ នូវស្រូវ អង្ករ ពោត សណ្តែក ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី និងជ័រកៅស៊ូ ដែលមានសុពលភាព ១ ឆ្នាំម្តង ក្នុងករណីដែលសហគ្រាសនោះកាន់បញ្ជីការគណនេយ្យ ស្រមតាមច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន។

---

[75] សុន្ទរកថាគន្លឹះ និងមតិបូកសរុប ថ្លែងក្នុងវេទិការាជរដ្ឋាភិបាល វិស័យឯកជន លើកទី ១៨ http://km.cnv.org.kh/2019/%E1%9E%9C%E1%9E%B7%E1%9E%9F%E1%9F%90%E1%9E%99%E1%9E%AF%E1%9E%80%E1%9E%87%E1%9E%93-%E1%9E%9B%E1%9E%BE%E1%9E%80%E1%9E%91%E1%9E%B8-%E1%9F%A1%E1%9F%A8/

រាជរដ្ឋាភិបាល ក៏បានប្រែក្លាយធនាគារអភិវឌ្ឍន៍ជនបទ ទៅជាធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។ ពេលកន្លងមក ធនាគារអភិវឌ្ឍន៍ជនបទសម្រេចបាននូវលទ្ធផលជាមួយនឹងដើមទុនមានកម្រិតទាប បើធៀបទៅនឹងការជាក់ស្តែង។ រាជរដ្ឋាភិបាលមានលទ្ធភាពផ្តល់ហិរញ្ញប្បទាន និងសេវាកម្ម ពេញលេញ ប្រកបដោយប្រសិទ្ធិភាព និងចីរភាព ដល់ការអភិវឌ្ឍកសិកម្ម និងសេដ្ឋកិច្ចជនបទ។

ទាក់ទងនឹងវិស័យអភិវឌ្ឍន៍ជនបទ តាមរយៈរបាយការណ៍សន្និបាតបូកសរុបការងាររបស់ក្រសួង ក្នុងឆ្នាំ ២០១៩ នេះក្រសួងបានដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៩-២០២៣ ដែលមានទិសដៅចម្បងគឺជំរុញឲ្យមានការផ្លាស់ប្តូរគុណភាពនៃការរស់នៅរបស់ប្រជាជនជនបទ ទាំងខាងសម្ភារនិងស្មារតី។ លើមូលដ្ឋាននេះ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់យកផែនការយុទ្ធសាស្ត្រចំនួន ៤ ដែលប្រែក្លាយទៅជាកម្មវិធីនៃការងាររបស់ក្រសួងសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ ក្រសួងបានកំណត់កម្មវិធីអាទិភាពចំនួន ៤ រួមមាន កម្មវិធីទី ១.ការអភិវឌ្ឍសមត្ថភាពនិងធនធានមនុស្ស, កម្មវិធីទី ២. ការអភិវឌ្ឍនហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងគមនាគមន៍, ទី៣.ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ និងទី ៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ។ ក្រសួងបានគូសបញ្ជាក់ភាពរីកចម្រើននៃវិស័យអភិវឌ្ឍជនបទ ក្នុងឆ្នាំ ២០១៩ រួមមានដូចជា៖

១.ការងារពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ជាយុទ្ធសាស្ត្រចម្បងទី១ សម្រាប់គាំទ្រដល់ដំណើរការរបស់ក្រសួងទាំងមូល ជាពិសេសការអនុវត្តកម្មវិធីកំណែ ទម្រង់នានារបស់រាជរដ្ឋាភិបាល ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការជាដើម,

២.យុទ្ធសាស្ត្រចម្បងទី ២ បានផ្តោតលើវិស័យអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ ដែលបច្ចុប្បន្នកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយនូវភាពក្រីក្រ ដោយមានការចូលរួមពីដៃគូរអភិវឌ្ឍន៍ជាពហុភាគី និងទ្វេរភាគី,

៣.យុទ្ធសាស្ត្រចម្បងទី៣ ក្រសួងបានកំណត់លើការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ ក្នុងគោលបំណងផ្លាស់ប្តូរទម្លាប់រស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជនបទដែលធ្លាប់ពឹងផ្អែកស្ទើរទាំងស្រុងទៅលើធម្មជាតិ ពុំមានអនាម័យធ្វើជាមធ្យោបាយក្នុងការរស់នៅ មកជាការរស់នៅ តាមបែបវិទ្យាសាស្ត្រ។ ករណីនេះ ក្រសួងបានកំណត់ចក្ខុវិស័យឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបរស់នៅ សហគមន៍ជនបទត្រូវទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព និង

៤.យុទ្ធសាស្ត្រចម្បងចុងក្រោយ ក្រសួងបានផ្តោលើការងារពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជនបទ និងជនជាតិដើមភាគតិច ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រឲ្យបានជាង ១% ក្នុងមួយឆ្នាំ តាមរយៈការធ្វើពិពិតកម្មការងារ និងមុខរបរ ដើម្បីបង្កើនប្រាក់ចំណូល។

បើទោះបីការអភិវឌ្ឍវិស័យកសិកម្មត្រូវបានផ្ដល់អាទិភាព និងមានគោលនយោបាយល្អៗសម្រាប់វិស័យនេះ ក៏វិស័យនេះនៅតែមានបញ្ហាប្រឈមដោយសារកង្វះខាតធនធាន និងការគាំទ្របច្ចេកទេសពីរដ្ឋាភិបាល។ កង្វះខាតទីផ្សារសម្រាប់ផលិតផលក្នុងស្រុកត្រូវបានចាត់ទុកថាជាបញ្ហាចំបង ហើយបញ្ហានេះមិនបានលើកទឹកចិត្តកសិករក្នុងការបង្កបង្កើតផលិតផលកសិកម្មរបស់ខ្លួនឡើយ ដោយជំនួសមកវិញពួកគេបានស្វែងរកការងារធ្វើនៅឆ្ងាយពីទីលំនៅរបស់ពួកគេ ដូចជាធ្វើការជាកម្មកររោងចក្រ និងពលករចំណាកស្រុក។

### 6.2. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព

រាជរដ្ឋាភិបាលនឹងអនុវត្តគោលនយោបាយ និងការងារអាទិភាពរបស់ខ្លួនដូចជា៖ ការជំរុញអនុវត្តគោលនយោបាយជាតិស្ដីពីធនធានរ៉ែឆ្នាំ ២០១៨-២០២៨ ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន សង្គម និងពង្រឹងការប្រមូលចំណូលថវិកាជាតិ។

ការពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មខ្សាច់ដោយកាត់បន្ថយជាអតិបរិមានូវផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន។

ការបន្តការគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃដោយថែរក្សាគម្របព្រៃឈើឲ្យលើស៦០%នៃផ្ទៃប្រទេស ការលើកកម្ពស់អភិវក្សព្រៃឈើ និងសត្វព្រៃ ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ នឹងឈូសឆាយដីព្រៃធ្វើជាកម្មសិទ្ធិ ការលើសកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការការពារ និងស្ដារព្រៃឈើឡើវិញ ព្រមទាំងការបង្ក្រាបបទល្មើសព្រៃឈើ និងការជួញដូរសត្វព្រៃ។

ការបន្តជំរុញការអភិរក្ស និងគ្រប់គ្រងធនធានជលផលតាមរយៈការបង្ក្រាបបទបល្មើសជលផល ការធើឲ្យប្រសើរឡើងនូវសហគមន៍នេសាទ និងការបង្កើនវារីវប្បកម្ម។

ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងការការពារតំបន់ធម្មជាតិដោយផ្ដោតលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរដើម្បីធានាគុណភាពដី នឹងចីរភាពប្រភពទឹក។

ការបន្តអភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ដោយជំរុញការចុះបញ្ជី ពង្រឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ និងចងក្រង ព្រមទាំងបង្កើតតម្លៃបេតិកភណ្ឌវប្បធម៌។

សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាតត្រូវបានរៀបចំបង្កើតឡើងក្នុងឆ្នាំ ២០១៩ នេះ។ ហើយរាជរដ្ឋាភិបាលរំពឹងថា ដំណាក់ប្រេងដំបូងអាចទាញយកមកប្រើប្រាស់ក្នុងពេលឆាប់ៗខាងមុខនេះ។ ក្រសួងរ៉ែ បានលើកឡើងថា កម្ពុជាមានប្លុកប្រេងកាតចំនួន ២៥ កន្លែងនៅក្នុងដែនសមុទ្រ និងដែនគោក ក្នុងនោះដែនសមុទ្រ ៦ប្លុក ដែនគោក ១៩ ប្លុក និង៤តំបន់នៅដែនសមុទ្រទាមទារ ត្រួតគ្នារវាងកម្ពុជា-ថៃ។ ក្រសួងរំលឹកថា នៅក្នុងឆ្នាំ ១៩៩១ មានការដេញថ្លៃប្លុកប្រេងកាតនៅដែនសមុទ្រកម្ពុជាលើកដំបូង ដោយកម្ពុជាបានផ្ដល់សិទ្ធិរុករកនៅដែនសមុទ្រឱ្យក្រុមហ៊ុនចំនួន៣។ ជាមួយគ្នានេះ នៅក្នុងឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាល បានអនុញ្ញាត និងផ្ដល់សិទ្ធិឱ្យសាជីវកម្មប្រេងកាតជប៉ុន ធ្វើការវាស់ស្ទង់តាមអាកាសដើម្បីវាយតម្លៃស្ថានភាពភូគព្ភសាស្ត្រជុំវិញតំបន់ទន្លេសាប និង តំបន់ ទន្លេ មេគង្គ។ បន្ទាប់មកនៅក្នុងឆ្នាំ

១៩៩៧ រាជរដ្ឋាភិបាល ក៏បានចុះកិច្ចព្រមព្រៀងប្រេងកាត ឱ្យក្រុមហ៊ុនប្រេងកាតអន្តរជាតិមួយចំនួន នៅតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា-ថៃ។ សកម្មភាពសិក្សារុករកប្រេងកាតនៅកម្ពុជាកាន់តែដំណើរការច្រើនឡើងវិញទាំងនៅក្នុងដែនសមុទ្រ និងដែនគោក។ នៅក្នុងឆ្នាំ ២០០២ រាជរដ្ឋាភិ បាលបានចុះកិច្ចព្រមព្រៀងប្រេងកាតនៅប្លុក «A» ជាមួយក្រុមហ៊ុន Chevron ដើម្បីធ្វើការស្វែង រុករកប្រេងកាតនៅដែនសមុទ្រកម្ពុជា និងក្នុងឆ្នាំ ២០០៦ រាជរដ្ឋាភិបាល បានអនុញ្ញាត និងផ្តល់សិទ្ធិឱ្យក្រុមហ៊ុន Petroleum Geo-Services ធ្វើការវាស់ស្ទង់ 2D Seismic ទាំងដែនគោក និងដែនសមុទ្រ និងបានចុះកិច្ចព្រមព្រៀង ប្រេងកាតជាមួយក្រុមហ៊ុនមកពីប្រទេសថៃ ចិន ជប៉ុន វៀតណាម និងឥណ្ឌូណេស៊ី ដើម្បីធ្វើការស្វែងរុករក ដែលក្រុមហ៊ុនទាំងនោះ សុទ្ធតែជាក្រុមហ៊ុនជំនាញ និងមានបទពិសោធន៍ និងសមត្ថភាពហិរញ្ញវត្ថុក្នុងសកម្មភាពសិក្សាស្វែងរុករកប្រេងកាតនៅកម្ពុជា។

ក្រសួងបានឲ្យដឹងថា កម្ពុជាអាចផលិតប្រេងបានក្នុងពេលដ៏ឆាប់ខាងមុខនេះ ក្រោមកិច្ចសហការរវាងក្រសួង ជាមួយក្រុមហ៊ុន KrisEnergy របស់សិង្ហបុរី ដែលទទួលបានសិទ្ធិវិនិយោគពីរាជរដ្ឋាភិបាលឲ្យបូមប្រេងនៅអណ្តូងអប្សរាក្នុងប្លុក A។ ស្របពេលដំណាក់ប្រេងកាតដំបូងរបស់កម្ពុជា រោងចក្រចម្រាញ់ប្រេងកាតដំបូងគេរបស់កម្ពុជា ដែលវិនិយោគដោយក្រុមហ៊ុនចិនសហការជាមួយកម្ពុជាក៏នឹងដំណើរការជំហានដំបូងរបស់ខ្លួនផងដែរ។ រោងចក្រនេះអាចចម្រាញ់ប្រេងបានប្រមាណ ២ លានតោនក្នុងមួយឆ្នាំ ខណៈជំហានទី ២ នឹងមានសមត្ថភាពចម្រាញ់ប្រេង នឹងកើនឡើងដល់ ៥ លានតោនក្នុងមួយឆ្នាំ។ រោងចក្រចម្រាញ់ប្រេងកាតដំបូងគេរបស់កម្ពុជា ត្រូវបានបើការដ្ឋានសាងសង់កាលពីខែឧសភា ឆ្នាំ ២០១៧ វិនិយោគដោយក្រុមហ៊ុន Cambodian Petrochemical Co.,Ltd និងក្រុមហ៊ុន ដៃគូរបស់ប្រទេសចិន មានទំហំទឹកប្រាក់ជាង ៦០០ លានដុល្លារ។

នៅចុងឆ្នាំ ២០១៨ ក្រសួងបរិស្ថានបានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង សម្រាប់គម្រោងអាជីវកម្មខ្សាច់សំណង់ និងដីល្បាយខ្សាច់ នៅលើផ្ទៃដីទំហំ ២០ ហិកតា ដែលមាន ទីតាំងស្ថិតនៅតាមដងទន្លេមេគង្គ ក្នុងភូមិកោះប៉ែន ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម របស់សហគ្រាស កង ម៉ារ៉ែន ដែលបានសិក្សាវាយតម្លៃដោយក្រុមហ៊ុនទីប្រឹក្សា ស៊ី អ៊ី អេស ខូ អិលធីឌី។[76] កិច្ចប្រជុំនេះ បានសម្រេចលទ្ធផលសំខាន់ៗរួមមាន (១). អង្គប្រជុំគាំទ្រគម្រោងអាជីវកម្មខ្សាច់សំណង់ និងដីល្បាយខ្សាច់នេះ (២). ត្រូវកំណត់បរិមាណនៃការធ្វើអាជីវកម្មបូមខ្សាច់ក្នុង ០១ឆ្នាំ ឱ្យបានលម្អិត (៣). ត្រូវផ្អាក ឬកាត់បន្ថយសកម្មភាពអាជីវកម្មនៅក្នុងរដូវត្រីពងកូន (៤). ត្រូវដាំដើមឈើនៅ ទីតាំងការដ្ឋានស្តុកខ្សាច់ និងការដឹកជញ្ជូនខ្សាច់ត្រូវគ្របប៉ាតង់ឱ្យបានត្រឹមត្រូវ ដើម្បីកាត់បន្ថយការហុយធូលី ព្រមទាំងគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីផ្លូវថ្នល់ (៥). ត្រូវបំពាក់ប្រព័ន្ធ GPS នៅពេលបូមខ្សាច់ និងស្លាកលេខទូកបូមខ្សាច់ ដើម្បីងាយស្រួលតាមដានសកម្មភាពបូមរបស់សហ

[76] កិច្ចប្រជុំអន្តរក្រសួង ដើម្បីពិនិត្យ និងផ្តល់យោបល់លើគម្រោងអាជីវកម្មខ្សាច់សំណង់ និងដីល្បាយខ្សាច់នៅខេត្តកំពង់ចាម ថ្ងៃ ពុធ 19 ធ្នូ 2018, https://www.moe.gov.kh/index/7569

គ្រាស និង (៦) ត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សាធ្វើការកែសម្រួលនូវចំណុចខ្វះខាតនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូងសម្រាប់គម្រោងនេះ ដែលសមាជិកអង្គប្រជុំបានផ្តល់យោបល់។

នៅក្នុងឆ្នាំ ២០១៩ នេះ កម្ពុជានៅតែមានបញ្ហាជាមួយអាជីវកម្មខ្សាច់។ ខ្សាច់ គឺជាធនធានដ៏សំខាន់មួយសម្រាប់វិស័យសំណង់ ឧស្សាហកម្ម និងដំណាំកសិកម្មផ្សេងៗ ជាពិសេសខ្សាច់ល្បាយភក់។ កម្ពុជាធ្វើសកម្មភាពបូមខ្សាច់តាមតំបន់ទន្លេមេគង្គ និងតាមតំបន់មាត់សមុទ្រ ជាពិសេសនៅខេត្តកោះកុង ដើម្បីបំពេញតម្រូវការក្នុងស្រុក និងការនាំចេញទៅក្រៅប្រទេស ដូចជាទៅកាន់ប្រទេសសិង្ហបុរី តៃវ៉ាន់ និងឥណ្ឌាជាដើម។ យោងតួលេខស្តីពីការនាំចេញខ្សាច់ក្នុងពិភពលោកសម្រាប់ឆ្នាំ ២០១៨ ដែលបានចេញផ្សាយកាលពីខែមិថុនាឆ្នាំ ២០១៩ ដោយគេហទំព័រ World's Top Exports ឬហៅកាត់ថា (WTEx) ដែលស្រាវជ្រាវអំពីការនាំចេញរបស់ប្រទេសនៅជុំវិញពិភពលោក នៅក្នុងចំណោមប្រទេសចំនួន ១៥ ដែលនាំចេញខ្សាច់ច្រើនជាងគេបង្អស់ក្នុងពិភពលោក ប្រទេសកម្ពុជាបានជាប់ចំណាត់ថ្នាក់ទី៧ នាំមុខប្រទេសមួយចំនួនមកពីតំបន់អឺរ៉ុប និងអាហ្វ្រិក។កម្ពុជា ដែលជាប្រទេសដ៏តូចបំផុតមកពីតំបន់អាស៊ីអាគ្នេយ៍ក្នុងចំណោមប្រទេសទាំង ១៥ នេះ បាននាំចេញខ្សាច់ដែលមានទឹកប្រាក់សរុបចំនួន ៣៤ លាន ៦សែនដុល្លារអាមេរិក បន្ទាប់ពីប្រទេសបារាំងដែលជាប់លំដាប់ថ្នាក់ទី៦ ដោយនាំចេញខ្សាច់ក្នុងទឹកប្រាក់ចំនួន ៥៤ លាន ៧ សែនដុល្លារ។ បើប្រៀបធៀបពីឆ្នាំ ២០១៤ ការនាំខ្សាច់កម្ពុជាកើនឡើងចំនួនជាង ៤៦០០ ភាគរយ ដែលស្ថិតក្នុងចំណោមប្រទេសដែលនាំចេញខ្សាច់ដ៏រហ័សបំផុត។ ក្នុងចំណោមប្រទេសទាំង១៥នេះ សហរដ្ឋអាមេរិកជាប់លំដាប់ថ្នាក់លេខ១ ដោយនាំចេញខ្សាច់ជាទឹកប្រាក់សរុប ៥៣៤ លាន ១សែនដុល្លារ។

ក្រុមអ្នកការពារបរិស្ថាននៅកម្ពុជាបានលើកឡើងជាបន្តបន្ទាប់ថាសកម្មភាពបូមខ្សាច់ដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវពីសមត្ថកិច្ចដោយក្រុមហ៊ុនឯកជន និងដែលកើតឡើងដោយសារអំពើពុករលួយ និងបក្ខពួកនិយម បានបង្កជាក្តីកង្វល់ធ្ងន់ធ្ងរខាងបរិស្ថាន និងការប្រឈមខាងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមមូលដ្ឋាន។ ពួកគេយល់ថា អាជីវកម្មបូមខ្សាច់នៅកម្ពុជាផ្តល់ផលប្រយោជន៍ដល់តែក្រុមអ្នកវិនិយោគទុនតែប៉ុណ្ណោះ ហើយអ្នកដែលរងផលប៉ះពាល់ពីសកម្មភាពរុករកធម្មជាតិមួយនេះ គឺប្រជាពលរដ្ឋតាមមូលដ្ឋាន។ ផលប៉ះពាល់ដែលបង្កឡើងដោយការបូមខ្សាច់ រួមមានការបំផ្លាញប្រព័ន្ធជីវៈចម្រុះដ៏សម្បូរបែបរបស់កម្ពុជា ការបាត់បង់ផ្ទះសម្បែងដោយសារតែការបាក់ច្រាំងដី ជាពិសេសសហគមន៍ដែលរស់នៅតាមដងទន្លេមេគង្គ និងការបាត់បង់មធ្យោបាយប្រកបមុខរបរចិញ្ចឹមជីវិត តាមរយៈការនេសាទត្រីសាប និងសមុទ្រជាដើម។

ការបូមខ្សាច់សម្រាប់ការនាំចេញក្រៅប្រទេសនេះគឺជាអាជីវកម្មមួយដែលទទួលបានប្រាក់ចំណេញរាប់រយលានដុល្លារ។ គួររំលឹកផងដែរថា កាលពីឆ្នាំ ២០១៧ របាយការណ៍មួយរបស់អង្គការចលនាមាតាធម្មជាតិបានរកឃើញថា កម្ពុជាបាននាំចេញខ្សាច់ស៊ីលីកាទៅកាន់ដែនកោះតៃវ៉ាន់ ដែលមានតម្លៃជាទឹកប្រាក់ប្រមាណ ៣១ លានដុល្លារអាមេរិកក្នុងចន្លោះឆ្នាំ ២០១២ ដល់ ឆ្នាំ២០១៦ ប៉ុន្តែរបាយការណ៍នេះត្រូវបានរដ្ឋាភិបាលកម្ពុជាច្រានចោល។

នៅខែកក្កដា ឆ្នាំ ២០១៧ ដោយទទួលបានសម្ពាធជាបន្តបន្ទាប់ជុំវិញសកម្មភាពបូមខ្សាច់បែបមិនប្រក្រតី ក្រសួងរ៉ែនិងថាមពលបានចេញសេចក្តីប្រកាសមួយ ដោយបានបញ្ឈប់ការនាំចេញខ្សាច់សំណង់គ្រប់ប្រភេទ រួមទាំងខ្សាច់ល្បាយភក់ នៅខេត្តកោះកុង ចេញទៅក្រៅប្រទេស។ ក្នុងឆ្នាំ ២០១៩ នេះដែរ ក្រសួងបានលុបចោល អាជ្ញាប័ណ្ណធ្វើសិប្បកម្មបូមខ្សាច់ចំនួន ៨ ក្នុងភូមិសាស្ត្រស្រុកស្រែអំបិលនិងស្រុកកោះកុង។ ទោះបីជាក្រសួងរ៉ែ និងថាមពលសម្រេចលុបចោលអាជ្ញាធរអាជីវកម្មរ៉ែក្នុងខេត្តកោះកុងជាច្រើនដងមកហើយក្តី ប្រជាពលរដ្ឋសង្កេតឃើញមានក្រុមហ៊ុនមួយចំនួនពិសេសឈ្មោះឡេងជិនកំពុងបន្តការបូមខ្សាច់ ដោយអត់ច្បាប់ដដែលនៅតាមដងព្រែកស្រែអំបិល និងបើកទីតាំងលក់យ៉ាងអនាធិប្បតេយ្យ។

ក្រោយរបបខ្មែរក្រហម ព្រៃឈើកម្ពុជា ត្រូវបានគេដឹងថាមានប្រមាណ ៧៣ ភាគរយនៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា។ មកដល់បច្ចុប្បន្ននេះ មានទិន្នន័យអំពីព្រៃឈើជាច្រើនខុសៗគ្នា ដែលទទួលបានពីការកំណត់និយមន័យ និងការវិធីសាស្ត្រសិក្សាខុសៗគ្នា។ ការប៉ាន់ស្មានក្រៅផ្លូវការថា ព្រៃឈើនៅកម្ពុជា អាចនៅសល់ប្រហែលជា ៣០ ភាគរយនៃផ្ទៃដីប្រទេស។ព្រៃឈើសេសសល់ ដែលគេស្គាល់ច្រើននោះ មានដូចជា ព្រៃឡង់ (ជាប់ខេត្ត ៤ ៖ ខេត្តក្រចេះ ស្ទឹងត្រែង កំពង់ធំ និងព្រះវិហារ) ព្រៃឈើនៅតំបន់អារ៉ែងខេត្តកោះកុង និងព្រៃឈើជួរភ្នំក្រវាញជាដើម។

ការបាត់បង់ព្រៃឈើ បានបង្កផលប៉ះពាល់ជាច្រើនចំពោះពលរដ្ឋ ជាពិសេស ជនជាតិដើមភាគតិច ដែលត្រូវរងការបណ្តេញចេញពីផ្ទះសម្បែង ដីចម្ការ និងព្រៃសហគមន៍របស់ពួកគេ។ របាយការណ៍អង្គការលីកាដូរកន្លងមក បានរកឃើញថា មានប្រជាជនកម្ពុជាប្រមាណ ៧០ ម៉ឺននាក់ រងប៉ះពាល់ពីជម្លោះដីធ្លីនៅកម្ពុជា។ ទន្ទឹមនឹងជម្លោះដីធ្លី ការកាប់បំផ្លាញព្រៃឈើ បានធ្វើឲ្យប៉ះពាល់មុខរបរពលរដ្ឋ ដូចជា ដងជ័រទឹក បោចវល្លិ៍ ដីចម្ការកសិកម្ម និងអនុផលព្រៃឈើផ្សេងទៀត។ មួយវិញទៀត ការបាត់បង់ព្រៃឈើ ក៏បណ្តាលឲ្យបាត់បង់សត្វព្រៃផងដែរ។ ក្រៅពីនេះ ការបាត់បង់ព្រៃឈើត្រូវបានគេស្តីបន្ទោសថា បានបង្កឲ្យមានគ្រោះធម្មជាតិជាច្រើនបានកើតឡើង ដូចជា គ្រោះទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ។ល។

មានមូលហេតុមួយចំនួន ដែលបណ្តាលឲ្យព្រៃឈើត្រូវបានកាប់បំផ្លាញ។ មូលហេតុមួយ គឺអាចបណ្តាលមកពី ការផ្តល់ដីសម្បទានសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកផ្ទៃដីដាំដុះ ពង្រឹងវិស័យកសិឧស្សាហកម្ម ដូចជា ដំណាំកៅស៊ូ ម្រេច ស្វាយ ដំឡូក ដូងប្រេង... ដើម្បីនាំចេញទៅក្រៅប្រទេស សម្រាប់បង្កើនចំណូលសេដ្ឋកិច្ចជាតិ។ ឆ្លៀតហេតុផលខាងលើនេះ ក្រុមហ៊ុនដីសម្បទានខ្លះ បានយករូបភាពអភិវឌ្ឍន៍នេះ ដើម្បីកាប់ឈើយកទៅលក់។ ក្រុមហ៊ុនខ្លះ មិនត្រឹមតែកាប់ឈើក្នុងរង្វង់ដីសម្បទានប៉ុណ្ណោះទេ តែពួកគេបានកាប់ឈើនៅក្រៅដីសម្បទាន ហើយនាំចូលក្នុងដីសម្បទាន បន្ទាប់មកនាំចេញជាឈើស្របច្បាប់។ មូលហេតុទីពីរ គឺអាចបណ្តាលមកពីអំពើពុករលួយរបស់មន្ត្រីពាក់ព័ន្ធមួយចំនួន ត្រូវរ៉ូវគ្នាជាមួយឈ្មួញរកស៊ីព្រៃឈើ និង មូលហេតុទីបី គឺបណ្តាលមកជីវភាពពលរដ្ឋក្រីក្រ និងកង្វះការយល់ដឹង ទើបជំរុញពួកគេឲ្យចូលព្រៃកាប់ឈើ ដើម្បីលក់ឲ្យឈ្មួញ ខណៈដែលយន្តការទប់ស្កាត់បទល្មើសព្រៃឈើរបស់រដ្ឋាភិបាល ត្រូវបានគេមើលឃើញថា មានភាពទន់ខ្សោយ។សូមបញ្ជាក់ថា កាលពីថ្ងៃទី ២២ សីហា ឆ្នាំ ២០១៦ សម្តេចនាយករដ្ឋម

ន្ត្រី ហ៊ុន សែន បានបង្កើតវេទិកាស្តីពី៖«ការការពារ និង អភិរក្សធនធានធម្មជាតិ» បានប្រកាសទទួលស្គាល់កំហុសចំពោះភាពខ្វះចន្លោះរបស់រដ្ឋាភិបាល ក្នុងការការពារព្រៃឈើ និងធនធានជលផលកន្លងមក។

កន្លងមកមានការអំពាវនាវរបស់ក្រសួងបរិស្ថាន និងរាជរដ្ឋាភិបាល អោយពលរដ្ឋចូលរួមដាំដើមឈើឡើងវិញ នៅតាមទីសាធារណៈ ដូចជា វត្តអារាម សាលារៀន ជាដើម។ តែសកម្មភាពអំពាវនាវមិនបានឆ្លើយនឹងមូលហេតុនៃការបាត់ព្រៃឈើឡើយ។ ការលើកទឹកចិត្តចំពោះការបំផុតអោយពលរដ្ឋចូលរួមចំណែកដាំដើមឈើឡើងវិញ ក៏ដូចជាការបណ្តុះស្មារតីអោយពលរដ្ឋចេះស្រលាញ់បរិស្ថានជាសកម្មភាពប្រសើរ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ឡើយ។ ក្រសួងបរិស្ថានត្រូវបង្ក្រាប និងទប់ស្កាត់រាល់បទល្មើសកាប់បំផ្លាញព្រៃឈើ ពីសំណាក់ក្រុមឈ្មួញរកស៊ី ដែលមានងារជាឧកញ៉ា អោយមានប្រសិទ្ធភាព។ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងស្ថាប័នជំនាញ ត្រូវតែមានយន្តការ ឬវិធានការច្បាប់អោយបានម៉ឺងម៉ាត់បំផុត ចំពោះក្រុមឧក្រិដ្ឋជន ដែលកាប់បំផ្លាញព្រៃឈើ ដ៏មានតម្លៃរបស់កម្ពុជា ។ មកទល់នឹងពេលនេះ ការចុះបង្ក្រាបបតល្មើសព្រៃឈើ ពីសំណាក់ក្រសួងស្ថាប័ន ជាពិសេសគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ហាក់មានភាពស្ងប់ស្ងាត់ទៅវិញ ខណៈការចុះបង្ក្រាបបទល្មើសព្រៃឈើ កាលពីកន្លងទៅ គឺជាការបង្ក្រាបនៅក្នុងរដូវវស្សា ដែលក្រុមឧក្រិដ្ឋជនរកស៊ីឈើ ភាគច្រើន មានការផ្អាកសកម្មភាពរបស់ខ្លួន។ នេះបើតាមការលើកឡើងរបស់សកម្មជនបរិស្ថាន។

របាយការណ៍របស់ក្រសួងបរិស្ថានបានឲ្យដឹង ថារយៈពេល ៩ ខែ ពោលចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០១៩ ចំណូលពីថ្លៃសួយសារព្រៃឈើ បានសរុបចំនួន ២២ ពាន់លានរៀល (ប្រមាណ៥.៥លានដុល្លារ) និងប្រាក់ដុល្លារសរុបចំនួន១២ម៉ឺនដុល្លារអាមេរិក។ របាយការណ៍បានឲ្យដឹងទៀតថា សម្រាប់រយៈពេល ៩ ខែ ឆ្នាំ ២០១៩ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៦៩១ ករណី ដោយពិន័យអន្តរការណ៍ចំនួន ៣៦២ ករណី និងបញ្ជូនទៅតុលាការចំនួន ៣២៩ ករណី ។ ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើ ដែលបានចាប់ឃាត់ និងដកហូតរួមមាន៖ ឈើគ្រាក់ក្រញូងចំនួន ២ ម៉ែត្រគូបនិង ២៣១ គីឡូក្រាម ឈើមូល-ជ្រងសរុបចំនួន ៣៤២ ម៉ែត្រគូប ឈើអារសរុបចំនួន ១,៦៧៩ ម៉ែត្រគូប ផ្ទៃដីព្រៃដែលបានកាប់រានទំហំ ១,៥២២ ហិកតា (ចំនួន ៤៣ ករណី) និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗទៀត។ គួរកត់សម្គាល់ផងដែរថា វិស័យរ៉ែ និងថាមពលត្រូវបានគេរិះគន់ថាខ្វះតម្លាភាពដែលបណ្តាលឲ្យជាប់ពាក់ព័ន្ធយ៉ាងជ្រៅទៅនឹងអំពើពុករលួយ និងខ្វះយន្តការត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។ ការចូលទៅកាន់តំបន់អាជីវកម្មរ៉ែត្រូវបានមានឃាត់យ៉ាងតឹងរឹង និងការពារដោយកងកម្លាំងប្រដាប់អាវុធ។

### 6.3. ការពង្រឹងការគ្រប់គ្រងនគររូបនីយកម្ម

រាជរដ្ឋាភិបាលនឹងអនុវត្តគោលនយោបាយ និងការងារអាទិភាពរបស់ខ្លួនដូចជា៖ ការបន្តជំរុញដំណើរការកែទម្រង់ដីធ្លី និងបង្កើនល្បឿននៃការកសាងផែនការមេ និងប្លង់គោលនៃការរៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលដៅគ្រប់គ្រង និងអភិវឌ្ឍវិស័យដីធ្លីឲ្យកាន់តែមានប្រសិទ្ធភាព។

ការពង្រឹងសមត្ថភាពអនុវត្តការងារនគរូបនីយកម្ម ការងារប្លង់គោលប្រើប្រាស់ដីរាជធានី ការកសាងប្លង់គោលប្រើប្រាស់ដីក្រុង ស្រុក ខណ្ឌ ឃុំ/សង្កាត់នៅទូទាំងរាជធានីខេត្ត ការរៀបចំយុទ្ធសាស្ត្រតំរង់ទិសក្នុងការកំណត់បែងចែកតំបន់ប្រើប្រាស់ និងការគ្រប់គ្រងលំនៅដ្ឋានដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

ការរៀបចំផែនការមេអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជនសំខាន់ៗសម្រាប់គាំទ្រការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក ក៏ដូចជាប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត និងជាពិសេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកង្វក់។

ការជំរុញការអភិវឌ្ឍវិស័យសំណង់ និងការរៀបចំទីក្រុង ទីប្រជុំជន ពិសេសក្រុងប៉ោយប៉ែត និងក្រុងបាវិតដោយជំរុញការអភិវឌ្ឍ និងអង្រឹងការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តិ បច្ចេកទេស និងស្តង់ដារសំណង់ដែលធានាគុណភាព សុវត្ថិភាព សោភ័ណភាព ប្រសិទ្ធភាពខ្ពស់ និងគោលការណ៍ទីក្រុងឆ្លាតវៃ ព្រមទាំងជំរុញអនុវត្តកម្មវិធីអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យ។

ការបន្តពង្រឹងសោភណ្ឌភាព និងសេវាទីក្រុងទីប្រជុំជនសំខាន់ៗតាមរយៈការគ្រប់គ្រងការប្រមូលសំរាម និងអនាម័យ ការរៀបចំផ្លូវថ្មើរជើង ទីធ្លាចំណត ការរៀបចំសួនច្បារសាធារណៈ ការកសាង និងការពារច្រាំងទន្លេ និងទនប់ ការរៀបចំសណ្តាប់ធ្នាប់ និងភ្លើងបំភ្លឺនៅក្នុងក្រុង ការអភិរក្សសំណង់ដែលមានតម្លៃប្រវត្តសាស្ត្រ ព្រមទាំងបន្តការរៀបចំពង្រីក និងពង្រឹងគុណភាពក៏ដូចជាជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងក្រុង។

សម្រាប់វិស័យសំណង់វិញ តាមរបាយការណ៍របស់ក្រសួង ក្នុងឆមាសទី ១ ឆ្នាំ ២០១៩ ទំហំនៃការវិនិយោគលើវិស័យសំណង់មានការកើនឡើង ធៀបនឹងរយៈពេលដដែលក្នុងឆ្នាំ ២០១៨ កន្លងទៅ ហើយក៏រំពឹងថានឹងបន្តកើនឡើងរហូតបំណាច់ឆ្នាំ។ ការអភិវឌ្ឍនគរូបនីយកម្ម អចលនទ្រព្យ និងសំណង់កំពុងមានកំណើនក្នុងសន្ទុះដ៏លឿន បានក្លាយជាសសរស្តម្ភស្នូលនៃការជំរុញកំណើនសេដ្ឋកិច្ចជាតិ ជាក់ស្តែងទុនវិនិយោគក្នុងវិស័យសំណង់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ មានទំហំវិនិយោគ ២៨ ពាន់លានដុល្លារ។ ការវិនិយោគលើអគារពាណិជ្ជកម្មចម្រុះក៏កំពុងមានការរីកចម្រើន ខណៈលំនៅដ្ឋានតម្លៃសមរម្យកំពុងទទួលបានការយកចិត្តទុកដាក់ពីក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ដើម្បីផ្តល់លទ្ធភាពដល់អ្នកទិញដែលមានចំណូលទាប និងចំណូលមធ្យម។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងរៀបចំគោលនយោបាយជាតិស្តីពីនគរូបនីយកម្មកម្ពុជា និងច្បាប់ស្តីពីការរៀបចំដែនដី និងនគររូបនីយកម្មដែលគ្រោងស្នើសុំអនុម័តនូវឆ្នាំ ២០២០ ដើម្បីឆ្លើយតបទៅនឹងកំណើនលឿនរហ័សនៃការអភិឌ្ឍន៍គរូបនីយកម្ម អចលនទ្រព្យ និងសំណង់។ ក្នុងដំណើររៀបចំគោលនយោបាយ និងច្បាប់នេះក្រសួងបានទទួលធាតុចូលដូចជា ចំណេះដឹង បទពិសោធន៍ និងគំរូអនុវត្តល្អៗលើការគ្រប់គ្រង និងការអភិវឌ្ឍទីក្រុងប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាប័ន្នពីក្រុមអ្នកជំនាញបរទេសផ្នែកនគររូបនីយកម្ម។

ស្របពេលដែលវិស័យសំណង់នៅកម្ពុជាកំពុងតែរីកចំរើន ក៏មានបញ្ហាប្រឈមមួយចំនួនកើតចេញពីវិស័យនេះផងដែរ។ គេនៅចាំបានថានៅឆ្នាំ ២០១៩ ដើមឆ្នាំ ២០២០ នៅកម្ពុជាបានកើតមានព្រឹត្តិការណ៍គ្រោះថ្នាក់ដោយសារការរលំបាក់អគារ នៃគម្រោងវិនិយោគសណ្ឋានគារនៅខេត្តព្រះសីហនុ និងខេត្តកែប។ គ្រោះថ្នាក់នេះបានបណ្តាលឲ្យបាត់បង់ជីវិតប្រជាពលរដ្ឋជាកម្មករសំណង់ជាច្រើននាក់ផងដែរ។ រាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធបានវាយតម្លៃថាគ្រោះថ្នាក់នេះកើតឡើងដោយសារសំណង់កំហុសបច្ចេកទេសនៃការសាងសង។

ក្រសួងដែនដីនគរូបនីកម្ម និងសំណង់បានឲ្យដឹងថា ម្ចាស់សំណង់តម្រូវឱ្យមានក្រុមហ៊ុនមើលការសំណង់នៅការដ្ឋាន ដើម្បីឱ្យក្រុមហ៊ុននេះទទួលខុសត្រូវរាល់ពេលមានហានិភ័យណាមួយកើតឡើង ដើម្បីឱ្យក្រុមហ៊ុនមើលការសំណង់នោះមើលការខុសត្រូវពីស្តង់ដាសុវត្ថិភាព និងគុណភាពសំណង់។ ក្រសួងថែមទាំងពង្រឹងបន្ថែមនូវការអនុវត្តអំពីការផ្សព្វផ្សាយ ប្រជាពលរដ្ឋដែលមានគម្រោងសាងសង់ និងក្រុមហ៊ុនសាងសង់បានដឹង និងចុះបញ្ជីឱ្យបានត្រឹមត្រូវច្បាស់លាស់ ងាយស្រួលក្នុងការគ្រប់គ្រង។

ចំពោះបញ្ហាចុះបញ្ជីដីធ្លីនិងការចេញបណ្ណកម្មសិទ្ធ ក្រសួងបានជំរុញការងារនេះជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស កុំមានការធ្វេសប្រហែស ឬយឺតយ៉ាវក្នុងការពន្លឿនការងារនេះឱ្យបានចប់សព្វគ្រប់តាមផែនការដែលបានកំណត់។ របាយការណ៍សរុបលទ្ធផលការងាររបស់ក្រសួងបានឲ្យដឹង គិតត្រឹមខែធ្នូឆ្នាំ ២០១៩ ក្រសួងបានចេញបណ្ណកម្មសិទ្ធិដីធ្លីបានចំនួន ៦២៥.៦៨៦ បណ្ណ ស្មើនឹង ៨០,៣៧% នៃក្បាលដីប៉ាន់ស្មាន ៧ លានក្បាលដី ក្នុងនោះការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន ៥.០០៨.១០៥ បណ្ណ និងបានចែកជូនប្រជាពលរដ្ឋចំនួន ៤.៦៦៣.០៥៦ បណ្ណ និងចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបាន ៦១៧.៥៨១ បណ្ណ។

ទោះបីយ៉ាងនេះក្តី អំឡុងពេលការចុះបញ្ជីដីធ្លីកំពុងដំណើរការ ជម្លោះ និងអំពើពុករលួយត្រូវបានគេចាត់ទុកថាជាបញ្ហាចំបងក្នុងផែនការគ្រប់គ្រងដីធ្លីរបស់រដ្ឋាភិបាល។ ការបង់ពន្ធលើការលក់ដូរដីធ្លីត្រូវទទួលរងការរិះគន់ជារឿយៗថាខ្វះខាតគោលនយោបាយជាក់លាក់។ ក្នុងករណីដែលកើតមានជារឿយៗ តម្លៃនៃការបង់ពន្ធនេះខុសប្លែកពីគ្នា ដោយអាស្រ័យលើការសម្រេចរបស់មន្ត្រីដែលផ្តល់សេវានេះ។

### 6.4. ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

រាជរដ្ឋាភិបាលនឹងអនុវត្តគោលនយោបាយ និងការងារអាទិភាពរបស់ខ្លួនដូចជា៖ ការបន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ២០១៣-២០៣០ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ យុទ្ធសាស្ត្រ និងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦-២០២៣ ផែនការយុទ្ធសាស្ត្រជេវបុកជាតិ និងការប្រើប្រាស់មូលនិធិបរិស្ថានសង្គមឲ្យមានប្រសិទ្ធភាព ដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ចបំភាយកាបូនទាប និងធននឹងការប្រែប្រួលអាកាសធាតុ។

ការបន្តពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ អភិរក្សជីវៈចម្រុះ អភិរក្សសម្បត្តិធម្មជាតិ ពិសេសប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរ។

ការពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន និងសារធាតុគ្រោះថ្នាក់តាមរយៈការអនុវត្តគោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ ការកែច្នៃឡើងវិញ និងការបដិសេធ ព្រមទាំងពង្រឹងយន្តការតាមដាន និងត្រួតពិនិត្យការបំពុល។

ការលើកកម្ពស់ការរស់នៅដោយមានប្រសិទ្ធភាព និងចីរភាពធនធានតាមរយៈការអនុវត្តគោលការណ៍នៃការប្រើប្រាស់ និងផលិតកម្មប្រកបដោយចីរភា (Sustainable Consumption and Production)។

ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាភាតរបិស្ថាន និងភាតរអាកាធាតុ (Environmental- Friendly and Climate- friendly Technologies) ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ការជំរុញអនុវត្តយន្តការពាណិជ្ជកម្មកាបូន និងក្របខណ្ឌគតិយុត្តិពាក់ព័ន្ធ ការពង្រឹងសមត្ថភាពរៀបចំ និងអនុវត្តវិធានការដើម្បីបន្សាំ និងធនទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការពីនិត្យលទ្ធភាពសិក្សាពីភាពធនផ្នែកហិរញ្ញវត្ថុក្នុងការឆ្លើយតបទៅគ្រោះមហន្តរាយបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

ការបន្តជំរុញការអភិវឌ្ឍ និងអនុវត្តផែនការគ្រប់គ្រងទឹកចំម្រុះ (Integrated Water Resource Management) ដើម្បីពង្រឹងការគ្រប់គ្រងទឹកឲ្យបានគ្រប់គ្រាន់តាមតម្រូវការ កាត់បន្ថយជាអតិបរមានូវហានិភ័យបណ្តាមកពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងធនជានសន្តិសុខទឹករយៈពេលវែង។

ការបន្តការលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាត និងថាមពលកើតឡើងវិញពិសេសថាមពលពន្លឺព្រះអាទិត្យ ទទ្ទឹមនឹងការកាត់បន្ថយការផលិតថាមពលពីប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង។

ការពង្រឹងក្របខណ្ឌគតិយុត្ត ព្រមទាំងការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាពជំនាញ និងចំណេះដឹងដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានទឹកចម្រុះ និងការប្រើប្រាស់ធនធានប្រកបដោយចីរភាព។

នៅកម្ពុជា សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុហាក់ដូចជាមិនទាន់បានអនុវត្តយ៉ាងសកម្មនោះទេ។ របាយការណ៍នៅឆ្នាំ ២០១៨ បានឲ្យដឹងថា នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព គិតត្រឹមចុងឆ្នាំ ២០១៨ បាននូវការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រធំៗរបស់ជាតិ រួមមាន យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ (មុំទី ៤ នៃសសរស្តម្ភទី ៤ "ការធានានិរន្តរភាពបរិស្ថាន និងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ"), គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា (គោលដៅទី១៣ "សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ"), និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ តែប៉ុណ្ណោះ។ ស្ថាប័ននេះបានរំពឹងទុកថា នឹងផ្តោតទៅលើការងារធំៗដែលផ្តល់ផលប៉ះពាល់វិជ្ជមានយូរអង្វែងដល់សហគមន៍មូលដ្ឋាន ការសិក្សាស្រាវជ្រាវសម្រាប់ជាធាតុចូលដល់ការរៀបចំគោលនយោបាយ ដោយផ្អែកលើវិទ្យាសាស្ត្រ។

## IX. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ បានកើតចេញពីលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០១៨ ។ ថ្នាក់ដឹកនាំរដ្ឋសភា បានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាលនីតិកាលទី៦ នេះ ដោយប្រើប្រាស់នីតិវិធីបោះឆ្នោតជាកញ្ចប់តាមមាត្រា ៣ នៃច្បាប់ធម្មនុញ្ញបន្ថែម ខណៈពេលដែលការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយនីតិវិធីបោះឆ្នោតដោយឡែកនៃមាត្រា ៨២ និង ១១៩ ថ្មី នៃរដ្ឋធម្មនុញ្ញអាចអនុវត្តទៅបាន។

រាជរដ្ឋាភិបាលនីតិកាលទី៦ មានសមាជិកត្រឹមតែចំនួន ៤៦ រូប ប៉ុន្តែមានមន្ត្រីជាន់ខ្ពស់យ៉ាងហោចណាស់ចំនួន ៨៥៨ រូប ដែលជារដ្ឋលេខាធិការ ២៤១ រូប អនុរដ្ឋលេខាធិការ៣ ៩១ រូប រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ១៩ រូប និងទីប្រឹក្សារដ្ឋាភិបាល ២០៧ រូប។ រដ្ឋាភិបាលមានគោលនយោបាយធ្វើកំណែទម្រង់អភិបាលកិច្ចល្អក្នុងស្ថាប័នសាធារណៈ ការកើនឡើងនៃចំនួនមន្ត្រីជាន់ខ្ពស់ គឺមិនអាចបង្ហាញអំពីប្រសិទ្ធភាពនៃកំណែទម្រង់បានឡើយ។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ដែលបានបង្កើតថ្មី ដោយមិនទទួលបាននីត្យានុកូលភាពជាតំណាងពីប្រជាពលរដ្ឋ ត្រូវបានចាត់ទុកថាជាយន្តការក្រៅសភាដែលទទួលជាតុចូលបន្ថែមពីគណបក្សនយោបាយ នៅពេលសភាមានតំណាងរាស្ត្រមកពីគណបក្សតែមួយ ប៉ុន្តែមិនមានស្វ័យភាពថវិកា និងមិនត្រូវបានផ្តល់ឯករាជ្យភាពពេញលេញក្នុងការបំពេញភារកិច្ច។

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៦ អនុវត្តគោលនយោបាយ និងកិច្ចការងារជាអាទិភាពដែលបានចែង ឬសន្យា តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ប៉ុន្តែគោលនយោបាយទាំងនោះ មិនបានកំណត់នូវសូចនាករច្បាស់លាស់ដើម្បីវាស់វែងពីសមិទ្ធផលនោះទេ។ ក្នុងរយៈពេលជាង ១ ឆ្នាំកន្លងទៅនេះ រដ្ឋាភិបាលបានអនុវត្តផ្នែកខ្លះនូវគោលនយោបាយរបស់ខ្លួន។

ទោះយ៉ាងណា ក្នុងរយៈពេលជាងមួយឆ្នាំដំបូងនៃការកាន់អំណាចនេះ ការខិតខំរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន ត្រូវបានជួបបញ្ហាប្រឈមធំៗទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ។ ទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ការកំណត់លក្ខខណ្ឌដោយសហគមន៍អឺរ៉ុបទាក់ទងនឹងការព្យួរប្រព័ន្ធអនុគ្រោះពន្ធ EBA នៅតែបន្តចាត់ទុកថាជារបៀបវារៈនយោបាយរវាងកម្ពុជា និងអឺរ៉ុប។ ចំណែកឯពាក់ព័ន្ធផ្នែកនយោបាយវិញ រដ្ឋាភិបាលបច្ចុប្បន្នបានដំណើរការទៅ ដោយគ្មានគណបក្សប្រឆាំងចំបងនៅក្នុងប្រទេស ហើយទំនាក់ទំនងជិតស្និទ្ធរវាងកម្ពុជាជាមួយចិន បានបង្កជាឧបសគ្គដល់ទំនាក់ទំនងរវាងកម្ពុជា ជាមួយប្រទេសលោកខាងលិច។ ដោយឡែកពាក់ព័ន្ធផ្នែកសង្គមកិច្ចវិញ រដ្ឋាភិបាលចាំបាច់ត្រូវកំណត់យកវិធីសាស្ត្រដោះស្រាយបញ្ហាជម្លោះនយោបាយរវាងគណបក្សចម្បងទាំងពីរ។ ទន្ទឹមនឹងនេះដែរ ប្រសិទ្ធភាពនៃការអនុវត្តន៏ច្បាប់និង ឯករាជ្យភាពនៃប្រព័ន្ធតុលាការនៅតែជាបញ្ហាចំបងដែលរាជរដ្ឋាភិបាលនៅមិនទាន់អាចធ្វើឲ្យពលរដ្ឋអាចជឿរទុកចិត្តបាននៅឡើយ។